# ការពន្យល់អំពីព្រះពុទ្ធសាសនា

## ពន្យល់អំពី

## សាសនា និង សង្គម

## បែបទស្សនវិជ្ជា

ប្រែនិងរៀបរៀងដោយ

**ភិក្ខុ ព្រំ ស៊ីណា**

ព.ស. ២៥៤៨ គ.ស ២០០៤

# ពុទ្ធសាសនាវណ្ណនា

ពន្យល់អំពី

## សាសនា និង សង្គម

បែបទស្សនវិជ្ជា

សម្រាប់អ្នកអានគ្រប់មជ្ឈដ្ឋាន

ដោយភិក្ខុ ព្រំ ស៊ីណា

ព.ស ២៥៤៨ គ.ស ២០០៤

# AN EXPOSITION OF BUDDHISM

By

Ven. Pidiville Piyatissa

Translated into Khmer by
Bhikkhu Prum Sina
(Sañjātavīviyo)

B.C. 2548 A.D. 2004

# មាតិកានុក្រម

ទំព័រ


❀ បុព្វកថា ........................................................ ក
❀ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ........................................ ០១
❀ ការផ្សព្វផ្សាយនៃព្រះពុទ្ធសាសនា .................................. ៣១
❀ តើបុគ្គលអាចក្លាយជាពុទ្ធសាសនិកដោយរបៀបណា? ....... ៣៥
❀ តើពុទ្ធសាសនិកបួងសួងចំពោះព្រះពុទ្ធដែរឬទេ? ................ ៤១
❀ ការស្រាយបំភ្លឺរបស់ព្រះពុទ្ធសាសនាអំពីជីវិតក្រោយពេលស្លាប់ ........................................................ ៤៥
❀ ទំនៀមទម្លាប់បុណ្យបូជាសពរបស់ពុទ្ធសាសនិក ................ ៥៥
❀ ពិធីបុណ្យនានាក្នុងព្រះពុទ្ធសាសនា .................................. ៦១
❀ ទស្សនៈព្រះពុទ្ធសាសនាអំពីអាទិទេព ឬ ពហុទេព ............ ៦៥
❀ ព្រះពុទ្ធសាសនា និង ការបែងចែកវណ្ណៈក្នុងសង្គម ............ ៧៥
❀ ព្រះពុទ្ធសាសនា និង សង្គមវប្បធម៌ចម្រុះ ......................... ៨៥
❀ ទស្សនៈព្រះពុទ្ធសាសនាអំពីការថែទាំមនុស្សចាស់ជរា ....... ៩១
❀ ទស្សនវិស័យព្រះពុទ្ធសាសនាអំពីចរិតឃោរឃៅ ............... ៩៧

❁ គោលដៅជីវិត ........................................................................ ១១១
❁ បរិសិដ្ឋ ........................................................................................ ១១៧

# បុព្វកថា

នៅពេលដែលអ្នកកាន់សាសនាដទៃ ចូលមកកាន់ទីសក្ការៈបូជារបស់យើង ភាគច្រើនពួកគេបានចង្អុលទៅកាន់ពុទ្ធបដិមា ហើយសួរខ្ញុំថា ៖ “តើនោះជាព្រះរបសខ្ញុំអ្នកឬ?”

នៅពេលដែលខ្ញុំឆ្លើយថា“ទេ!”នោះសំនួរបន្ទាប់ទីពីររបស់ពួកគេគឺ ៖ “អ៊ីចឹង នោះជាអ្នកបង្រៀនខាងសាសនា ឬក៏ជាសាសនទូតនៃព្រះរបស់អ្នកឬ?” ខ្ញុំក៏ពន្យល់ពួកគេនូវសំនួរទាំងឡាយ ទាក់ទងនឹងព្រះពុទ្ធសាសនា។

ជារឿយៗ ខ្ញុំនិយាយថា ប្រសិនបើអ្នកចង្អុលទៅប៊ិចដែលមានពណ៌ក្រហមមួយដើម ហើយសួរថា ៖ “សូមប្រាប់មក តើប៊ិចនេះពណ៌ខ្មៅ ឬ ពណ៌ខៀវ?” ចំលើយពិតជាថា ៖ “មិនមែនពណ៌ខ្មៅ ហើយក៏មិនមែនពណ៌ខៀវដែរ”។ ម្ល៉ោះហើយខ្ញុំជឿជាក់ថា នៅពេលដែលសួរសំនួរណាមួយនោះ យើងត្រូវតែយល់ដឹងឲ្យបានច្បាស់ពីសភាពពិតនៃសំនួររបស់យើង។

ខ្ញុំយល់ថា ជាការងាយស្រួលណាស់ដើម្បីឆ្លើយនូវសំនួរដែលថា៖ “តើនោះជានរណា?” “តើប៊ិចនេះមានពណ៌អ្វី?” ជាដើម ជាជាងសួរសំនួរទាំងឡាយខាងលើ។

ការពិតដែលសំខាន់ជាងនេះទៅទៀត យើងត្រូវយល់ដឹងថា យើងគួរតែព្យាយាមឲ្យអស់ពីលទ្ធភាព ដើម្បីយល់នូវអត្ថន័យនៃវប្បធម៌ពិសេស ដែលប្រឫកប្រឫល់ ជាជាងឈានទៅរកបំណាក ស្រាយ និងការសន្និដ្ឋានទាំងឡាយរបស់យើង ដោយអត្តនោម័តៗ ទង្វើបែបនេះ នឹងបង្ការមិនឲ្យយើងធ្វើការបកស្រាយ និងការសន្និដ្ឋានខុសៗ

ដូច្នេះហើយ បានជាខ្ញុំសរសេរសៀវភៅនេះឡើង ដើម្បីណែនាំអ្នកកាន់សាសនាដទៃឲ្យស្គាល់ពីព្រះពុទ្ធសាសនាៗ ជាពិសេស ខ្ញុំជឿជាក់ថា សៀវភៅនេះនឹងជាគុណប្រយោជន៍ សម្រាប់សិស្សានុសិស្សទាំងឡាយ ដែលកំពុងស្វែងយល់ពីការសិក្សាផ្នែកសាសនា និងជនគ្រប់រូបដែលចាប់អារម្មណ៍ ក្នុងព្រះពុទ្ធសាសនាៗ បើតាមបទពិសោធន៍ដែលខ្ញុំមានផ្ទាល់ ក្នុងលោកខាងលិចជាមួយនឹងជនដែលកាន់សាសនាដទៃ ខ្ញុំយល់ថាមានកស្សិណោសមហេតុសមផល ដើម្បីបង្ហាញថាព្រះពុទ្ធសាសនាកំពុងរីកចំរើនបន្តិចម្តងៗ ប៉ុន្តែច្បាស់ជាមានការនិយមបំផុត ក្នុងចំណោមប្រជាជននៃបណ្តាសង្គមលូតលាស់ផ្នែកឧស្សាហកម្មៗ

ទោះបីជាមានសៀវភៅជាច្រើន បានសរសេរអំពីព្រះពុទ្ធសាសនាយ៉ាងណាក៏ដោយ ក៏តម្រូវការដូចបានពោលមកខាងលើហាក់បីដូចជាពុំទាន់គ្រប់គ្រាន់នៅឡើយ។ នេះជាមូលហេតុដ៏ចំបងដូច្នេះបានជាខ្ញុំសម្រេចចិត្តសរសេរជាសៀវភៅនេះឡើង។

ហាក់មានការយល់ខុស និងបំណកស្រាយខុសក៏ថាបានអំពីអ្នករកឃើញព្រះពុទ្ធសាសនា ហើយនឹងសង្ឃសាវ័ក (ព្រះសង្ឃនិងឧបាសកឧបាសិកា)។ សៀវភៅនេះដោះស្រាយ នូវចំនុចខ្វែងគំនិតគ្នា ហើយខ្ញុំក៏បានព្យាយាមអស់ពីលទ្ធភាព ដើម្បីសិក្សាពាក្យប្រៀនប្រដៅពិតៗរបស់ព្រះសម្មាសម្ពុទ្ធនៃយើង។ ចាប់តាំងពីព្រះពុទ្ធសាសនាត្រូវបានគេប្រតិបត្តិ នៅក្នុងបណ្តាប្រទេសនានាអស់រយៈកាលជាច្រើនសតវត្សរ៍មក រឿងនេះក៏ អាចនិយាយបានថា ការចង់ដឹងរបស់ជនបរទេសត្រូវបានគេរាប់បញ្ចូល ចំពោះរឿងនេះផងដែរ។ ក៏ប៉ុន្តែ ខ្ញុំត្រូវការចៀសវាងរឿងរ៉ាវបែបនេះនៅពេលដែលខ្ញុំដោះស្រាយតាមរយៈការសិក្សា ហើយខ្ញុំក៏បានយកចិត្តទុកដាក់ ចំពោះសំនួរដែលគួរឲ្យចូលចិត្ត ហើយក៏ពេញចិត្តនឹងឆ្លើយនូវសំនួរដូចជា ៖ “តើនោះជាព្រះរបស់អ្នកឬ?”។

# ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ

## ព្រះពុទ្ធ

ព្រះពុទ្ធជាអ្នកបង្កើតព្រះពុទ្ធសាសនា។ ពាក្យថា "**ព្រះពុទ្ធ**" ជាឈ្មោះ ដែលគេដាក់អោយ ដែលមានន័យថា "**អ្នកត្រាស់ដឹង**"។ ព្រះគោត្តនាម របស់ព្រះអង្គគឺ "**គោតម**" ហើយព្រះនាម របស់ព្រះអង្គគឺ "**សិទ្ធត្ថ**" ដែលមានន័យថា "អ្នកដែលអាចធ្វើឲ្យសម្រេចប្រយោជន៍គ្រប់យ៉ាង"។ យើងដឹងថា ព្រះអង្គទ្រង់ប្រសូត នៅក្នុងវង្សក្សត្រនៃនគរហិមាល័យតូច នៅក្នុងប្រទេសឥណ្ឌា។ ព្រះបិតារបស់ព្រះអង្គ ព្រះនាមព្រះបាទ**សុទ្ធោទនៈ** និងព្រះមាតា របស់ព្រះអង្គ ព្រះនាមព្រះនាង**មហាមាយា** (មាតាដែលមានអភិនិហាន៍)។ ទ្រង់ប្រសូតនៅថ្ងៃនក្ខត្តឫក្សពេញបូណ៌មី ១៥ កើត ខែពិសាខ (ខែឧសភា) ៦២៣ ឆ្នាំមុនគ្រិស្តសករាជ។ ព្រះពុទ្ធទ្រង់ពុំបានណែនាំខ្លួនព្រះអង្គថាជាអាទិទេព ឬក៏ជាសាសនទូតនៃព្រះអាទិទេព ឬក៏ជាអ្នកបង្រៀនខាងសាសនា ឬក៏ប្រកាសថាជាតួអង្គ ឬអ្វីផ្សេងទៀត ដែលមានការទាក់ទងជាមួយអំណាចអភិធម្មជាតិនោះទេ។ ព្រះអង្គបានប្រសូតមកជាមនុស្ស នៅកន្លែងមួយឈ្មោះ

ថា ឧទ្យានលុម្ពិនី នៅក្នុងប្រទេសនេប៉ាល់ ជិតព្រំដែនប្រទេសឥណ្ឌា។ ព្រះអង្គ បានត្រាស់ដឹងជាព្រះពុទ្ធក្នុងព្រះជន្ម ៣៥ ព្រះវស្សា ក្រោមដើមពោធិព្រឹក្ស ដោយគ្មានការដឹកនាំ ឬជំនួយពីអំណាចអភិធម្មជាតិណាមួយទេ ហើយព្រះអង្គចូលបរិនិព្វានក្នុងព្រះជន្មាយុ៨០ព្រះវស្សា នៅចន្លោះដើមសាលព្រឹក្សទាំងគូ នៅក្នុងឧទ្យានឧបវ័ន ក្នុងរាជធានីតូចមួយឈ្មោះថា **កុសិនារា** (កោះកូស៊ីណាហ្គាទំនើប)។ មួយជីវិតរបស់ព្រះអង្គគ្មានកសិណសាក្សីអ្វីដែលគួរឲ្យជឿជាក់ថា ព្រះអង្គមានការទាក់ទងជាមួយអាទិទេពណាមួយឡើយ។ ជាងនេះទៅទៀត នៅក្នុងឱកាសជាច្រើន ព្រះអង្គបានបដិសេធ ដោយខ្លួនព្រះអង្គផ្ទាល់ ថាគ្មានការទាក់ទងជាមួយអាទិទេពទេ។

ព្រះបិតារបស់ព្រះអង្គ មានព្រះរាជហឫទ័យសប្បាយរីករាយជាខ្លាំង ដោយមានព្រះរាជបុត្រស្នងរាជជំនួសព្រះអង្គ។ ប៉ុន្តែព្រះអង្គមិនសប្បាយព្រះទ័យ នៅពេលដែលព្រាហ្មណ៍ម្នាក់បានទស្សន៍ទាយថា បើព្រះរាជបុត្រដែលទើបប្រសូត មិនបានក្លាយជាស្ដេចចក្រទេ នោះព្រះអង្គនឹងក្លាយទៅជាព្រះពុទ្ធ (ព្រះបរមសាស្ដាចារ្យខាងសាសនា)។

ព្រះបាទសុទ្ធោទន៍បានដឹងច្បាស់ថា ដំណើរជីវិតដ៏សែនលំបាកឈឺចាប់ នឹងធ្វើឲ្យចិត្តគំនិតរបស់ព្រះសិទ្ធត្ថ បែរផ្ដោះទៅរកសាសនា។ ដូច្នេះ ព្រះអង្គបានធ្វើអ្វីគ្រប់បែបយ៉ាង ដោយអំណាចរបស់ព្រះអង្គដើម្បីឃុំគ្រង ជីវិតរបស់ព្រះរាជបុត្រឲ្យស្ថិតនៅក្នុងពិភពលោកមួយ ដែលមានសុវត្ថិភាព និងបរិបូណ៌ដោយគ្រឿងប្រណិតគ្រប់បែបយ៉ាង។ ពេលព្រះអង្គ (ព្រះសិទ្ធត្ថ) ពេញវ័យឡើង ព្រះអង្គបានរៀបអភិសេកជាមួយព្រះនាង **យសោធរា** ហើយប្រសូតបានបុត្រាមួយអង្គ ព្រះនាម**រាហុល** ។

ទោះបីជាយ៉ាងណាក៏ដោយ ថ្ងៃមួយព្រះអង្គបានរៀបចំចេញដំណើរ ទៅទតមើលជីវិតអ្នកភូមិធម្មតាមួយ។ ព្រះអង្គបានយាងទៅទីនោះបួនលើក ហើយបានធ្វើឲ្យជីវិតរបស់ព្រះអង្គផ្លាស់ប្ដូរ។ លើកទីមួយ ព្រះអង្គបានទតឃើញ មនុស្សចាស់ជរា លើកទីពីរទតឃើញ មនុស្សឈឺ និងលើកទីបីទតឃើញ មនុស្សកំពុងដង្ហែរសាកសពទៅបូជា។ ការមិនធ្លាប់ឃើញវ័យចាស់ជរា ជម្ងឺ និងការស្លាប់ពីមុនមក បានធ្វើឲ្យព្រះអង្គរន្ធត់ញាប់ញ័រពេញព្រះកាយ។ ជាកាពិតប្រាកដណាស់ ការរន្ធត់ញាប់ញ័របានធ្វើឲ្យជីវិតនៅក្នុងរាជវាំងរបស់ព្រះអង្គ លែងមានសេចក្ដីសុខតទៅមុខទៀតហើយ

រហូតដល់ ធ្វើឲ្យព្រះអង្គអត់ទ្រាំលែងបាន។ ព្រះអង្គបានរំពឹងគិតទៅរកភាពពិត នៃសេចក្តីទុក្ខ និងការស្វែងរកវិធីដើម្បីរំលត់សេចក្តីទុក្ខនោះ។

ដំនើរយាត្រាលើកទី៤ ព្រះអង្គបានឃើញនូវវិធីដែលអាចរកឃើញចំលើយនៃចំនោទរបស់ព្រះអង្គ។ ព្រះអង្គបានជួបទេវទូតមួយអង្គក្លែងភេទ ជាអ្នកបួសដែលបានលះបង់ទ្រព្យសម្បត្តិគ្រប់បែបយ៉ាង ដើម្បីដើរតាមមាគ៌ា សាសនាក្នុងការរស់នៅ។ ទោះបីគ្មានអ្វីសោះក៏ដោយ អ្នកបួសមានសេចក្តីស្ងប់ស្ងៀមដ៏រុងរឿងដែលត្រូវនឹងទឹកព្រះទ័យរបស់ព្រះអង្គ ដែលថាមិនដឹងជាធ្វើយ៉ាងម៉េច ដើម្បីឲ្យត្រូវទៅនឹងសេចក្តីពិតនៃទុក្ខដែលមិនគួរឲ្យសប្បាយរីករាយ។

ដូច្នេះ ព្រះសិទ្ធត្ថបានសម្រេចព្រះទ័យដើរតាមគំរូរបស់ទេវទូត។ ព្រះអង្គបានសព្វព្រះរាជហឫទ័យ ចាកចេញពីព្រះរាជវាំង ទាំងកណ្តាលអាធ្រាត។ ផ្លាស់ប្តូរសំពត់កម្ពលរបស់ព្រះអង្គចេញ ដោយស្លៀកពាក់សំលៀកបំពាក់ ធម្មតាដូចអ្នកបួស ហើយកាត់ព្រះកេសាដ៏ខ្មៅរលោងស្អាត ទុកឲ្យនៅសល់ត្រឹមប្រវែង២ធ្នាប់។ បន្ទាប់មកគ្មានយកអ្វីទៅទាំងអស់ លើងលែងតែ

បាត្រមួយ ហើយព្រះអង្គបានតាំងចិត្តនៅក្នុងសមាបត្តិ។

ព្រះអង្គបានស្វែងរកគ្រប់គ្រូល្បីៗ ហើយរៀននូវអ្វីៗដែលគ្រូបង្រៀនបានចេះសព្វគ្រប់។ បន្ទាប់មកព្រះអង្គបានធ្វើឲ្យរាងកាយព្រះអង្គ ទទួលរងទារុណកម្មនិងលំបាកក្រៃលែង។ ព្រះអង្គបានរស់នៅក្នុងព្រៃស្មសាន ពេលថ្ងៃដុតព្រះកាយនឹងកំដៅព្រះអាទិត្យ ពេលយប់ត្រូវទឹកសន្សើមជំ សឹងនៅលើបន្លា ហើយពេលខ្លះគង់នៅក្នុងទីស្មសាន មិនធាន់ចង្ហាន់ រហូតទៅជាស្គមព្រះកាយ ហើយប្រសិនបើព្រះអង្គស្ទាបព្រះឧទរ ព្រះអង្គមានអារម្មណ៍ ថា ប៉ះនិងឆ្អឹងខ្នង។ ប៉ុន្តែ ព្រះអង្គនៅតែមិនអាចរកឃើញពន្លឺនៃការត្រាស់ដឹង ហើយព្រះអង្គបានដឹងថា ប្រសិនបើប្រព្រឹត្តបែបនេះព្រះអង្គប្រហែលជា សុគតមុនត្រាស់ដឹង។

ហេតុនេះហើយ បានជាព្រះអង្គចាប់សោយនូវចង្ហាន់តាមធម្មតាវិញ ដែលជាទីជិនធ្ងន់នៃភិក្ខុ៥រូប ដែលបានរត់ចោលព្រះអង្គ។ បន្ទាប់មកព្រះអង្គបានគង់នៅទីងមួយកន្លែង ក្រោមដើមពោធិព្រឹក្ស ដែលសព្វថ្ងៃគេហៅកន្លែងនោះថា**ពោធិគយា**។ ព្រះអង្គបានប្តេជ្ញាថានឹងគង់នៅទីនោះ រហូតបានត្រាស់ដឹង ពុំនោះទេព្រះអង្គនិងព្យាយាមរហូតដល់សុគត។

ក្នុងរាត្រីពេញបូណ៌មី១៥កើតខែពិសាខ ព្រះអង្គបានចូលឈានយ៉ាងជ្រៅ ហើយបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិធម៌ៗ ព្រះអង្គបានរលឹកនូវជាតិទាំងឡាយ នៅក្នុងអតីតដែលបានកន្លងទៅរាប់សែនជាតិ សំវដ្តកប្ប និងវដ្តកប្ប ព្រះអង្គបានឃើញនូវការប្រព្រឹត្តទៅនៃកម្ម ដែលមានផលមិនអាចចៀសវាងបាន កុសលកម្មឲ្យផលជាកុសល អកុសលកម្មឲ្យផលជាអកុសល ព្រះអង្គបានឃើញផងដែរ នូវមាគ៌ាឈ្មោះតណ្ហា ការប្រកាន់មាំ (ឧបាទាន) ក្នុងសង្ខារនិងមិច្ឆាទិដ្ឋិៗ ជាទីបញ្ចប់នៅពេលផ្កាយព្រឹកបានរះឡើង ព្រះអង្គបានត្រាស់ដឹងដូចជាការយល់សប្តិ ហើយព្រះអង្គបានប្រកាសថា "ឥឡូវនេះ តថាគតបានដល់នូវវិមុត្តិហើយ ការកើតបានធ្វើឲ្យតថាគតនឿយណាយជីវិតដ៏បរិសុទ្ធនេះធ្វើឲ្យតថាគតរួចចាកទុក្ខទាំងពួងៗ អ្វីដែលតថាគតមិនទាន់បានត្រាស់ដឹង គឺបានត្រាស់ដឹងហើយ តថាគតគ្មានទុក្ខកង្វល់ទៀតទេៗ" បន្ទាប់ពីនោះមក ព្រះអង្គបានត្រូវគេដឹងថា ជាព្រះពុទ្ធ ជាអ្នកត្រាស់ដឹង ជាអ្នកឃើញនូវព្រះធម៌ តាមសភាវៈពិតៗ

**ការប្រៀនប្រដៅរបស់ព្រះពុទ្ធ** (ព្រះធម៌)

ធម្មៈ មានន័យថាសច្ចធម៌ ពិតតាមសភាវៈ។ តាំងពីព្រះពុទ្ធទ្រង់បានបដិសេធមិនព្រមទទួលស្គាល់ ទម្រង់នៃទំនាក់ទំនងជាមួយអាទិទេព ហើយគ្មានកន្លែងណាមួយ ដែលអាចបញ្ជាក់ឲ្យឃើញអំពីរឿងនេះ តាំងពីដើមមក ដូចដែលមេដឹកនាំសាសនាដទៃទៀត បានប្រកាសថាខ្លួនជាអាទិទេព ឬជាអ្នកមានការទាក់ទងជាមួយអាទិទេព។ ការប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនាបានបង្ហាញឲ្យឃើញអំពីការត្រាស់ដឹង របស់ព្រះពុទ្ធអំពីលោក។ បរមឱវាទនេះគឺទាក់ទងជាចំបង ជាមួយបញ្ហាមនុស្សលោក។ បើតាមឱវាទរបស់ព្រះពុទ្ធ យើងត្រូវដោះស្រាយបញ្ហារបស់យើងដោយខ្លួនឯង ហើយមានតែសតិរបស់យើងទេ ដែលអាចឈានឡើងដល់កម្រិតខ្ពស់បំផុតនៃបញ្ញា ដែលអាចជួយយើងឲ្យស្គាល់នូវសភាពពិតក្នុងលោក (**យថា ភូត ញាណទស្សន**) ហេតុនេះយើងអាចបង្ហាញថា ព្រះពុទ្ធសាសនាជាសាសនាផ្សារភ្ជាប់មនុស្សជាតិ (មនុស្សមណ្ឌល) មិនមែនជាសាសនាផ្សារភ្ជាប់អាទិទេព (អាទិទេពមណ្ឌល) នោះទេ។ ព្រះពុទ្ធសាសនាមិនដូចសាសនាដទៃៗទៀត ដែលមានតែគម្ពីរមួយនោះទេ (ដូចជាគម្ពីរសាសនា

យេស៊ូ ឈ្មោះគម្ពីរគ្រឹស្តសាសនា គម្ពីរសាសនាឥស្លាម ឈ្មោះគម្ពីរគូរ៉ាន់ជាដើម)។ ប៉ុន្តែអ្វីដែលព្រះសម្មាសម្ពុទ្ធបានប្រៀនប្រដៅអស់រយៈពេល៤៥ព្រះវស្សា មានចារឹកក្នុងគម្ពីរព្រះត្រៃបិដក (កញ្ជើរបី) គឺ**សុត្តន្តបិដក** (ព្រះសូត្រ) **វិនយបិដក** (ព្រះវិន័យ) និង**អភិធម្មបិដក** (ព្រះអភិធម្ម)។ ការចែកជាគម្ពីរគោលធំៗទាំងបីនេះ អាចចែកជាគម្ពីរតូចៗតទៅទៀត។ ជាតួយ៉ាងសុត្តន្តបិដក (ព្រះសូត្រ) មានចែកជា៥គម្ពីរជាសំខាន់ ដោយ ផ្អែកលើមូលដ្ឋានទំហំនៃព្រះធម៌វែងឬខ្លី មានដូចជា**ទីឃនិកាយ** (សូត្រវែងពិស្តារ) **មជ្ឈិមនិកាយ** (សូត្រវែងមធ្យម)។

តាមការចែកជាគម្ពីរគោលបីសំខាន់ សុត្តន្តបិដក ជាគម្ពីរស្តីពីការពន្យល់ព្រះធម៌។ វិន័យបិដក ជាគម្ពីរស្តីពីច្បាប់ក្រឹត្យក្រមសំខាន់ ជាគោលប្រតិបត្តិនៃបព្វជិតនិងគ្រហស្ថ។ អភិធម្មបិដក ឬបរមត្ថវិជ្ជាព្រះពុទ្ធសាសនា ជាគម្ពីរស្តីពីទស្សនវិជ្ជាដែលចែងអធិប្បាយ អំពីចិត្ត ចេតសិក រូប និព្វាន ហើយនិងអត្ថបទស្តីពីធម៌អាថ៌ អត្ថនៃធម៌ដ៏ជ្រាលជ្រៅល្អិតសុខុមដទៃទៀត។ អាថ៌ធម៌នៅក្នុងគម្ពីរនេះ ជាការប្រៀនប្រដៅចុងក្រោយរបស់ព្រះសម្មាសម្ពុទ្ធ ដល់ពួកសាវ័ករបស់ព្រះអង្គ។ ពុទ្ធោវាទចែងជាសំខាន់

តាមរបៀប**សំវាទ** (ការពោលព្រមគ្នា) ការបែកជាពួកក្រុមត្រឹមត្រូវ នាពេលបច្ចុប្បន្ននេះ បានធ្វើឡើងដោយបឋមសង្គាយនាដោយ**ការកសង្ឃ** ចំនួន៥០០អង្គ ក្នុងកាលដែលព្រះសាស្តាបរិនិព្វានកន្លងទៅហើយបាន៣ខែ។ ពុទ្ធោវាទដ៏ធំធេងទាំងនេះរួមមក មាន១១០ក្បាល (ច្រើនជាងគម្ពីរគ្រីស្តសាសនា)។ ហេតុនេះលោកអ្នកឥឡូវនេះអាចយល់ដឹងបានថា ហេតុអ្វីបានជាគេសួរសំនួរដែលមិនទាក់ទងថា "តើគម្ពីរធម៌របស់អ្នកឈ្មោះអ្វី?" បើទុកជាទំហំនៃព្រះធម៌ធំធេងក៏ដោយ យើងអាចបំព្រួញទៅជាសូត្រតែមួយបាន។ នេះគឺជាអត្ថបទសង្ខេបនៃព្រះធម៌សំខាន់ៗ ដែលមាននៅខាងក្រោយនៃជំពូកនេះ។

ក្រៅពីការប្រៀនប្រដៅ ដ៏វិសេសវិសាលជាច្រើនរបស់ព្រះពុទ្ធ ខាងក្រោមនេះមានការពោលជាពិសេសដូចជា អរិយសច្ច៤ សាមញ្ញលក្ខណៈ៣ អកុសលមូល៣ ទស្សនៈរបស់ព្រះពុទ្ធសាសនា ស្តីពីជីវិតក្រោយពេលស្លាប់ (កម្មនិងការកើត) បដិច្ច-សមុប្បាទ និងទិសដៅចុងក្រោយរបស់ព្រះពុទ្ធសាសនា ពោលគឺនិព្វាន។

**ចតុរារិយសច្ចៈ**

ដោយហេតុថា មានសូត្រជាច្រើនបានសរសេរដើម្បីពន្យល់ឱវាទដ៏សំខាន់នេះ ខ្ញុំមិនចង់ចំណាយពេលច្រើនដើម្បីផ្តល់ការពន្យល់ដដែលៗ នៅក្នុងសៀវភៅនេះទេ។ ប៉ុន្តែ ខ្ញុំសូមសរសេរសង្ខេបពីការពិបាកប្រែគំនិតទស្សនវិជ្ជាដ៏ស្មុគស្មាញ ពីភាសាបាលីមកជាភាសាខ្មែរ។ ពួកលោកខាងលិច (បច្ចិមប្រទេស) ផ្តោតការយកចិត្តទុកដាក់ ទៅលើការមើលភាពពិតខាងក្រៅ និងបច្ចេកវិទ្យាលូតលាស់យ៉ាងធំសម្បើមមហិមា។ ពួកលោកខាងកើត (បូព៌ាប្រទេស) ផ្តោតការយកចិត្តទុកដាក់ទៅលើការមើលភាពពិតខាងក្នុង និងការយល់ដឹងដែលលូតលាស់យ៉ាងធំសម្បើមមហិមា។ ភាសាបាលីជា ភាសាយានបានប្រើប្រាស់ដោយព្រះសង្ឃ ដើម្បីបង្ហាញការយល់ដឹងជ្រៅជ្រះរបស់ពួកគេ សំបូរវាក្យស័ព្ទ ដែលស្ទើរតែគ្មាននៅក្នុងភាសាខ្មែរ ឬភាសាអង់គ្លេស។ ការនេះបណ្តាលឲ្យមានការលំបាក នៅពេលដែលគេព្យាយាមបកស្រាយនូវទស្សនៈ ឬបញ្ញត្តិ ពីភាសាមួយទៅភាសាមួយទៀត។ បញ្ហាដូចគ្នាដែរ អាចជាបទពិសោធន៍ដោយគ្មានការងឿងឆ្ងល់ ប្រសិនបើយើងព្យាយាមបកប្រែអត្ថបទវិទ្យាសាស្ត្រ ឬ

បច្ចេកទេសស្មុគស្មាញពីភាសាខ្មែរ ទៅជាភាសាបាលី។ យើងគួរតែមានការពិចារណា ដោយប្រុងប្រយ័ត្នបំផុត ក្នុងការផ្តល់អត្ថន័យនៃជំនឿដ៏ជាក់លាក់នេះ នៅពេលដែលយើងមានបំណងបង្ហាញគំនិតពុទ្ធសាសនាជាភាសាខ្មែរ។

**ចតុរារិយសច្ចៈ ឬអរិយសច្ចៈ៤**

១. ***ទុក្ខសច្ចៈ*** ការកើតមាននៃទុក្ខ

២. ***សមុទយសច្ចៈ*** ហេតុនាំឲ្យកើតទុក្ខ

៣. ***មគ្គសច្ចៈ*** សេចក្តីរំលត់ទុក្ខ

៤. ***និរោធសច្ចៈ*** សេចក្តីប្រតិបត្តិឲ្យដល់ទីរលត់ទុក្ខ

ពាក្យខ្មែរ "សេចក្តីទុក្ខ" ជាធម្មតាមានន័យថា ការឈឺចាប់ ឬទុក្ខព្រួយផ្នែកផ្លូវកាយ និងផ្លូវចិត្តនៅក្នុងជីវិតរបស់មនុស្ស។ ពាក្យនេះមិន បង្ហាញឲ្យឃើញជម្រៅពិតនៃពាក្យបាលីដើមថា "ទុក្ខៈ" នោះទេ។ ព្រះពុទ្ធបានប្រើពាក្យ "ទុក្ខ" ដើម្បីបញ្ចូលគំនិតយល់ដឹងជ្រៅជ្រះទៅក្នុងធម្មជាតិមនុស្សពិត។ នៅពេលដែលយើងប្រែពាក្យគន្លឹះនេះ (ទុក្ខៈ) ជាភាសាខ្មែរថា "សេចក្តីទុក្ខ, សេចក្តីមិនសប្បាយចិត្ត ឬសេចក្តីអាក់អន់ស្រពោន់ចិត្ត ជាធម្មតា

មនុស្សជាច្រើនយល់ច្រឡំថា ព្រះពុទ្ធសាសនាទុទិដ្ឋិនិយម ពីព្រោះព្រះពុទ្ធទ្រង់ដាក់ការប្រៀនប្រដៅរបស់ព្រះអង្គ លើបទពិសោធន៍របស់មនុស្ស ប្រកបដោយការឈឺចាប់ និងការមិនសប្បាយចិត្ត ដូចជា សេចក្តីទុក្ខ ហេតុនាំឲ្យមានសេចក្តីទុក្ខជាដើម ហើយពួកគេគិតថា "ហេតុអ្វីបានជាព្រះពុទ្ធមិនចាប់ផ្តើមបង្រៀន អំពីបទពិសោធន៍របស់មនុស្ស ប្រកបដោយសេចក្តីសប្បាយរីករាយ និងរុងរឿង?" និងម្យ៉ាងទៀតផ្នែកដ៏ភ្លឺស្វាងមួយនៃពិភពលោកៗចម្លើយសាមញ្ញចំពោះសំនួរទាំងនេះគឺ ៖

១. អត្ថន័យពិតនៃពាក្យថា "ទុក្ខៈ" គួរត្រូវបានគេយល់ដឹងដូចព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងពន្យល់ៗ

២. យើងត្រូវយល់ថា នៅក្នុងពុទ្ធោវាទផ្តល់ឲ្យយើងនូវការវិភាគពេញបរិបូណ៌អំពីបញ្ហារបស់មនុស្សៗ នៅពេលដែលព្រះពុទ្ធទ្រង់ពន្យល់អំពីអរិយសច្ចៈ៤ ព្រះអង្គបានពន្យល់ច្បាស់ថា ប្រសិនបើយើងដឹងហេតុពិតនៃសេចក្តីទុក្ខ យើងក៏អាចរកវិធីដើម្បីរំលាស់ខ្លួនចេញពីសេចក្តីទុក្ខនេះបានដែរៗ ជាងនេះទៅទៀតព្រះពុទ្ធបានជានាទីបញ្ចប់នៃសេចក្តីទុក្ខបែបនេះៗ គេអាចធ្វើខុសឆ្គង ប៉ុន្តែនៅពេលគេដឹងថាខ្លួនខុសឆ្គង គេអាចកែតម្រូវ ដោយ

ខ្លួនគេ ដោយយល់ដឹងពីកំហុសរបស់ខ្លួនដោយរកវិធីត្រឹមត្រូវដើម្បីចៀសចេញ។ ហេតុនេះ បើតាមពុទ្ធវាទ មនុស្សម្នាក់មិនមែនជាអ្នកធ្វើអំពើបាប ដែលកែលែងបាននោះទេ។ នៅក្នុងឱកាសជាច្រើន ព្រះពុទ្ធបានបញ្ជាក់ថា មិនត្រឹមតែអ្នកនោះអាចកែប្រែដោយខ្លួនគេទេ ថែមទាំងអាចស្វែងរកសេរីភាពផ្ទាល់ខ្លួន ក្នុងករណីនេះ គេអាចស្វែងរកផ្លូវត្រូវ ដើម្បីចេញពីទំងន់នៃសេចក្ដីទុក្ខរបស់គេបាន។

៣.ចុងបញ្ចប់ គេអាចយល់ច្បាស់ថា ហេតុអ្វីបានជាមនុស្សខ្លះ យល់ថាព្រះពុទ្ធសាសនាមានគំនិតទុទិដ្ឋិនិយម ពោលគឺ ដោយសារតែព្រះពុទ្ធសាសនាគិតច្រើនតែ អំពីសេចក្ដីមិនសប្បាយចិត្តនិងសេចក្ដីទុក្ខ។ យើងដឹងថា វេជ្ជបណ្ឌិតនិងគិលានុប្បដ្ឋាកទាំងឡាយធ្វើការងារដើម្បីសុខភាពមនុស្ស ហើយយើងទាំងអស់គ្នាដឹងថា កម្មសិក្សារបស់ពួកគេគឺគ្រប់ដណ្ដប់ ដោយជម្ងឺផ្សេងៗ ប៉ុន្តែគ្មាននរណាម្នាក់និយាយថា វិជ្ជាជីវៈបែបនេះជាការងារបម្រើឲ្យ “សេវាកម្មជម្ងឺ” ឬ “អាជ្ញាធរជម្ងឺ” ឬ “មណ្ឌលជម្ងឺ” នោះទេ គេ តែងនិយាយថា “សេវាកម្មសុខភាព“ ឬ “អាជ្ញាធរសុខភាព” ឬ “មណ្ឌលសុខភាព”។ ដូចគ្នានេះដែរ ដោយសារតែព្រះពុទ្ធ

សាសនាបានសង្កត់ធ្ងន់ថា យើងគួរតែទទួលស្គាល់ សេចក្តីទុក្ខ និងហេតុនាំឲ្យកើតទុក្ខ ដើម្បីដឹងនូវសេចក្តីរីករាយពេញចិត្ត របស់មនុស្សឲ្យបានប្រសើរឡើងៗ វាជាការយល់ខុសទាំងស្រុង ដែលចាត់ទុកព្រះពុទ្ធសាសនាថា ទុទិដ្ឋិនិយមនោះៗ នៅពេលគេ ទទួលសារភាពថា សេចក្តីទុក្ខមាន សំនួរបន្ទាប់នឹងលេចឡើង ភ្លាមគឺ៖ "តើអ្វីអាចជាហេតុដែលបណ្តាលឲ្យមានសេចក្តីទុក្ខ?" ឬ ក៏ "ហេតុអ្វីបានជាសេចក្តីទុក្ខកើតមាន ហើយសេចក្តីទុក្ខនេះកើត ឡើង តាមរបៀបណា?" តាមព្រះពុទ្ធសាសនា ចំលើយចំពោះ សំនួរនេះគឺកើតមកពី "តណ្ហា"ៗ ពេលយើងដឹងហេតុនាំឲ្យកើត មានសេចក្តីទុក្ខ ជំហានបន្ទាប់គឺត្រូវរំលត់សេចក្តីទុក្ខនោះៗ វិធី បញ្ឈប់សេចក្តីទុក្ខលែងឲ្យកើតមានគឺអភិវឌ្ឍចិត្ត ដោយដើរតាម ផ្លូវកណ្តាល "មជ្ឈិមបដិបទា" ដែលនាំទៅដល់ ការរំលត់ទុក្ខទាំង អស់ ពោលគឺព្រះនិព្វាន[១]ៗ

---

[១] និព្វាន គឺ ការអស់ទៅនូវសេចក្តីប្រាថ្នាទាំងពួង (តណ្ហា) សេចក្តីស្អប់ (ទោសៈ) និងសេចក្តីវង្វេងអវិជ្ជា (មោហៈ)ៗ

## មាគ៌ារំលត់ទុក្ខ

ឈ្មោះវិធីរំលត់ទុក្ខគឺ “ផ្លូវកណ្តាល” (មជ្ឈិមបដិបទា) ពីព្រោះចៀសវាងនូវអន្តធម៌ពីយ៉ាងគឺ ធម៌ដែលប្រកបខ្លួនឲ្យជាប់ជំពាក់ដោយកាម (កាមសុខល្លិកានុយោគ) និងធម៌ដែលប្រកបសេចក្តីដល់ខ្លួន (អត្តកិលមថានុយោគ)។ នៅក្នុងឱកាសមួយចំនួនព្រះសម្មាសម្ពុទ្ធបានប្រើពាក្យមជ្ឈិមបដិទានេះ ដើម្បីពន្យល់ចំណុចទស្សនវិជ្ជាជ្រៅៗ ដូចជាការយល់ដឹងអំពីយថាភូតធម៌ ដោយចៀសវាងទិដ្ឋិពីរផ្សេងទៀតគឺ ឃើញថាជារបស់ខ្លួន (អត្ថិតៈ) និងឃើញថាមិនមាន (ឆត្ថិតៈ)។

មជ្ឈិមបដិបទានេះមានប្រាំបី ដូច្នេះហើយទើបគេហៅថាអដ្ឋង្គិកមគ្គ គឺប្រាជ្ញាយល់ឃើញត្រូវ សម្តីត្រូវ ការងារត្រូវ កិរិយាចិញ្ចឹមជីវិតត្រូវ ព្យាយាមត្រូវ សេចក្តីរឭកត្រូវ និងកិរិយាតម្កល់ចិត្តឲ្យនឹងត្រូវ។ ម្យ៉ាងទៀត អដ្ឋង្គិមគ្គទាំងប្រាំបីនេះ ត្រូវបានគេពន្យល់ក្រោមគោលសិក្ខាបីយ៉ាង។ ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់អំពីព្រះធម៌ ដែលព្រះពុទ្ធទ្រង់បានបង្រៀន ជាការសំខាន់ណាស់ក្នុងការពិចារណាដោយប្រុងប្រយ័ត្ន អំពីវិធីដែលគេពន្យល់ ក្រោមត្រៃសិក្ខាទាំងបីនេះ។

## ត្រៃសិក្ខា

ជាធម្មតា គេហៅត្រៃសិក្ខាថា បញ្ញា សីល និងសមាធិ ប៉ុន្តែម៉្យាងទៀតយើងឃើញត្រៃសិក្ខានេះនៅក្នុងលំដាប់ខុសគ្នា ទៅជា សីល សមាធិ និងបញ្ញា។ ហេតុនេះ គេអាចលើកជាសំនួរថា៖ "ហេតុអ្វីបានជាព្រះពុទ្ធគូរលំដាប់នៅទីនេះ?" គឺមានហេតុផលពិសេសមួយ។ អរិយសច្ចគឺសំខាន់ណាស់ដូចទស្សនវិជ្ជាទាំងអស់របស់ព្រះពុទ្ធ គឺផ្អែកលើការប្រៀនប្រដៅដ៏សំខាន់នេះ។ ដូចយើងដឹងហើយថា ផ្លូវនាំទៅកាន់ទីរំលត់ចុងក្រោយគឺអរិយសច្ចបួន។ ព្រះសម្មាសម្ពុទ្ធពិតជាបានសម្តែងថា ការយល់ដឹងរបស់មនុស្សម្នាក់ស្តីពីលោក បង្ហាញឲ្យឃើញទស្សនៈទាំងមូលរបស់ខ្លួន។ ហេតុនេះទើបព្រះពុទ្ធទ្រង់បានចាប់ផ្តើមពន្យល់មាគ៌ារបស់ព្រះអង្គ ជាមួយបញ្ញា។ ដើម្បីមានភាពងាយស្រួលយល់ យើងអាចបង្ហាញពីរបៀបដែលរៀបជាក្រុមក្រោមត្រៃសិក្ខា។

សម្មាទិដ្ឋិ
សម្មាសង្កប្បៈ } បញ្ញា

សម្មាវាចា
សម្មាកម្មន្តៈ } សីល
សម្មាអាជីវៈ

សម្មាវាយាមៈ
សម្មាសតិ } សមាធិ
សម្មាសមាធិ

**សម្មាទិដ្ឋិ** មានន័យថា ការយល់ដឹងត្រូវរបស់យើងអំពីលោក។ យើងអាចមានប្រភេទខ្លះនៃការយល់ដឹង ឬចំណេះដឹងអំពីលោក ប៉ុន្តែការយល់ដឹងនេះមិនអាចសុទ្ធតែត្រូវនោះទេ។ ហេតុនេះ ព្រះសម្មាសម្ពុទ្ធទ្រង់បានសង្កត់ធ្ងន់ទៅលើសារៈប្រយោជន៍នៃសម្មាទិដ្ឋិ។ តាមធម្មតា សម្មាទិដ្ឋិ មានន័យថាការទទួលបាននូវចំណេះដឹងអំពីអរិយសច្ចបួន។ ប្រសិនបើយើង ពិតជាយល់ដឹងអត្ថន័យនៃសេចក្តីទុក្ខ ហេតុដែលនាំឲ្យកើតទុក្ខ ការរំលត់ទុក្ខ និងវិធីរំលត់ទុក្ខ ទើបយើងអាចប្រកាសថា យើងស្ថិតនៅលើផ្លូវត្រូវ។ ព្រះពុទ្ធទ្រង់បានសម្តែងថា សត្វទាំងឡាយមានទុក្ខផ្សេងៗនៅក្នុងការរស់នៅរបស់ពួកគេ ដោយសារអវិជ្ជា។ **អវិជ្ជា** នៅទីនេះ មានន័យថា ការយល់ខុស និងការបកស្រាយខុសអំពីលោក។ តាមពាក្យថា "**លោកៈ**" មានន័យថា គ្រប់សង្ខារទាំងអស់អាចនឹងប្រែប្រួល (លុជ្ជតិ បលុជ្ជតីតិ លោកោ)។

បានសេចក្ដីថា រាល់សរីរៈមានជីវិតនិងឥតជីវិតទាំងអស់ដែលមាន ហៅថា លោក។ ការទទួលបានការយល់ដឹងជ្រៅជ្រះអំពីយថាភូតធម៌ពិត គេហៅថា សម្មាទិដ្ឋិ។ ដើម្បីសម្រេចបាននូវគោលដៅនេះ ព្រះពុទ្ធសាសនាបង្ហាញសាមញ្ញលក្ខណៈបីយ៉ាង។

**សាមញ្ញលក្ខណៈ**

១) អនិច្ចំ ការប្រែប្រួលមិនទៀង

២) ទុក្ខំ ជាទុក្ខ

៣) អនត្តា មិនមែនជារបស់ខ្លួន។

ទីមួយ **អនិច្ចំ** បង្ហាញសភាវៈពិតដែលគ្មានអ្វីមួយនៅក្នុងលោកនេះ នៅទីងមួយកន្លែង ឬស្ថិតនៅជាអចិន្ត្រៃយ៍នោះទេ។ យើងខ្លួនឯងមិនជាមនុស្សដដែល ទាំងផ្នែកផ្លូវកាយអារម្មណ៍ និងទាំងផ្លូវចិត្តនោះក្ដី ដែលយើងមានអាយុដប់ឆ្នាំ ឬ សូម្បីតែដប់នាទីកន្លងផុតទៅក្ដី។ ដូច្នេះការរស់នៅ ដូចការផ្លាស់ប្ដូរការរំកិលនៃជីវព្រាច់ សម្រាប់យើងមិនអាចរកសុវត្ថិភាពយូរអង្វែងបានទេ។

ក្នុងចំណោកដែលពាក់ព័ន្ធនឹងលក្ខណៈទីពីរ យើងបានឃើញពីរបៀប ដែលទុក្ខកើតមាន ដែលធ្វើឲ្យព្រះសម្មាសម្ពុទ្ធចាកចេញ

ទៅស្វែងរកជំនួយផ្នែកស្មារតី។ ទោះបីសេចក្តីទុក្ខមិនមែនជាការប្រែដ៏ល្អចំពោះពាក្យដើម "ទុក្ខៈ" ក៏ដោយ។ ពាក្យថា "ទុក្ខៈ" បញ្ជាក់នូវធម្មជាតិដែលមិនគួរឲ្យពេញចិត្តទូទៅនៃជីវិត។

លក្ខណៈទីបី **មិនមែនជារបស់ខ្លួន** គឺមានការលំបាកបន្តិច។ អ្នកកាន់ព្រះពុទ្ធសាសនា មានអ្វីមួយដែលស្ថិតនៅជារៀងរហូត ឬមិនផ្លាស់ប្តូរនោះទេនៅក្នុងភាពជាមនុស្ស ពោលគឺ គ្មានអត្តាតួខ្លួន ឬជារបស់ខ្លួនដែល អត្ថន័យមិនប្រែប្រួលនៃពាក្យថា "អញ" អាចបង្ខំខ្លួនឯង។ ទស្សនៈទាំងមូលនៃពាក្យថា "អញ" តាមពិតគឺជាទស្សនៈមួយ ដែលយល់ខុសជាសារវន្តមួយដែលព្យាយាមបង្កើតខ្លួនឯងឡើង នៅក្នុងការប្រមូលផ្តុំ**មហាភូតរូប** បណ្តោះអាសន្ន និងអស្ថេរភាព។ ចូរធ្វើសទិសភាពរទេះមួយ ពោលគឺរទេះមួយអាចធ្វើការរុះរើទៅជាធាតុផ្សំដើមរបស់ខ្លួន ដូចជា ភ្លៅកង់ នឹម និងផ្នែកផ្សេងៗទៀតជាដើម ដូច្នេះរទេះគ្មានទៀតទេ អ្វីៗទាំងអស់ ដែលយើងមានគឺគំនរមួយនៃធាតុផ្សំ។ ដូចគ្នានេះដែរ "ខ្លួន" ផ្សំឡើងដោយមហាភូតរូបផ្សេងៗ ឬការប្រមូលផ្តុំ (ខន្ធ) ទម្រង់ (រាងកាយ) អារម្មណ៍ សញ្ញា (ការសម្គាល់) ចេតនា និងចិត្ត ហើយទោះបីទាំងអស់នេះ អាចធ្វើការហើយប្រមូលផ្តុំចូលគ្នា

តិច ឬច្រើនមួយរយៈក៏ដោយ ក៏នៅពេលសេចក្ដីស្លាប់ចូលមកដល់ ក៏រលត់បាត់ទៅវិញជាចំណែកផ្សេងៗគ្នា។

ដោយយល់ដឹងអំពីធម្មជាតិសកល ដែលបានរៀបរាប់ខាងលើនេះ ចាត់ទុកថា សម្មាទិដ្ឋិនៅក្នុងព្រះពុទ្ធសាសនា។ សម្មាទិដ្ឋិសំខាន់ ដូចជា ចំណុចចាប់ផ្ដើមមួយ ពីព្រោះមាគ៌ាជីវិតរបស់មនុស្សម្នាក់ៗទាំងមូល ត្រូវបានបង្កើតឡើង យោងទៅតាមការយល់ដឹងរបស់ខ្លួនស្ដីពីសកលលោក។ ហេតុនេះ សម្មាសង្កប្បៈតាមធម្មតា ហូរចេញពីសម្មាទិដ្ឋិ។ ព្រះពុទ្ធទ្រង់បានបដិសេធទស្សនៈស្ដីពីអាត្មន ឬបញ្ញត្តិស្ដីពី “អញ” ដោយសារមានហេតុផលពិសេស។ ទីមួយ គ្មានវត្ថុណា ដែលមិនប្រែប្រួលនៅក្នុងធម្មជាតិនោះទេ។ ទីពីរ **មិច្ឆាទិដ្ឋិ**នេះ អាចបង្កើតឲ្យមានអារម្មណ៍ ឬអត្តចរិតអវិជ្ជមាន ចំពោះអ្នកដទៃ (សង្គមដទៃ)។ ទីបី មិច្ឆាទិដ្ឋិនេះអាចបណ្ដាលឲ្យមានការខូចខាតជាច្រើនដល់សង្គម និងការអភិវឌ្ឍប្រាជ្ញាស្មារតីរបស់ខ្លួន។ ជាឧទាហរណ៍ ទស្សនៈថា “អញ” អាចត្រួតត្រាចិត្តរបស់ខ្លួនជាមួយនឹងអាកប្បកិរិយា ដែលឲ្យទុក្ខទោស ដូចជា **ឆន្ទាគតិ** ការប្រព្រឹត្តអំពើមិនល្អ **វិហឹង្សាព្យាបាទ** ជាដើម ពេលដែលយល់អត្តន័យពិតនៃភាពមិនមែនជា

របស់ខ្លួន (អនត្តា) តាមធម្មតា **កាមមច្ឆរិយៈ** រលាយបាត់បន្តិចម្តងៗជាលំដាប់ ពីព្រោះគេរកមិនឃើញមូលដ្ឋានដើម្បីបណ្តុះឲ្យកើតមានឡើង ហើយគ្មានអ្វីដើម្បីយល់ថាជា "របស់ខ្លួន" ដោយសារគ្មានពាក្យថា "អញ"។

**សម្មាវាចា សម្មាកម្មន្តៈ** និង **សម្មាអាជីវៈ** ទាក់ទងទៅនឹងការវៀរចាកផ្នែកសីល គឺមិននិយាយកុហក មិនលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃ មិនប្រព្រឹត្តអំពើហឹង្សា មិនរកស៊ីចិញ្ចឹមជីវិតតាមវិធីផ្តល់ទុក្ខទោសឲ្យអ្នកដទៃ និងការផ្សារផ្សេងៗទៀតដែលត្រូវវៀរចាកដូចគ្នានេះដែរ។ ការមិនប្រព្រឹត្តអំពើអាក្រក់ ហើយកាន់យកនូវការរក្សាសីលនេះ មិនត្រឹមតែជួយឲ្យយើងមានការចុះសម្រុងគ្នានៃសង្គមទូទៅទេ ថែមទាំងជួយឲ្យយើងគ្រប់គ្រង និងបន្ថយការប្រកាន់មាំថា "អញ" ទៀតផង។

បន្ទាប់មក **សម្មាវាយាមៈ** ក៏សំខាន់ណាស់ដែរ ពីព្រោះវាផ្តល់ឲ្យមនុស្សនូវញាណបន្ថែមទៀត ដើម្បីកែតម្រូវខ្លួនគេ ប្រសិនបើគេធ្វើខុស។ ហើយនឹងមានការកែលំអ និងការអភិវឌ្ឍកាន់តែប្រសើរឡើងថែមទៀត នៃជីវិតរបស់គេ ប្រសិនណាបើគេធ្វើត្រូវ។ ជំហានពីរចុងក្រោយរបស់អដ្ឋង្គិកមគ្គ គឺ **សម្មាសតិ** និង

**សម្មាសមាធិ** ដែលពាក់ព័ន្ធទៅនឹងការភាវនា (សមាធិ) ឬការអភិវឌ្ឍប្រាជ្ញាញាណរបស់យើង។ គោលបំណងសំខាន់នៃការភាវនារបស់ព្រះពុទ្ធសាសនា គឺគ្រប់គ្រងចិត្ត ដើម្បីធ្វើឲ្យអស់ទៅនៃអកុសលមូលគឺលោភៈ ទោសៈ និង មោហៈ និយាយរួម ដើម្បីសម្រេចបានកម្រិតខ្ពស់បំផុតនៃសេចក្ដីស្ងប់ និងការធ្វើចិត្តឲ្យបរិសុទ្ធ ពោលគឺនិព្វាននេះឯង។

មាគ៌ារបស់ព្រះពុទ្ធ គឺអាចធ្វើបាន និងអនុវត្តតាមបានគ្រប់ពេលទាំងអស់ និងមិនរើសអើងភេទ ពណ៌សម្បុរ ត្រកូលវណ្ណៈជាដើម។ បើតាមព្រះសម្មាសម្ពុទ្ធ សច្ចៈទាំងអស់នេះ មិនមែនជាការបង្កើតឡើងរបស់ពួកអ្នកកាន់ព្រះពុទ្ធសាសនានោះទេ គឺជាការរកឃើញឡើងវិញនូវមាគ៌ា ដែលគេបានបោះបង់ចោល និងបំភ្លេចចោលជាយូរណាស់មកហើយ។

## ព្រះសង្ឃ

ព្រះសង្ឃ (សមាជិកនៃគណសង្ឃ) ជាផ្នែកសំខាន់មួយទៀតរបស់ព្រះពុទ្ធសាសនា។ ព្រះពុទ្ធ (អ្នកបង្កើតព្រះពុទ្ធសាសនា) ព្រះធម៌ (ពាក្យប្រៀនប្រដៅ) និងព្រះសង្ឃ (គណសង្ឃ) រួមគ្នា

បង្កើតបានជាត្រៃរតន៍ៗ ត្រៃរតន៍នេះត្រូវបានគេគោរពស្មើគ្នា នៅក្នុងបណ្តាប្រទេសកាន់ព្រះពុទ្ធសាសនាៗ ព្រះសង្ឃ ជាអ្នកបង្ហាត់បង្រៀនព្រះពុទ្ធវចនៈទៅពិភពលោក និងបានថែរក្សាព្រះពុទ្ធសាសនាអស់រយៈពេលជាច្រើនសតវត្សមកហើយ ទោះបីស្ថិតនៅក្រោមស្ថានភាពគ្រោះថ្នាក់ក៏ដោយ ពិសេសនៅពេលការវិវត្តផ្នែកនយោបាយមិនអំណោយផលដល់ព្រះពុទ្ធសាសនា ដូចជាស្ថិតនៅក្រោមការត្រួតត្រារបស់បរទេសជាដើមៗ

## និកាយសំខាន់ៗពីររបស់គណសង្ឃ

មាននិកាយសំខាន់ពីរ នៅក្នុងព្រះពុទ្ធសាសនា គឺ **ទក្ខិណ-និកាយ** តាមធម្មតាគេស្គាល់ថា **និកាយថេរវាទ** និង**ឧត្តរនិកាយ** ឬ **និកាយមហាយាន**ៗ និកាយដើមឈ្មោះថា ទក្ខិណនិកាយ ពីព្រោះនិកាយនេះ គេប្រកាន់ជាសំខាន់នៅបណ្តាប្រទេសអាស៊ីភាគខាងត្បូង ដូចជា ប្រទេសស៊ីរីលង្កា ឥណ្ឌា កម្ពុជា ថៃ និង ប្រទេសមីយ៉ាន់ម៉ា (ភូមា)ៗ ឈ្មោះទីពីរនៃនិកាយនេះ "ថេរវាទ" មានន័យថា "និកាយរបស់ព្រះថេរៈ"ៗ និកាយបន្ទាប់ ឈ្មោះថា ឧត្តរនិកាយ ពីព្រោះនិកាយនេះផ្សព្វផ្សាយទៅ បណ្តាប្រទេសអាស៊ីភាគ ខាងជើង ដូចជា ប្រទេសចិន ទីបេ កូរ៉េ វៀតណាម និងជប៉ុនៗ

## ភាពខុសគ្នាសំខាន់ៗខាងនិកាយទាំងពីរ

អ្នកកាន់និកាយមហាយាន ជឿថា ដោយឆ្លងកាត់សមុទ្រនៃ ***វដ្តសង្សារ*** គឺការវិលកើត វិលស្លាប់នៅក្នុងភព មនុស្សម្នាក់អាចក្លាយជាព្រះពុទ្ធ ដូច្នេះហើយទើបមានឈ្មោះថា “យានធំ” (មហាយាន)។ អ្នកកាន់និកាយថេរវាទ ជឿថាមានវិធីបីយ៉ាងដើម្បីបញ្ចប់ការកើត ពោលគឺ ការត្រាស់ដឹងជាព្រះពុទ្ធ **ព្រះបច្ចេកពុទ្ធ** (ព្រះអង្គអាចសម្រេចពោធិញ្ញាណ ដោយគ្មានការជួយពីអ្នកដទៃ ប៉ុន្តែព្រះអង្គមិនប្រៀនប្រដៅអ្នកដទៃឲ្យរំលត់ទុក្ខទេ) និង **ព្រះអរហន្ត** (អរិយបុគ្គលទាំងឡាយដែលបានកាត់ផ្តាច់ហេតុនៃការកើត និងធ្វើនូវទីបំផុតនៃទុក្ខបាន ពោលគឺ ព្រះនិព្វានដោយ បដិបត្តិតាមពុទ្ធោវាទ)។ ទោះបីមានភាពខុសប្លែកគ្នាក៏ដោយ ក៏និកាយទាំងពីរបដិបត្តិរួមគ្នានូវភាពដូចគ្នាផងដែរ។

## ភាពដូចគ្នា

និកាយទាំងពីរទទួលយកព្រះពុទ្ធ ថាជាអ្នកបង្កើតព្រះពុទ្ធសាសនា ហើយមិនកាន់ជំនឿទៅលើអាទិទេពនោះទេ។

គ្មាននិកាយណាមួយ ជឿទៅលើអាត្មន័នោះឡើយ។

ចំណុចចុងក្រោយ មានការយល់ព្រមរវាងនិកាយទាំងពីរ អំពីពុទ្ធវាទគោលរបស់ព្រះសម្មាសម្ពុទ្ធ។

និកាយទាំងពីរមានគណសង្ឃ ប៉ុន្តែស្បៀកដណ្តប់ស្បង់ចីវរខុសគ្នាបន្តិច។ ទាំងភេទប្រុសនិងភេទស្រីអាចចូលជាគណសង្ឃបាន។ សមាជិកភេទប្រុសនៃគណសង្ឃ ធម្មតាហៅថាភិក្ខុ និងសមាជិកភេទស្រី ហៅថាភិក្ខុនី។ ជាអកុសល ដោយហេតុផលខ្លះ គ្មានស្ត្រីបួសជាភិក្ខុនីទេសព្វថ្ងៃនេះ នៅក្នុងប្រពៃណីព្រះពុទ្ធសាសនានិកាយថេរវាទ។

នៅក្នុងបណ្តាប្រទេស កាន់ព្រះពុទ្ធសាសនានិកាយថេរវាទ ព្រះសង្ឃទាំងឡាយ គេងាយស្រួលចំណាំណាស់ ពីព្រោះព្រះសង្ឃស្បៀកដណ្តប់ចីវរពណ៌លឿង កោរសក់ និងនិមន្តដោយព្រះបាទទទេ។ ពួកគេអាចចូលទៅក្នុងវត្តអារាមនៅកន្លែងមួយជាលើកដំបូង សម្រាប់អំឡុងពេលសាកល្បង ហើយប្រសិនបើព្រះចៅអធិការសម្រេចចិត្តថា ជីវិតអ្នកបួសសមគួរដល់ពួកគេៗ អាចបេ្តជ្ញាខ្លួន ដោយទទួលឧបសម្បទាជាភិក្ខុភាពថែមទៀត។ ពួកគេត្រូវបានផ្តល់ឈ្មោះថ្មី និងស្បង់ចីវរ ហើយនឹងត្រូវរស់នៅដោយ

បដិបត្តិតាម សិក្ខាបទ២២៧។ ព្រះសង្ឃអាចសម្រេចចិត្តលាចាកសិក្ខាបទ (សឹក) នៅពេលណាក៏បាន។

ភិក្ខុចិញ្ចឹមជីវិតសាមញ្ញតឹងរឹងដោយការធ្វើភាវនា សិក្សារៀនសូត្រ និងធ្វើការងារដោយសឹងតិចម៉ោង និងឆាន់ចង្ហាន់មួយពេល (ឬក៏ពីរពេល) ក្នុងមួយថ្ងៃ។ លោកជាអ្នកមានតួនាទីសំខាន់ក្នុងការជួយបង្ហាត់បង្រៀន និងជួយសង្គ្រោះឧបាសកឧបាសិកា និងរៀបចំពិធីបុណ្យផ្សេងៗផ្នែកសាសនា។

មិនដូចអ្នកកាន់និកាយថេរវាទ អ្នកកាន់និកាយមហាយានមានបំណងទទួលយកកម្លាំងអំណាចក្រៅខ្លួន អ៊ីចឹងហើយទើបគេហៅថា "ព្រះពុទ្ធសាសនាពេញនិយម"។ ហេតុនេះពួកគេប្រែប្រួលយ៉ាងច្រើនខុសគ្នា ផ្នែកទំនៀមទម្លាប់ ការស្លៀកពាក់ ជាដើមជាងផ្នែកផ្សេងៗទៀតរបស់និកាយថេរវាទ។ ពណ៌ស្បង់ចីវររបស់ពួកគេ គ្របដណ្តប់ដោយពណ៌ទឹកក្រូចរហូតដល់ពណ៌ខ្មៅ ហើយពួកគេចូលចិត្តស្លៀកដណ្តប់ពណ៌ផ្សេងៗ ជាច្រើនទៀត។ ជាឧទាហរណ៍ ព្រះសង្ឃនៅជប៉ុនស្លៀកដណ្តប់ចីវរពណ៌ខ្មៅ ចំណែកឯព្រះសង្ឃឡាម៉ាទីបេ ស្លៀកដណ្តប់ចីវរពណ៌ក្រហមចាស់។

ព្រះសង្ឃមកពីនិកាយទាំងពីរ គោរសក់ និងភាគច្រើននៃព្រះសង្ឃព្រះពុទ្ធសាសនានៅលីវ។ មានតែបព្វជិតជប៉ុនខ្លះ និងឡាម៉ាទីបេតិចតួច ត្រូវបានគេអនុញ្ញាតិឲ្យរៀបការ។

អ្នកកាន់និកាយថេរវាទ ថែរក្សាគម្ពីរដីការរបស់ពួកគេ ទុកជាភាសាបាលី (មគធៈភាសា) និងអ្នកកាន់និកាយមហាយាន ថែរក្សាក្បួនខ្នាតរបស់ពួកគេជាភាសាសំស្ក្រឹត។

ដោយនិយាយជាទូទៅ មានទំនោរប្រពៃណីដោយឡែកពីរយ៉ាង នៅក្នុងបណ្ដាសហគមន៍វត្តអារាម នៃព្រះពុទ្ធសាសនាថេរវាទ។ ទីមួយ មានគណសង្ឃរស់នៅក្នុងព្រៃ (អរញ្ញវាសី) ដែលជាកន្លែង ព្រះសង្ឃទាំងឡាយចូលចិត្តរស់នៅឆ្ងាយពីសង្គមជាង ហើយសម្រាកនៅក្នុងព្រៃដើម្បីធ្វើវិបស្សនាភាវនា។ ទីពីរមានវត្តអារាមនៅតាមស្រុកខេត្តក្រុង ជាកន្លែងដែលសកម្មភាពប្រចាំថ្ងៃពាក់ព័ន្ធ ទៅនឹងការសិក្សាទស្សនវិជ្ជាព្រះពុទ្ធសាសនាជាភាសាបាលី និងជាប់ពាក់ព័ន្ធផងដែរ ទៅនឹងការជួយសង្គ្រោះសាធារណជន ដោយវិធីផ្សេងៗ។ ជាតួយ៉ាង តាមរយៈប្រវត្តិ-សាស្ត្រនៃប្រទេសសិរីលង្កា វត្តអារាមទាំងឡាយមិនបានត្រូវគេចាត់ទុកថាជាកន្លែង គ្រាន់តែសម្រាប់គោរពបូជាប៉ុណ្ណោះទេ ថែម

ទាំងជាស្ថាប័នវប្បធម៌ទ្រទ្រង់ ទស្សនវិស័យផ្សេងៗនៃជីវិតសាធារណៈ។ វត្តអារាមទាំងឡាយ នៅក្នុងប្រទេសសិរីលង្កាមានសកម្មភាពមមាញឹកនឹងសេវាសង្គម និងជាមជ្ឈមណ្ឌលដែលប្រជាជនចូលចិត្ត។

ទោះបីជា សកម្មភាពទាំងពួង ប្រចាំថ្ងៃរបស់បព្វជិតនៅក្នុងទីក្រុង និងក្នុងព្រៃ មានភាពខុសគ្នាក៏ដោយ ក៏បព្វជិតទាំងនោះរស់នៅចិញ្ចឹមជីវិត ផ្អែកលើ**នេក្ខម្ម**។ ពាក្យដើមជាភាសាបាលីថា "**អភិនិក្ខម**" អាចសំដៅយក "**ការលះបង់កាមលោកីយ**"។ មិនមានន័យថា"ការលះបង់សង្គម"នោះទេ។ ជាគោលបំណងរបស់យើងដើម្បីរស់នៅក្នុងលោក ប៉ុន្តែមិនមែនរបស់លោកទេ។ ក្នុងនាមជាព្រះសង្ឃ យើងគប្បីបដិបត្តិតាមមាគ៌ានេះបន្តិចម្តងៗ ដូចនេះតាមគំរូរបស់យើងនិងការណែនាំរបស់យើង យើងអាចលើកទឹកចិត្តអ្នកដទៃឲ្យដើរតាមផ្លូវកណ្តាល (មជ្ឈិមបដិបទា)។

បើតាមបទពិសោធន៍ផ្ទាល់ ជាបព្វជិតព្រះពុទ្ធសាសនាមួយរូប អស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំដឹងដោយផ្ទាល់ខ្លួនថា បព្វជិតភាគច្រើននៃគណសង្ឃលះបង់ ដោយស្មោះត្រង់នូវពេលវេលាដ៏ច្រើនរបស់ពួកគេ ដើម្បីជួយសាធារណជនដោយមធ្យោបាយ

ផ្សេងៗ។ ជាឧទាហរណ៍ វត្តអារាមទាំងឡាយនៅក្នុងប្រទេសសិរីលង្កា មិនត្រឹមបានចាត់ទុកជា គ្រាន់តែជា កន្លែងសម្រាប់គោរពបូជាប៉ុណ្ណោះទេ ថែមទាំងជាស្ថាប័នវប្បធម៌គ្របដណ្តប់ទស្សនវិស័យជីវិតសាធារណៈ តាមរយៈប្រវត្តិសាស្ត្រនៃប្រទេសសិរីលង្កា។ បច្ចុប្បន្ន វត្តអារាមនៅក្នុងប្រទេសនេះ ជាប់រវល់យ៉ាងខ្លាំងជាមួយសេវាសង្គម ហើយជាមជ្ឈមណ្ឌលដែលប្រជាជនចូលចិត្ត និងធ្វើតាម យ៉ាងទូលំទូលាយគ្រប់អត្តន័យទាំងអស់នៃពាក្យ។

# ការផ្សព្វផ្សាយនៃព្រះពុទ្ធសាសនា

នៅពេលដែលព្រះពុទ្ធសាសនា លេចឡើងលើចាក់នៃទស្សនវិជ្ជាឥណ្ឌា នាសតវត្សទី៦ មុនគ.ស មានកិច្ចខិតខំប្រឹងប្រែងដ៏ធំសម្បើម និងការចូលចិត្តស្រាវជ្រាវរាវរកការពិតនៃជីវិត និងពិភពលោក។ ជាលទ្ធផល បន្ទាប់មកមានទម្រង់ជាច្រើននៃបណ្ដាចលនាសាសនា និងទស្សនវិជ្ជា។

មនុស្សអាចបដិបត្តិសាសនាតាមកម្រិតរៀងៗខ្លួន ឬតាមក្រុម ដែលបានរៀបចំ។ តួយ៉ាង ដូចពួក**អាជីវក** និង **បរិព្វាជក** ប្រព្រឹត្ត**តបៈ**ដាច់ដោយឡែក ចំណែកឯ**មហាវីរៈ** និងគ្រូល្បីដទៃទៀត (គ្រូទាំង៦) បានរៀបចំថែមទៀតនូវទម្រង់នៃសាសនាដោយមានសាវកជាច្រើនគោរព និងពេញចិត្តយ៉ាងខ្លាំងពីសំណាក់បណ្ឌិតជាច្រើន (សង្ឃីគណោ គណាចរិយោ ពហុជន បុជិតោ សាធុសម្មតោ)។ ព្រះសមណៈគោតមក៏បានអនុវត្ត តាមការបង្រៀនទាំងនោះ អស់រយៈពេលប្រាំមួយព្រះវស្សា ហើយចុងក្រោយបានលះបង់ចោល ដោយដឹងថាការបង្រៀនទាំងនោះមិនមែនជា ផ្លូវនាំទៅរកបញ្ញា (ការត្រាស់ដឹង) នោះទេ។ ដោយដើរតាមមាគ៌ាផ្ទាល់របស់ព្រះអង្គ "ផ្លូវកណ្ដាល" ទីបំផុតព្រះអង្គបាន

រកឃើញនូវអ្វីដែល ព្រះអង្គបាននឹងកំពុងស្វែងរកដោយ **មហា-បធាន** អស់ជាច្រើនជាតិ ក្នុងអតីតនោះ។

សាសនាថ្មីនេះ កំពុងបានទាក់ទាញខ្លាំង និងទទួលបានការយល់ដឹង សុក្រឹតនៅក្នុងជីវិតពិតនោះ។ ហេតុនេះ ប្រជាជនគ្រប់ស្រទាប់វណ្ណៈទាំងអស់ ទាំងប្រុសទាំងស្រី ចាប់ផ្តើមប្រតិបត្តិតាមព្រះពុទ្ធ ហើយក្នុងពេលដ៏ឆាប់ ព្រះពុទ្ធសាសនាបានក្លាយជាមានប្រជាប្រិយភាព នៅក្នុងចំណោមប្រជាជន។ នៅក្នុងសម័យពុទ្ធ-កាល ព្រះពុទ្ធសាសនាបានក្លាយជាសាសនា នាំមុខគេនៅក្នុងអាណាចក្រសំខាន់ៗនៃប្រទេសឥណ្ឌា (**មគធៈ កោសល អវន្តិ** និង **វត្ស**”) អាណាចក្រទាំងនេះ គឺជារដ្ឋដែលមានអំណាចបំផុតក្រៅពីអាណាចក្រដប់ប្រាំមួយ នៅក្នុងប្រទេសឥណ្ឌាសម័យបុរាណ។

ទោះបីយ៉ាងណាក៏ដោយ នៅតែមានភស្តុតាងមិនទាន់គ្រប់គ្រាន់ ដើម្បីជឿថា ព្រះពុទ្ធសាសនារីករាលដាលនៅក្នុងទឹកដីកំណើតរបស់ខ្លួន នៅសម័យពុទ្ធកាល។ បើតាមប្រវត្តិសាស្ត្រព្រះពុទ្ធសាសនាបាននាំទៅផ្សព្វផ្សាយដំបូង នៅបណ្តាប្រទេសជិតខាង ដូចជា សិរីលង្កា ថៃ ជាដើម នៅក្នុង រជ្ជកាលព្រះបាទ

អសោក (សតវត្សទី៣មុនគ.ស) និងទៅកាន់**បច្ចន្តប្បទេស**នានា នៅក្នុងឥណ្ឌាទៀតផង។

តាំងពីពេលនោះមក ព្រះពុទ្ធសាសនាចាប់ផ្តើមផ្សព្វផ្សាយទៅកាន់បណ្តាប្រទេសដទៃទៀតជាច្រើន ដូចជា ឥណ្ឌូចិន និងបណ្តាប្រទេសអាស៊ីអគ្នេយ៍ផ្សេងទៀត។ ព្រះពុទ្ធសាសនាក៏បានផ្សព្វផ្សាយទៅកាន់បណ្តាប្រទេសជួរភ្នំហេមពាន្ត ដូចជា ប្រទេសស៊ីកង់ ប៊ូតង់ និងប្រទេសនេប៉ាល់ ប្រទេសទីបេ និងភាគខាងកើតទៅកាន់ប្រទេសចិន កូរ៉េ និងជប៉ុន។ នេះគឺជាការរីកចម្រើនជោគជ័យក្នុងនាមព្រះពុទ្ធសាសនា។ ប៉ុន្តែត្រូវរលាយទៅវិញនៅក្នុងប្រទេសឥណ្ឌា បន្ទាប់ពីការលុកលុយរបស់ពួកមូស្លីម (ឥស្លាម) នៅសតវត្សទី១១ នៃគ.ស។ នៅក្នុងសម័យទំនើបថ្មី ការរីករាលដាលនៃលទ្ធិកុម្មុយនីស ជាក់ស្តែងបានបំផ្លាញចោលព្រះពុទ្ធសាសនាផងដែរ ពីប្រទេសដទៃផ្សេងៗទៀត ដែលព្រះពុទ្ធសាសនាពីមុនត្រូវបានបង្កើតឡើង យ៉ាងមាំ (ជាតួយ៉ាង ប្រទេសចិន)។ យ៉ាងណាក៏ដោយ សព្វថ្ងៃនេះ ព្រះពុទ្ធសាសនាកំពុងទាក់ទាញការកើនឡើងមួយនៅទ្វីបអឺរ៉ុប និងសហរដ្ឋអាមេរិច។ នៅទ្វីបអាស៊ី ព្រះពុទ្ធសាសនានៅតែមានជីវិតរស់រវើក ដូចជា នៅក្នុង

ប្រទេសសិរីលង្កា កម្ពុជា ភូមា ថៃ កូរ៉េ និងប្រទេសជប៉ុន។

រឿងដែលសំខាន់ជាងគេ នៅក្នុងប្រវត្តិសាស្រ្តទាំងអស់នៃការលូតលាស់របស់ព្រះពុទ្ធសាសនា គឺគ្មានការបង្ហូរឈាមណាមួយកើតឡើង និងទម្រង់នៃការធ្វើទុក្ខបុកម្នេញ ត្រូវបានគេអនុវត្តដើម្បីប្រយោជន៍នៃសាសនានេះឡើយ។

# តើបុគ្គលអាចក្លាយជាពុទ្ធសាសនិកដោយរបៀបណា?

តើលោកជាអ្នកកាន់ព្រះពុទ្ធសាសនាដោយជាតិឬ? តើលោកជាអ្នកកាន់ព្រះពុទ្ធសាសនាតាមប្រពៃណីឬ? សំនួរទាំងនេះត្រូវបានគេសួរញើកញាប់ណាស់ ពីសំណាក់ពួកលោកខាងលិច និងពួកអ្នកមកពីជំនឿសាសនាផ្សេងៗ នៅពេលដែលពួកគេជួបខ្ញុំ ជាពិសេសនៅពេលដែលយើង ពិភាក្សាគ្នាអំពីសាសនា។ សម្រាប់ខ្ញុំសំនួរទាំងនេះជាសំនួរមិនជាប់ទាក់ទង ពីព្រោះព្រះពុទ្ធសាសនាបានបង្រៀនយើងពីវិធីមើលអ្វីៗគ្រប់យ៉ាងតាមសភាវៈពិត ជាជាងព្យាយាមដើម្បីបកស្រាយច្បាប់ធម្មជាតិ ទៅតាមអារម្មណ៍របស់យើង និងការស្រមើលស្រមៃ ដែលរាំងយើងមិនឲ្យមើលឃើញធម្មជាតិពិតនៃសកលលោក។ តាមការយល់ឃើញរបស់ខ្ញុំ ព្រះពុទ្ធសាសនាជាមុខវិជ្ជាមួយផ្សេងទៀត ដូចវិទ្យាសាស្ត្រដែរ ដែលប្រាប់យើងឲ្យដឹងពីអាថ៌កំបាំងនៃជីវិតនិងធម្មជាតិ។ ចាំបាច់ណាស់ត្រូវសិក្សាសាសនានេះ ដោយប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់។ កាលណាបើយើងយល់ច្បាស់ពី គោលបំណង និងទិសដៅសំខាន់ៗនៃពុទ្ធោវាទ ពេលនោះយើងស្ទើរតែក្លាយជាពុទ្ធសាសនិក

ហើយ។ ប៉ុន្តែគ្រាន់តែយល់ដឹងមិនទាន់គ្រប់គ្រាន់ ពោលគឺ ចាំបាច់ត្រូវប្រតិបត្តិតាមក្រិត្យក្រមសីលធម៌ (ក្នុងព្រះពុទ្ធសាសនា) ថែមទៀត ទើបយើងអាចបង្ហាញខ្លួនយើងថា ជាពុទ្ធសាសនិក (អ្នកកាន់ព្រះពុទ្ធសាសនា) បាន។

យើងដឹងហើយថា ជាការអត់ន័យដែលសួរនរណាម្នាក់ថា “តើលោកជាវិស្វករដោយជាតិឬ, តាមប្រពៃណីឬ?” ដូចគ្នានេះដែរ សម្រាប់ខ្ញុំដែលសួរថា តើនរណាម្នាក់ គឺជាពុទ្ធសាសនិកដោយជាតិ ឬតាមប្រពៃណី ឬយ៉ាងណា គឺជាសំនួរដែលមិនទាក់ទងស្មើគ្នាដែរ។ ប៉ុន្តែការអនុវត្តជាក់ស្តែង មនុស្សជាច្រើននិងបានទទួលយកពាក្យដូចជា “ពុទ្ធសាសនិកពីកំណើត” និង “បណ្តាប្រទេសកាន់ព្រះពុទ្ធសាសនាជាប្រពៃណី” ថាជាពាក្យសាមញ្ញធម្មតា និងមានន័យពេញលេញ។ បន្ទាប់មកសំនួរគួរសួរថា “ហេតុអ្វីបានជាច្រើនគ្នាគិតដូចនេះ?”

ជាប្រពៃណី ព្រះពុទ្ធសាសនា ត្រូវរួមបញ្ចូលក្រោមតារាងនៃបណ្តាសាសនានានា ហើយតាមប្រពៃណីនិយម គេដាក់បណ្តាប្រទេសនានាជាក្រុម ដូចជា គ្រីស្តសាសនា សាសនាឥស្លាម សាសនាហិណ្ឌូ ព្រះពុទ្ធសាសនា ជាដើម នៅពេលដែលគេគិត

អំពីសាសនា។ បន្ទាប់មកទៀត សំនួរមួយទៀតលើកឡើងថា "តើមាគ៌ាព្រះពុទ្ធអាចចាត់ទុកថា ជាសាសនាមួយបាន ដែរឬទេ?" ចម្លើយរបស់ខ្ញុំគឺអាចនិងមិនអាច។ "មិនអាច" ពីព្រោះព្រះពុទ្ធសាសនាគ្មានតួអង្គដូចសាសនាដទៃទៀតទេ ដូចជាអាទិទេពបង្កើតលោក បញ្ញត្តិអំពើបាប ការបួងសួងអង្វរករ ។ល។ "អាច" ពីព្រោះព្រះពុទ្ធសាសនា ដែលបានរៀបចំឡើង ដូចជា កន្លែងសម្រាប់គោរពថ្វាយបង្គំ បូជា និងធ្វើគារវៈ ជាដើម។

គ្មានពិធីប្រហាក់ប្រហែល ទៅនឹងពិធីលាងបាបនៅពេលដែលអ្នកណាម្នាក់ក្លាយជាពុទ្ធសាសនិកឡើយ ពោលគឺមានតែវិធីមួយគត់ ដើម្បីកាន់ព្រះពុទ្ធសាសនា គឺយល់នូវអ្វីដែលព្រះសម្មាសម្ពុទ្ធបានត្រាស់សម្តែង។ សេចក្តីសំអាងនេះ និងកាន់តែជាក់ច្បាស់ នៅពេលដែលយើងមើលសំនួនសេចក្តីដែលមនុស្សជាច្រើនប្រើ បន្ទាប់ពី **សាកច្ឆា សំវាទ** (ការសន្ទនា) **ធម្មទេសនា** ហើយសូម្បីតែការជជែកវែកញែកជាមួយព្រះពុទ្ធ។ ព្រះសូត្រទាំងឡាយតែងតែបញ្ចប់ដោយសំនួនសេចក្តី ដែលបង្ហាញឲ្យឃើញការភ្ញាក់ផ្អើលដ៏រីករាយ អំណរគុណ និងការបន្ទរទុក្ខព្រួយរបស់ពួកគេ។ សំនួនសេចក្តីបែបធម្មតាមួយ មានដូចខាងក្រោម៖

៣៨ តើបុគ្គលអាចក្លាយជាពុទ្ធសាសនិកដោយរបៀបណា?

"បពិត្រព្រះអង្គដ៏ចំរើន ពិរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ពិរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះអង្គសំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ (ក្លីច្បាស់ណាស់) ដូចជាមនុស្សផ្ងារបស់ដែលគេផ្កាប់ ឬក៏ដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិសពុំនោះសោតដូចជាគេទ្រោលប្រទីប ក្នុងទីងងឹតដោយគិតថាមនុស្សអ្នកមានចក្ខុទាំងឡាយ រមែងមើលឃើញនូវរូបទាំងឡាយ ខ្ញុំព្រះអង្គនោះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាសរណៈចាប់ដើមតាំងពីថ្ងៃនេះទៅ សូមព្រះមានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះករុណាថាជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះរៀងទៅ"។

ទោះបីជាយ៉ាងណាក៏ដោយ ទីណាដែលព្រះពុទ្ធសាសនាបានរីករាលដាលយ៉ាងទូលំទូលាយហើយ បានប្រតិបត្តិអស់ជាច្រើនជំនាន់មកហើយ សរណគមន៍ដែលបានរៀបចំទុកមិនបាត់បង់អត្ថន័យដើមនៅឡើយទេ។

**សរណគមន៍នេះគឺ៖**

ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក។

ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ជាទីពឹងទីរលឹក។

ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃជាទីពឹងទីរលឹក។

ជាធម្មតា សរណគមន៍នេះត្រូវថាចំនួនបីដង ហើយបន្ទាប់មក គេទទួលសិក្ខាបទប្រាំ (សីលប្រាំ) ដែលជាក្រមសីលធម៌គ្រឹះរបស់ពុទ្ធសាសនិកជន។

**សិក្ខាបទប្រាំ ឬបញ្ចសីល (សីលប្រាំ) គឺ៖**

១) ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើជីវិតសត្វឲ្យធ្លាក់ចុះគឺសម្លាប់សត្វ។

២) ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា។

៣) ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

៤) ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក។

៥) ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ។

## ៤០ តើបុគ្គលអាចក្លាយជាពុទ្ធសាសនិកដោយរបៀបណា?

មិនត្រឹមតែ អាចក្លាយជាពុទ្ធសាសនិក ដោយទទួលម្តង ហើយម្តងទៀតនូវសរណគមន៍ និងសិក្ខាបទទាំងនេះទេ ថែមទាំង ពុទ្ធសាសនិក បន្តទទួលនិងចាំនូវសិក្ខាបទទាំងនេះជារៀងរាល់ថ្ងៃ ដើម្បីធ្វើឲ្យជាក់ច្បាស់ថា ពួកគេកំពុងដឹកនាំជីវិតក្នុងផ្លូវត្រូវ។

ទោះបីជាយ៉ាងណាក៏ដោយ ការទទួលសរណគមន៍នៅក្នុង ព្រះពុទ្ធ (យកព្រះពុទ្ធជាទីពឹងជាទីរលឹក) មិនបានបញ្ជាក់ការធានា ផ្ទាល់ខ្លួន ថាគេនឹងទៅដល់គោលដៅរបស់គេនោះទេ។ ផ្ទុយទៅ វិញ ព្រះពុទ្ធបានសម្តែងថា "អ្នកធ្វើបាបដោយខ្លួនឯង នឹងសៅ-ហ្មងដោយខ្លួនឯង អ្នកមិនធ្វើបាបដោយខ្លួនឯង តែងបរិសុទ្ធស្អាត ដោយខ្លួនឯង សេចក្តីបរិសុទ្ធនិងមិនបរិសុទ្ធស្រេចតែនឹងខ្លួនឯង អ្នកដទៃនឹងធ្វើអ្នកដទៃឲ្យបរិសុទ្ធពុំបានឡើយ។ (ធម្មបទ)

# តើពុទ្ធសាសនិកបួងសួងចំពោះព្រះពុទ្ធដែរឬទេ?

តើអ្នកបួងសួង ចំពោះព្រះប៉ុន្មានដងក្នុងមួយថ្ងៃ? តើអ្នកបួងសួងនៅពេលណានិងនៅកន្លែងណា? ទាំងនេះគឺជាសំនួរដែលមិនទាក់ទងដទៃទៀតដែលគេបានសួរខ្ញុំជាច្រើនលើកៗ គ្រប់ពេលទាំងអស់ ខ្ញុំពន្យល់ថា មិនត្រឹមត្រូវទេក្នុងការសួរសំនួរទាំងនោះចំពោះអ្នកកាន់ព្រះពុទ្ធសាសនាៗ ការបួងសួងមានន័យថា ការអង្វរករសុំ ឬការថ្លែងអំណរគុណចំពោះអាទិទេពៗ តាំងពីដើមមកព្រះពុទ្ធសាសនាគឺជាសាសនាដែលមិនជឿទៅ លើព្រះ (ព្រះអាទិទេព) ពាក្យទាំងឡាយបែបនេះ ទៅជាគ្មានន័យដោយស្វ័យប្រវត្តិៗ

ប៉ុន្តែម្យ៉ាងទៀត យើងត្រូវតែទទួលយកជាការសមហេតុសមផល ក្នុងការសួរបណ្តាសំនួរបែបនេះ ពីព្រោះដូចសាសនាដទៃទៀតដែរ ពុទ្ធសាសនិកជន ក៏មានទីកន្លែងពិសេសដែលយើងហៅថាព្រះវិហារ និងគោរព យ៉ាងជ្រាលជ្រៅនូវនិមិត្តរូបទាំងឡាយ ដូចជា ព្រះពុទ្ធបដិមា វត្តអារាម (ជាកន្លែងដែលមានបញ្ចុះអដ្ឋិធាតុព្រះសម្មាសម្ពុទ្ធ) ដើមពោធិព្រឹក្ស ជាកន្លែងដែលព្រះសមណៈគោតមទ្រង់បានសម្រេចសម្មាសម្ពោធិញាណ ជាដើមៗ ពុទ្ធសាសសនិកជនក៏ធ្វើវន្ទនាការ និងបូជាចំពោះព្រះពុទ្ធផងដែរ

ហើយពួកគេសូត្រធម៌នមស្សការ នៅពេលដែលពួកគេបូជា និង វន្ទាចំពោះព្រះបរមសាស្ដា។ អ្នកកាន់ព្រះពុទ្ធសាសនាបូជាទៀន ធូប សូម្បីតែចង្ហាន់ក៏បូជាចំពោះព្រះពុទ្ធរូបដែរ។ បើទុកជាទម្រង់ និងវិធីនៃការបូជានិងសូត្រធម៌ ខុសគ្នាពីនិកាយមួយទៅនិកាយ មួយក្ដី អត្ថន័យនៃសកម្មភាពទាំងនេះ នៅតែមិនផ្លាស់ប្ដូរដដែល។

ពុទ្ធសាសនិកវន្ទាព្រះពុទ្ធជានិមិត្តរូបនៃកតញ្ញូតាធម៌ ពី ព្រោះ ព្រះអង្គបានបង្ហាញយើងនូវផ្លូវត្រូវ ដើម្បីរំលត់សេចក្ដីទុក្ខ និងបានផ្ដល់ឲ្យយើងនូវពុទ្ធិពិត ដើម្បីមើលឃើញពិភពលោកនេះ ទៅតាមសភាវពិត ជំនួសឲ្យតាមរយៈមោហៈ (សេចក្ដីភាន់នៃ វិញ្ញាណ) និងការស្រមើស្រមៃរបស់យើង។ ដើម្បីបំពេញកិច្ចទាំង នេះ ព្រះពុទ្ធបូជាពេលវេលា កម្លាំងកាយចិត្ត និងសូម្បីតែជីវិត របស់ព្រះអង្គ មិនមែនតែម្ដងទេ គឺជាច្រើនលើករាប់មិនអស់។ ទីពីរការបូជានិងការវន្ទានេះ នាំមកនូវទម្រង់នៃសមាធិ។ យើងមិន បូជាផ្កា ទៀន និងធូប ចំពោះព្រះពុទ្ធដើម្បីជាការតុបតែងលំអរ ឬ ជាអំណោយដើម្បីធ្វើឲ្យព្រះអង្គពេញព្រះទ័យ ឬដើម្បីទទួលបាន ពរជ័យទាំងឡាយជាសម្ភារៈ (ឧៈ ទ្រព្យសម្បត្តិ សុខុមាលភាព សុវត្ថិភាព ជាដើម) ទេ។ ចំពោះពុទ្ធសាសនិក ការបូជាទាំងនេះគឺ

ជាគុំរូមួយល្អណាស់ ស្តីអំពីភាពប្រែប្រួលមិនទៀង (អនិច្ចំ)។ ឥឡូវនេះផ្កាទាំងឡាយស្រស់ស្អាតណាស់ ហើយគួរឲ្យទាក់ទាញទៀតផង ប៉ុន្តែនៅថ្ងៃស្អែក ពួកវានឹងស្វិតស្រពោន ហេតុដូច្នេះរាងកាយរបស់អាត្មាអញក៏នឹងបែកធ្លាយ អ៊ីចឹងដែរ (បុប្ផំ មិលាយតិ យថា ឥទម្មេ កាយេ តថា យាតិ វិនាស ភាវំ)។ ចំពោះយើង ពន្លឺគឺជាវត្ថុមានប្រយោជន៍ច្រើនជាងនេះទៅទៀត។ ពុទ្ធសាសនិកចាត់ទុកពន្លឺជានិមិត្តរូបនៃបញ្ញា ហើយអវិជ្ជា និងមាយាជាភាពងងឹត។ ពន្លឺក៏បង្ហាញផងដែរ នូវភាពមិនទៀង។

គេចាត់ទុក ធូបជានិមិត្តរូបនៃជីវិតប្រកបដោយគុណធម៌ (ឃតេសំ គន្ធ ជាតានំ, សីល គន្ធោ អនុត្តរោ ក្លិននៃសីលជាគុណជាតិប្រសើរបំផុតជាងគន្ធជាតិទាំងពួង, ធម្មបទ)។ ហេតុនេះពេលយើងធ្វើការបូជា រឿយៗ យើងនឹកឃើញវិភាគទានដ៏ធំធេងរបស់ព្រះអង្គចំពោះមនុស្សជាតិ និងធម្មជាតិពិតនៃសត្វលោកផងដែរ ព្រមទាំងសារៈសំខាន់នៃការទទួលបានបញ្ញា។ ប្រតិបត្តិតាមគុណធម៌ និងគុណសម្បត្តិរបស់ព្រះពុទ្ធ គឺជាប្រភេទពិសេសមួយនៃសមាធិ (ពុទ្ធានុស្សតិ)។ ដូច្នេះ ជាការខុសឆ្គងធ្ងន់ធ្ងរណាស់ដែលចាត់ទុកការវន្ទារបស់ពុទ្ធសាសនិក ថាជាការគោរព

## ៤៤ តើពុទ្ធសាសនិកបួងសួងចំពោះព្រះពុទ្ធដែរឬទេ?

ទេវរូប ការគោរពចំពោះបុព្វបុរស ឬក៏ការធ្វើឲ្យព្រះពុទ្ធពេញព្រះហឫទ័យ ដើម្បីទទួលបាននូវតម្រូវការផ្នែកស្មារតីនិងសម្ភារៈដោយចាត់ទុកព្រះអង្គថាជា អំណោយទិព្វមានជីវិតមួយ ដូចសាសនាអាទិទេពនិយមនោះ។

ការបូជាទាំងនេះ អាចបង្កើតបានជាបុណ្យដ៏មានប្រយោជន៍ ហេតុដូច្នេះ នេះគឺជាអំពើបុណ្យមួយ។ ទស្សនៈនៃអំពើបុណ្យ (ផលនៃអំពើល្អ) គឺជាលក្ខណៈពិសេសគួរឲ្យកត់សម្គាល់មួយទៀតផងដែរ នៅក្នុងព្រះពុទ្ធសាសនាដែលរឿយៗឲ្យផលជាមិច្ឆាទិដ្ឋិក្នុងចំណោមអ្នកដទៃ រហូតមានការបង្រៀនដូចគ្នាដែរនៅក្នុងសាសនាទាំងឡាយ ដូចជា សាសនាហិណ្ឌូ និង សាសនាជេន។ នៅក្នុងជំពូកបន្ទាប់ ខ្ញុំសូមពន្យល់ទ្រឹស្តីកម្មផល និងការស្រាយបំភ្លឺ របស់ព្រះពុទ្ធសាសនាចំពោះការស្លាប់និងជីវិតក្រោយពេលស្លាប់។ ខ្ញុំសូមពន្យល់ផងដែរ អំពីទំនៀមទម្លាប់បុណ្យបូជាសពរបស់ពុទ្ធសាសនិកជន។

# ការស្រាយបំភ្លឺរបស់ព្រះពុទ្ធសាសនាចំពោះជីវិតក្រោយស្លាប់

ជំនឿសម័យបច្ចុប្បន្នជាច្រើន និងសូម្បីតែសាសនាទាំងឡាយ នៃយុគសម័យដំបូងខ្លះ មានប្រភេទមួយចំនួននៃការជឿលើជីវិតក្រោយពេលស្លាប់។ មិនដូចអ្នកកាន់សាសនាគ្រឹស្តឥស្លាម និងសាសនាជ្វីហ្វ (Jews) ដែលហាក់ដូចជាជឿទៅលើជីវិតតែមួយគត់ ក្រោយពេលស្លាប់ ទាំងនៅក្នុងនរក ឬឋានសួគ៌គ្មានទីបំផុត អាស្រ័យកម្មរបស់ខ្លួនពេលនៅរស់, ព្រះពុទ្ធសាសនាយល់ឃើញត្រូវគ្នាជាមួយសាសនាហិណ្ឌូ សាសនាជេន និងសាសនាសិខ (Sikhism) នូវទស្សនៈអំពីវដ្តនៃជីវិតដែលនៅតែបន្តរហូតបានសម្រេចព្រះនិព្វាន។ យើងមិនគួរភ្លេច ដូចសេចក្តីពិតជាច្រើនរបស់ព្រះពុទ្ធសាសនា បញ្ញត្តិអំពីជីវិតក្រោយពេលស្លាប់គឺខុសគ្នាយ៉ាងច្រើនទៅនឹងសាសនាដទៃទៀត និងរកអ្វីមកប្រៀបស្មើពុំបាន ទោះបីជាសាសនាទាំងនោះអាចមានជំនឿដូចគ្នាក៏ដោយ។ ហេតុនេះចាំបាច់ត្រូវយល់ពីភាពខុសគ្នារវាងការប្រៀនប្រដៅដូចគ្នាទាំងនេះ។ នៅក្នុងជំពូកនេះ ខ្ញុំសូមលើកយកមក

ពិចារណានូវភាពខុសគ្នាសំខាន់ៗ រវាងការប្រៀនប្រដៅទាំងនេះ។

នៅក្នុងព្រះពុទ្ធសាសនា មានពាក្យបីដែលនិយាយដល់ទស្សនៈមួយនេះស្តីអំពី "ជីវិតក្រោយពេលស្លាប់"។ ពាក្យទាំងនេះគឺ "បុនរវតារៈ" (អវតារ) "បុនរុត្បត្តិ" (បដិសន្ធិ) និង "បុនព្ភវៈ" (ភពថ្មី)។ ទាំងបីនេះជាពាក្យខុសគ្នាទាំងស្រុង និងបានត្រូវប្រើប្រាស់ ដើម្បីពន្យល់ការវិវត្តទាំងឡាយខុសៗគ្នា ទោះបីពាក្យទាំងនេះ សុទ្ធតែនិយាយដល់ប្រភេទខ្លះ នៃស្ថានភាពជីវិតក្រោយពេលស្លាប់។ វចនានុក្រមអង់គ្លេសភាគច្រើនឲ្យនិយមន័យ ពាក្យថា បដិសន្ធិ និងអវតារ (rebirth និង reincarnation) ថាជាពាក្យសទិសន័យ។ ជាឧទាហរណ៍ វចនានុក្រម Oxford Reference Dictionary ឲ្យនិយមន័យពាក្យទាំងនេះ តាមរបៀបដូចខាងក្រោម ÷

"អវតារ មានន័យថា បដិសន្ធិនៃវិញ្ញាណ", "បដិសន្ធិ មានន័យថា អវតារថ្មី (តំណរកើតថ្មី)" ខ្ញុំស្ទើរតែមិនអាចរកឃើញពាក្យ "ភពថ្មី (re-becoming)" ដែលបង្ហាញឲ្យឃើញទស្សនៈពុទ្ធសាសនា ស្តីអំពីជីវិតក្រោយពេលស្លាប់ នៅក្នុងវចនានុក្រម

មួយចំនួនៗ មានតែវចនានុក្រមព្រះពុទ្ធសាសនា ដោយព្រះតេជគុណ ញាណតិលោកៈ ឲ្យនិយមន័យពាក្យថា "បុនព្ភវៈ" ("ភពថ្មី") ជាការកើតបន្តៗ

ឥឡូវនេះ ខ្ញុំសូមពន្យល់ពាក្យទាំងនេះបន្ថែមទៀត ដើម្បីបំភ្លឺ បញ្ជាក់ភាពខុសគ្នានៃអត្ថន័យ ដូចដែលខ្ញុំយល់ដឹងពីភាពខុសគ្នាៗ

**បុនរវតរ** (អវតារ)

ពាក្យ "បុនៈ" មានន័យថា "ទៀត, ម្តងទៀត", "អវតរ" គឺជាពាក្យនាមនៃពាក្យ "អវតរណ" ដែលមានន័យថា "ការចុះចាក"ៗ ឥឡូវនេះ យើងអាចសន្និដ្ឋានអត្ថន័យនៃពាក្យ "បុនវតរ" ជាការចុះចាក ឬអ្នកដែលចុះចាកៗ តើនរណាជាអ្នកចុះចាក នៅក្នុងសេចក្តីនេះ? ព្រះអាទិទេពជាអ្នកចុះចាកៗ អ្នកកាន់សាសនាហិណ្ឌូជឿថាព្រះអាទិទេពរបស់ពួកគេ (ព្រះវិស្ណុ) ចុះចាកឋានសួគ៌ ហើយបែងភាគផ្សេងៗ នៅពេលណា និងនៅកន្លែងណាមួយដែលចាំបាច់ៗ ពួកគេតាំងការបែងភាគបែបនេះទាំងដប់ របស់ព្រះអាទិទេព ហើយពួកគេឲ្យឈ្មោះថា "ទស អវតារៈ" (អវតារទាំង

ដប់នៃព្រះវិស្ណុ)។ បើតាមពួកគេ ព្រះអាទិទេពចុះចាកពីឋានសួគ៌មកចាប់កំណើតជាមនុស្សនៅឋានក្រោម ដូចជា ផែនដី ដូច្នេះពាក្យថា "អវតារ" មានន័យថា ការចុះចាក។ ហេតុដូចនេះ អវតារ គឺការបែងភាគនៃព្រះអាទិទេពជារូបផ្សេងៗ។

ភាពពិត អវតារមិនអាចប្រើដើម្បីពន្យល់ស្ថានភាពក្រោយពេលស្លាប់នៃទម្រង់ផ្សេងនៃជីវិតទេ។ ទស្សនៈសាសនាហិណ្ឌូនេះហាក់មានទស្សនៈត្រូវគ្នា ជាមួយសាសនានានាផ្សេងទៀត (ឧ: សាសនាគ្រិស្ត: "ព្រះបិតា និងបុត្រ គឺតែមួយ")។

**បុនរុត្បត្តិ** (បដិសន្ធិ)

ពាក្យ "បដិសន្ធិ" ពាក់ព័ន្ធខ្លាំងទៅនឹងបញ្ញត្តិអំពីអាត្ម័ន។ ដូចយើងបានឃើញនៅក្នុងនិយមន័យ របស់វចនានុក្រមអង់គ្លេស "បដិសន្ធិ" មានន័យថា ការត្រាច់ទៅនៃព្រលឹង។ បញ្ញត្តិនេះ អំពីអាត្ម័ន (បាលី:អត្ត) ជាប្រភពនៃ**វាទប្បដិវាទ** (ការជជែករកខុសត្រូវ) ដែលបានចាក់បញ្ចាំងនៅក្នុងប្រវត្តិសាស្ត្រនៃសាសនា។ បើតាមការពន្យល់នៃសាសនាមួយចំនួន នៅពេលមនុស្សស្លាប់ ព្រលឹងត្រូវចាកចេញនិងបន្តរស់នៅក្នុងរូបថ្មី នៅកន្លែងថ្មីមួយ

ទៀត។ ព្រះពុទ្ធសាសនាមិនទទួលយករបៀបនេះ ថាជាអាត្ម័ន នោះទេ។ ព្រះសម្មាសម្ពុទ្ធសម្តែងថា ការជឿថាជីវិត (មហាភូតរូប[២] និងវិញ្ញាណ) មិនមានទីបំផុតជាទិដ្ឋិមួយ, ការជឿថាជីវិតមិនកើតទៀតទេ នៅពេលសត្វស្លាប់ទៅ (ឧច្ឆេទទិដ្ឋិ) គឺជាទិដ្ឋិមួយផ្សេងទៀត។ ព្រះពុទ្ធទ្រង់បានយល់ច្បាស់ពីយថាភូតធម៌ធម្មជាតិ (ភាពពិតនៃធម្មជាតិ) ដោយលះបង់ទិដ្ឋិទាំងពីរនេះ។ ដូច្នេះហើយ មាគ៌ារបស់ព្រះពុទ្ធ ហៅបានថា មជ្ឈិមបដិបទា (ផ្លូវកណ្តាល)។ ជាធម្មតា ព្រះពុទ្ធបានបដិសេធទស្សនៈស្តីអំពីភាពគ្មានទីបំផុត និងការមិនកើតទៀតក្នុងទីបំផុតនៃមហាភូតរូប នៅពេលដែលសត្វស្លាប់ទៅ។

**បុនព្ភវ** (ភពថ្មី)

ពាក្យ “ភពថ្មី” ឬ “ការកើតថ្មី” អាចចាត់ទុកថាជាទស្សនៈព្រះពុទ្ធសាសនា ស្តីអពីជីវិតក្រោយពេលស្លាប់។

---

[២] មហាភូតរូបគឺធាតុដី (បឋវី) ធាតុទឹក (អាបោ) ធាតុភ្លើង (តេជោ) ធាតុខ្យល់ (វាយោ)។

នៅពេលណា នរណាម្នាក់បដិសេធទស្សនៈស្តីពីអាត្មន័គ្មានទីបំផុត ឬទម្រង់នៃវត្ថុធាតុមិនចេះចប់មិនចេះហើយ គេលើកសំនួរជាក់ស្តែងថា "ប្រសិនបើគ្មានអាត្មន័ទេ នរណាទឹងកើត?" មុនឆ្លើយសំនួរនេះ សំនួរមួយផ្សេងទៀតគួរត្រូវឆ្លើយ។ សំនួរគឺថា "នរណាកំពុងរស់នៅ?" នៅពេលដែលយើងរកឃើញចម្លើយត្រូវនឹងសំនួរនេះ ជាស្វ័យប្រវត្តិយើងអាចរកឃើញចម្លើយទៅនឹងសំនួរទីមួយ។

នរណាទឹងត្រូវកើត? សត្វទឹងត្រូវកើត។ ខ្ញុំបានពន្យល់ពីមុនរួចហើយ ពីលក្ខណៈរបស់សត្វលោក។ ព្រះសម្មាសម្ពុទ្ធបានសម្តែងថា គ្មានអ្វីមួយនៅដដែលដូចពីមុន សូម្បីតែកើតមានឡើងជាលើកទីពីរក៏ដោយ។ អ្វីៗទាំងអស់ស្ថិតនៅក្នុងភាពបន្តជាប់ជានិច្ចនៃដំណើរប្រែប្រួល។ ទ្រឹស្តីនេះគេហៅថា អនិច្ចំ ពោលគឺប្រែប្រួលមិនទៀង យើងមិនអាចចាត់ទុកធម៌ទាំងនេះជាជាសេចក្តីសុខដ៏ក្រៃលែងនោះទេ។ ប្រសិនបើធម៌ទាំងឡាយប្រែប្រួលរហូតនិងជាទុក្ខ តើយើងអាចចាត់ទុកធម៌ទាំងនេះជាជាអាត្មន័គ្មានទីបំផុតដោយរបៀបណា? ម្យ៉ាងទៀត តើយើងអាចចាត់ទុកធម៌ទាំងឡាយដែលប្រែប្រួលមិនទៀង និងជាទុក្ខថាជា "ខ្ញុំ" និង

"របស់ខ្លួន" ដោយរបៀបណា? ទម្រាំយើងយល់ធម្មជាតិពិតនៃព្រះធម៌ យើងមុខជាកើតម្ដងហើយម្ដងទៀត តើយើងទទួលយកទ្រឹស្ដីនេះឬក៏អត់ៗ ហេតុនេះ ចម្លើយនឹងសំនួរទីមួយ "នរណានឹងត្រូវកើត?" គឺ "សត្វនឹងត្រូវកើត" ជាឧទាហរណ៍ ពេលយើងនិយាយថា "តើភ្លៀងឬ?" គ្មាននរណាម្នាក់ចាត់ទុកសំនួរ "តើអ្វីកំពុងភ្លៀង?" ថាជាសំនួរមានន័យនោះទេ នៅពេលគ្រប់គ្នាដឹងថាភ្លៀងគឺកំពុងភ្លៀងៗ ដូចគ្នានេះដែរ ប្រសិនបើអ្នកណាម្នាក់សួថា "តើអ្វីឬនរណានឹងត្រូវកើត?" ចម្លើយរបស់យើងគឺ "សត្វនឹងត្រូវកើត"ៗ

ទោះបីជាយ៉ាងណាក៏ដោយ វាមានន័យគ្រប់គ្រាន់ដើម្បីសួរថា តើហេតុអ្វីសត្វនឹងត្រូវកើតហើយកើតដោយរបៀបណាៗ ចម្លើយយ៉ាងរហ័ស ចំពោះសំនួរនេះគឺ៖

"យើងកើត ពីព្រោះតណ្ហាជិតជាប់ជាយូរមកហើយចំពោះលោកបានចងយើងជាប់នៅក្នុងវាលវដ្ដសង្សារៗ តណ្ហាយ៉ាងមាំទាំងនេះមានបីគឺ តណ្ហាប្រព្រឹត្តទៅក្នុងកាម (កាមតណ្ហា) តណ្ហាប្រព្រឹត្តទៅក្នុងភព (ភវតណ្ហា) និង តណ្ហាប្រព្រឹត្តទៅក្នុងការប្រាសចាកភព (វិភវតណ្ហា)ៗ តណ្ហាទាំង ៣ នេះ ជាដើមហេតុនៃ

ការកើតរបស់ខ្លួន ពីព្រោះយើងជាប់ចិត្ត និងតណ្ហាកាន់តែខ្លាំង យើងជាប់ស្អិតនៅក្នុងវដ្តនៃការកើត តួយ៉ាង ប្រសិនបើយើង បោះវត្ថុទាំងឡាយឡើងទៅលើ ពួកវាធ្លាក់ចុះមកផែនដីវិញ។ ដូចគ្នានេះដែរ តណ្ហាមានកម្លាំងលោហកាន្ត (មេដែក) ដែលចងភ្ជាប់សត្វនៅក្នុងវដ្តនៃការកើត។ នៅពេលយើងកាត់ផ្តាច់ឫសគល់នៃតណ្ហាទាំងនេះ ត្រឹមតែប៉ុណ្ណោះយើងនឹងរួចផុតពីការវិលកើតវិលស្លាប់។ ព្រះសម្មាសម្ពុទ្ធបានបង្ហាញឲ្យឃើញថា សត្វលោកមិនអាចយល់ដឹងពីធម៌នេះទេ ពីព្រោះតែអវិជ្ជារបស់ពួកគេ។ សត្វលោកស្ថិតនៅក្នុងវដ្តនៃការកើតស្លាប់-ស្លាប់កើត រហូតដល់ពួកគេអាចយកឈ្នះ លើតណ្ហាដែលជាប់ស្អិតជាយូរមកហើយរបស់គេបាន។ ជាលទ្ធផល ពួកគេនៅតែផ្ទុកប្រេងចាំបាច់សម្រាប់ ដំណើរដ៏វែងឆ្ងាយរបស់ពួកគេ។ ប្រេងនេះ គេហៅថា "**វិបាក**" ពោលគឺ ផលនៃកម្ម។ ផលអាចជាកុសល (អំពើបុណ្យ) ឬអកុសល (អំពើបាប)។ ទស្សនៈព្រះពុទ្ធសាសនា គឺថា ធ្វើអំពើល្អទទួលបានផលល្អ ធ្វើអំពើអាក្រក់ទទួលបានផលអាក្រក់។ កម្មនីមួយៗ និងគ្រប់កម្មទាំងអស់ ត្រូវបាន"កត់ត្រាទុក" ហើយយើងត្រូវទទួលខុសត្រូវចំពោះកម្មផ្ទាល់របស់យើង។ កម្មនេះមានកម្លាំង

ខ្លាំងសម្បើមណាស់ ដូច្នោះជីវិតបន្ទាប់របស់យើង អាស្រ័យច្រើនតែទៅលើអ្វីដែលយើងបានធ្វើនៅក្នុងជាតិនេះ។

ចំណុចមានសារៈសំខាន់មួយទៀត គឺពុទ្ធសាសនិកមិនត្រឹមតែជឿលើជីវិតក្រោយពីការស្លាប់ប៉ុណ្ណោះទេ ថែមទាំងមានជំនឿយ៉ាងមុតមាំ ទៅលើជីវិតមុនការកើតបច្ចុប្បន្ននេះទៅទៀត។ ដូចយើងនិយាយថា មានថ្ងៃម្សិលមិញជាច្រើន ហើយក៏នឹងមានថ្ងៃស្អែកជាច្រើនទៀតដែរ យើងនឹងមានជាតិជាច្រើនទៀត ក្រោយពេលស្លាប់ និងមានជាតិជាច្រើនផងដែរពីមុន។ គេអាចនឹងបញ្ចេញទស្សនៈផ្ទុយថា គេមិនទទួលយកទ្រឹស្តីនេះទេ ពីព្រោះពួកគេមិនអាចយល់ទ្រឹស្តីបែបនេះ។ នេះដូចជាមនុស្សខ្វាក់ម្នាក់និយាយថា "លោកនិយាយអំពីពណ៌ទាំងឡាយ ដូចជា ខ្មៅ សគ្នោត ជាដើម ប៉ុន្តែខ្ញុំមើលមិនឃើញពណ៌ណាមួយទេ ហេតុនេះគ្មានវត្ថុណាពណ៌អ្វីចឹងទេ តើយើងយល់ព្រមនឹងការថ្លែងរបស់ពួកគេទេ? នេះមិនមានន័យអាថ៌កំបាំងថា យើងត្រូវតែជឿអ្វីៗទាំងអស់ដែលនិយាយដោយសាសនាទាំងងងឹតនោះឡើយ ពោលគឺយើងមិនគួរភ្លេចថា គ្មានកន្លែងណាមួយ សម្រាប់ជំនឿងងឹតងងល់នោះទេ (អមូលិកសទ្ធា) នៅក្នុងព្រះពុទ្ធសាសនា។ ប្រសិន

បើយើងក្រឡេកមើលសង្គម មានភស្តុតាងច្រើនណាស់ ដើម្បីជឿថា មានអំណាចអរូបីគ្រប់គ្រងជីវិតរបស់ពួកយើង តើវាជាកម្មឬជាបំណងរបស់ព្រះអាទិទេព?

ទោះបីជាយ៉ាងណាក៏ដោយ ទ្រឹស្តីកម្មនេះដូចបានពន្យល់នៅក្នុងព្រះពុទ្ធសាសនា មិនមានន័យថា អ្វីៗទាំងអស់សុទ្ធតែកើតឡើងពីកម្មទាំងអស់នោះទេ។ មានហេតុដទៃមួយចំនួនទៀតដែលទាក់ទង។ គេហៅថា (បញ្ច និយាមធម៌) (ច្បាប់ធម្មជាតិទាំងប្រាំយ៉ាង)។ ច្បាប់កម្មផល ទាំងជានិយតិវាទ (ជឿកម្មវាសនា) ទាំងទតវាទ (ជឿការរៀបចំទុកជាមុន) ដែលបដិសេធអំណាចសម្រេចខ្លួនឯងរបស់មនុស្ស។ សេចក្តីលំអិតបន្ថែម អាចរកអានអំពីទ្រឹស្តីកម្មផលរបស់ព្រះពុទ្ធសាសនានៅក្នុងសៀវភៅ ដូចជា វិញ្ញាណទស្សនៈ និព្វានទស្សនៈ...ជាដើម។

# ទំនៀមទម្លាប់បុណ្យបូជាសពរបស់ពុទ្ធសាសនិក

ទំនៀមទម្លាប់របស់អ្នកកាន់ព្រះពុទ្ធសាសនានៅទូទាំងពិភពលោក ខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ ពីនិកាយមួយទៅនិកាយមួយទៀតៗ ហេតុផលសំខាន់ចំពោះរឿងនេះគឺព្រះពុទ្ធទ្រង់បានសម្ដែងពីសារៈ សំខាន់នៃជីវិត ដែលបដិបត្តិព្រះធម៌ ជាជាងលះបង់ពេលវេលា កម្លាំងកាយ និងសូម្បីតែចំណេះដឹងជាច្រើនរបស់យើងទៅរៀបចំពិធីនានា និងពិធីបុណ្យផ្សេងៗដែលមានតម្លៃថ្លៃៗនិងរស់រវើក ពីព្រោះពិធីទាំងនេះមិនអាចជួយយើងឲ្យទទួលបានការអភិវឌ្ឍផ្លូវចិត្ត ឬក៏យកជ័យជំនះលើបញ្ហាសំខាន់ៗរបស់យើងបានទេ។ ហេតុនេះគ្មានច្បាប់ និងបទបញ្ញាមិនប្រែប្រួលអំពីការសាងសង់វត្តអារាម ការរៀបចំពិធីបុណ្យទានសាសនា និងពិធីបុណ្យនានា ឬសូម្បីតែការសូត្រអត្ថបទធម៌ស័ក្តិសិទ្ធិក៏គ្មានដែរ។ អ៊ីចឹងហើយ ទីកន្លែងសក្ការៈបូជានានា វត្តអារាមនិងបុណ្យផ្សេងៗខុសៗគ្នា ពីប្រទេសមួយទៅប្រទេសមួយ និងពីប្រពៃណីមួយទៅប្រពៃណីមួយ នៅក្នុងប្រទេសអ្នកកាន់ព្រះពុទ្ធសាសនានានាក្នុងពិភពលោក។

ប្រពៃណីព្រះពុទ្ធសាសនាផ្សេងៗគ្នា មានពិធីបុណ្យនានា ដែលទាក់ទងទៅនឹងការកើត ការរៀបអាពាហ៍ពិពាហ៍ ការស្លាប់ ជាដើម។ ទោះបីពិធីបុណ្យទាំងនោះប្លែកៗពីគ្នាជាក់ស្តែងក៏ដោយ ក៏ទស្សនៈដើមនៅតែគ្មានខុសខាតដដែល។ នៅក្នុងជំពូកនេះ ខ្ញុំសូមពន្យល់ពីលក្ខណៈពិសេសសំខាន់ៗ នៃទំនៀមទម្លាប់បុណ្យបូជាសព។

នៅពេលដែលនរណាម្នាក់ស្លាប់ គ្មានការទាក់ទងណាមួយទៅនឹងអ្វីៗក៏ដោយ រវាងរាងកាយដែលស្លាប់ (សាកសព) ហើយនឹងជីវិតថ្មីបន្ទាប់របស់គេទេ។ ហេតុនេះ ពុទ្ធសាសនិកមិនមានការតឹងរឹង អំពីការកំណត់ពេលវេលា ឬថាតើគួរបូជា ឬគួរកប់យ៉ាងណានេះ។ ពឹងផ្អែកជាខ្លាំងលើ នៅពេលណា និងនៅកន្លែងណា ដែលមនុស្សនោះស្លាប់។ ជាតួយ៉ាង នៅពេលកុមារស្លាប់នៅអាយុតិច ពុទ្ធសាសនិកជាតិសិរីលង្កា ជាធម្មតាកប់សាកសពក្មេងនោះ ប្រសិនបើនរណាម្នាក់ស្លាប់ពេលមានអាយុច្រើន ជាធម្មតាគេបូជាសាកសពនោះ។ រយៈពេលមុនពិធីបូជាសពក៏ខុសប្លែកគ្នា បើយោងទៅតាមកាលៈទេសៈ។ ពេលខ្លះអាចពីរ ឬបីម៉ោង ហើយជួនកាល គេតម្កល់រាប់ឆ្នាំ។ ជាឧទាហរណ៍ នៅក្នុង

ប្រទេសថៃ ជូនកាលគេតម្កល់ សាកសពនៃព្រះសង្ឃដែលល្បី ឈ្មោះ ឬព្រះមហាក្សត្ររយៈពេលពីរ ឬក៏បីឆ្នាំ។ ប៉ុន្តែ ពិតជាមិន មានបញ្ហាអ្វីទេរយៈពេលប៉ុន្មានដែលសាកសព ត្រូវគេតម្កល់ទុក ឬថាតើបូជា ឬក៏កប់នោះ ពីព្រោះកាលណាមនុស្សស្លាប់ហើយ មិនដែលត្រលប់មកកាន់សាកសពនេះម្ដងទៀតទេ។

ជាធម្មតា គេនិមន្តព្រះសង្ឃទៅសូត្រធម៌ និងសម្ដែងព្រះ ធម្មទេសនា ពន្យល់អំពីសេចក្ដីស្លាប់និងជីវិតក្រោយពេលស្លាប់។ នៅក្នុងឱកាសទាំងនេះ ព្រះសង្ឃជារឿយៗពន្យល់អំពីអនិច្ចតាធម៌ និងបញ្ជាក់អំពីសារៈសំខាន់នៃជីវិត ដែលប្រកបដោយគុណធម៌ ពីព្រោះការកើតបន្ទាប់ពឹងផ្អែកជាខ្លាំងលើអ្វី ដែលបានធ្វើនៅក្នុង ជាតិនេះ។ ប្រសិនបើសាកសពត្រូវបានគេបូជា ជូនកាលគេរក្សា ទុក**អដ្ឋិធាតុ** (ឆ្អឹង) នៅក្នុងកន្លែងដែលបានកសាង ជាពិសេស ជា និមិត្តរូបនៃគារវៈ ប៉ុន្តែនេះមិនមានលក្ខណៈទូទៅ ចំពោះបណ្ដា ប្រទេសកាន់ព្រះពុទ្ធសាសនាទាំងអស់ទេ។

អ្វីដែលមានលក្ខណៈរួម ចំពោះបណ្ដាប្រទេសកាន់ព្រះពុទ្ធ សាសនាទាំងអស់ គឺទស្សនៈស្ដីអំពីបុណ្យរំលឹកខួប។ សូមបញ្ជាក់ សារជាថ្មីថា ទោះបីជាគ្មានពិធីបុណ្យសកលក៏ដោយ ក៏អត្ថន័យ

ដើមនៅតែមិនផ្លាស់ប្តូរចំពោះពុទ្ធសាសនិកទាំងអស់។ ទោះបីជាអ្នកដែលស្លាប់បាត់បង់ផ្ទែករាងកាយ និងគ្មាននៅលើលោកនេះទៀតក៏ដោយ ក៏នៅមានទំនាក់ទំនងរវាងវិញ្ញាណរបស់គេ ពិសេសប្រសិនបើវិញ្ញាណមិនទាន់ទៅចាប់កំណើតក្នុងភពថ្មី ក្រោយពេលស្លាប់ ដោយខ្វះកម្មជាកុសលមានកម្លាំងឲ្យផល ឬដោយសារកម្មជាអកុសល។ នៅក្នុងកាលៈទេសៈបែបនេះ អ្នកដែលស្លាប់ទៅពឹងទៅលើញាតិសន្តាន និងមិត្តភក្តិរបស់គេ ឲ្យជួយដើម្បីបានទៅចាប់កំណើតក្នុងភពដ៏ប្រសើរ។ ការជួយនេះអាចត្រឹមតែបញ្ជូនទៅឲ្យបុគ្គលដែលស្លាប់ជាផលកុសលតែប៉ុណ្ណោះ។ ផលជាកុសលនេះជាធម្មតាត្រូវបានធ្វើនៅផ្ទះសាច់ញាតិដែលនៅជិតបំផុត។ គេនិមន្តព្រះសង្ឃ និងប្រគេនចង្ហាន់ ដែលបន្ទាប់មកកុសលត្រូវគេបញ្ជូនតាមការច្រួចទឹកជានិមិត្តរូប។ ជាធម្មតា ព្រះសង្ឃផ្តល់សាកច្ឆា (ការសាកសួរធម៌អាថ៌( ខ្លីមួយ ស្តីអំពីអត្ថន័យ និងសារៈសំខាន់នៃការធ្វើបុណ្យឧទ្ទិសបែបនេះ។ ការធ្វើបុណ្យបញ្ជូនកុសលនេះ ហៅថា បត្តិទាន ហើយការបែងចែករំលែកបុណ្យកុសល ហៅថា បត្តានុមោទនា។ ពិធីបុណ្យរំលឹកខួបជាធម្មតាប្រារព្ធ ធ្វើក្រោយពេលស្លាប់ប្រាំពីរថ្ងៃ ហើយម្តងទៀតបន្ទាប់ពី

ស្ទាប់បីខែ ឬមួយឆ្នាំក្រោយមរណភាព។ ស្មើតែពិធីបុណ្យរំលឹកខួបប្រចាំឆ្នាំ និយមធ្វើក្នុងចំណោមអ្នកកាន់ព្រះពុទ្ធ ពិធីបុណ្យខួបនេះចាត់ទុកជាពិធីបុណ្យសំខាន់ ហើយគេថាជានិមិត្តរូបនៃកតញ្ញូតាធម៌។ វាជាភារកិច្ចរបស់កូនចៅ ក្នុងការធ្វើពិធីបុណ្យខួបរំលឹក ដល់មាតាបិតារបស់ពួកគេ។

គ្មានពិធីបុណ្យសកលស្តីអំពីការកើត ការរៀបអាពាហ៍-ពិពាហ៍ ឬពិធីបុណ្យធ្វូងទេ។ ពិធីបុណ្យទាំងនេះខុសប្លែកគ្នា ពីប្រទេសមួយទៅប្រទេសមួយ និងពីប្រពៃណីមួយទៅប្រពៃណីមួយ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលកន្លែងជាច្រើនព្រះសង្ឃ និងបព្វជិត នឹងចូលរួមនៅក្នុងរបៀបមួយ ដោយសូត្រធម៌អំពីគម្ពីរព្រះសូត្រឲ្យពរ ឬសម្តែងធម៌ទេសនា។ ឧបាសកឧបាសិកាអាចទៅវត្តអារាម ឬព្រះវិហារក្នុងពិធីបុណ្យមួយចំនួន។ ពិធីបុណ្យខ្លះក្នុងចំណោមពិធីបុណ្យធម្មតា នៅក្នុងប្រទេសកាន់ព្រះពុទ្ធសាសនាថេរវាទ និងមានពន្យល់ដោយសង្ខេប នៅក្នុងជំពូកបន្ទាប់នេះ។

# ពិធីបុណ្យនានាក្នុងព្រះពុទ្ធសាសនា

## ពិសាខបូជា

ដោយសារតែព្រះពុទ្ធសាសនាមានទំនោរ បញ្ចូលគ្នាតែមួយ នៅក្នុងជីវិតប្រចាំថ្ងៃ នៃបណ្តាប្រទេសនានាដែលខ្លួនបានចាក់ឫសគាល់ ពិធីបុណ្យព្រះពុទ្ធសាសនាភាគច្រើនមានឥទ្ធិពល ដោយវប្បធម៌តាមតំបន់ៗ ព្រះពុទ្ធសាសនាមានទំនោរប្រកាន់យក ឬ សម្របខ្លួនទៅតាមពិធីបុណ្យនានា ដែលមានស្រាប់ ហើយនៅក្នុងប្រទេសមួយចំនួន តួយ៉ាងដូចប្រទេសនេប៉ាល់ ពិធីបុណ្យទាំងនេះមានច្រើនយ៉ាង និងអធិកអធមៗ ចំណុចសំខាន់នៃប្រតិទិនព្រះពុទ្ធសាសនា ក្នុងបណ្តាប្រទេសកាន់ព្រះពុទ្ធសាសនាថេរវាទ គឺខែ “ពិសាខ” ជាពេលដែលព្រះពុទ្ធសាសនិកជនទាំងឡាយធ្វើពិធីបុណ្យរំលឹកដល់ព្រះសម្មាសម្ពុទ្ធទ្រង់ប្រសូត្រ ត្រាស់ដឹង និង បរិនិព្វានៗ ពិធីបុណ្យនេះ ជាទូទៅត្រូវថ្ងៃពេញបូណ៌មី ខែឧសភា ជារៀងរាល់ឆ្នាំៗ នៅក្នុងបណ្តាប្រទេសកាន់ព្រះពុទ្ធសាសនាមហាយាន ក៏មានភាពខុសគ្នា ទៅតាមតំបន់និងនិកាយ ដែលទាក់ទិន

ទៅនឹងពេលវេលា ដែលព្រឹត្តិការណ៍ធំៗទាំងនេះ ត្រូវបានគេប្រារព្ធធ្វើដើម្បីរំលឹកដល់ពិធីនោះៗ ជាពិសេសនៅប្រទេសលោកខាងលិច ពិធីបុណ្យនេះត្រូវបានគេហៅថា "Buddha Day"ៗ

## អាសាឡ្ហបូជា

ជាប្រពៃណី នៅក្នុងបណ្តាប្រទេសកាន់ព្រះពុទ្ធសាសនា ឲ្យឈ្មោះថា អាសាឡ្ហបូជា ជាពិធីបុណ្យសម្តែងធម្មចក្រៗ ថ្ងៃពេញបូណ៌មី ខែកក្កដា ជារៀងរាល់ឆ្នាំ ជាធម្មតា ពុទ្ធសាសនិកប្រារព្ធធ្វើពិធីបុណ្យរំលឹកដល់ព្រះធម្មទេសនាដំបូង របស់ព្រះសម្មាសម្ពុទ្ធ ដែលសម្តែងនៅព្រៃឥសិបតន មិគទាយវ័ន ជិតក្រុងពារាណសី ចំពោះបញ្ចវគ្គិយ ដែលជាអ្នកតាមបម្រើព្រះអង្គពីមុនៗ

## កឋិនទាន

ពិធីបុណ្យកឋិនទាន ជាធម្មតាប្រារព្ធធ្វើបន្ទាប់ពីការចាំព្រះវស្សា ជារៀងរាល់ឆ្នាំៗ ជាធម្មតា នៅថ្ងៃពេញបូណ៌មី ខែកក្កដា ជារៀងរាល់ឆ្នាំ ព្រះសង្ឃនៃបណ្តាប្រទេសកាន់ព្រះពុទ្ធសាសនា ចាប់ផ្តើមចូលព្រះវស្សា ដែលមានរយៈពេលបីខែ ហើយនៅក្នុង

ខែតុលា យើងប្រារព្ធធ្វើពិធីបុណ្យប្រគេនកឋិនចីវរ និងបរិវារកឋិន ចំពោះព្រះសង្ឃ។ ពិធីបុណ្យនេះប្រារព្ធធ្វើឡើង ដាច់ដោយឡែកពីគ្នា ទៅតាមវត្តនីមួយៗ នៅថ្ងៃដែលបានជ្រើសរើសទុក នៅក្នុងខែដែលកំណត់។ ពិធីបុណ្យនេះជានិមិត្តរូបនៃទំនាក់ទំនងជិតស្និទ្ធរវាងព្រះសង្ឃ និងឧបាសកឧបាសិកា។

**ពិធីបុណ្យពុស្សុខ**

ថ្ងៃពេញបូណ៌មី ខែមិថុនា ជារៀងរាល់ឆ្នាំ ពុទ្ធសាសនិកនៅប្រទេសសិរីលង្កា ប្រារព្ធធ្វើពិធីបុណ្យរំលឹកដល់ការផ្សព្វផ្សាយព្រះពុទ្ធសាសនាចូលមកប្រទេសសិរីលង្កា ដោយព្រះអរហន្ត **មហិន្ទ** ជាបុត្ររបស់ព្រះបាទអសោក កាលពីជាង ២.០០០ឆ្នាំមុន។

ស្ទើរតែនៅគ្រប់ពិធីបុណ្យទាំងអស់ខាងលើ ពុទ្ធសាសនិករៀបចំព្រឹត្តិការណ៍ទាំងនេះ ដោយទទួលសីលប្រាំបី បូជាផ្កាភ្ញី និងទៀនធូប ចំពោះព្រះពុទ្ធ ធ្វើសមាធិភាវនា ប្រគេនចង្ហាន់ចំពោះព្រះសង្ឃ ហើយអ្នកទាំងឡាយណា ដែលទទួលសីលប្រាំបី រៀបចំកម្មវិធីបុណ្យ និងស្តាប់ព្រះធម៌ទេសនា ឬធម្មសាកច្ឆា ដែលទាក់ទងនឹងខ្លឹមសារនៃព្រឹត្តិការណ៍ក្នុងឱកាសពិសេសនេះ។ ជាធម្មតាការរៀបចំពិធីបុណ្យនេះប្រព្រឹត្តទៅនៅក្នុងវត្តអារាមនិងព្រះវិហារ។

# ទស្សនៈព្រះពុទ្ធសាសនាអំពីអាទិទេព ឬពហុទេព

នៅពេលដែលមានទិដ្ឋិផ្ទុយគ្នាទាំងស្រុង បានបញ្ជាក់នៅក្នុងការនិពន្ធរបស់ពួកលោកខាងលិច អំពីឥរិយាបថរបស់ព្រះពុទ្ធសាសនា ចំពោះទស្សនៈអាទិទេព ឬពហុទេព ខ្ញុំចាត់ទុកថាមានប្រយោជន៍ ក្នុងការស្រាវជ្រាវរាវរកបុព្វហេតុនៃប្រធានបទ ឲ្យកាន់តែជិតដិតថែមទៀត។

ក្នុងអក្សរសិល្ប៍ពុទ្ធនិយមទាំងអស់ ទស្សនៈអំពីអាទិទេពបង្កើតលោក គឺគ្រាន់តែបង្កើតនៅក្នុងគំនិតស្រមើស្រមៃ គ្មានព្រំដែន និងប្រកបដោយសព្វានុភាពមិនស៊ីគ្នា ជាមួយឱវាទរបស់ព្រះសម្មាសម្ពុទ្ធ។ ទស្សនៈអំពីព្រះជាម្ចាស់នៃការរ៉ាយរាប់ណាមួយ ដូចជា បរមត្ម: ឬ ឯកធម្ម: ត្រូវបានបដិសេធដោយពុទ្ធោវាទស្ដីអំពីអនត្តាធម៌ (មិនមែនជារបស់ខ្លួន)។

នៅក្នុងអក្សរសិល្ប៍ពុទ្ធនិយម ជំនឿទៅលើអាទិទេពអ្នកបង្កើតលោក (ឥស្សរនិម្មានវាទ) ត្រូវបានអធិប្បាយនិងប្រានចោលជាមួយហេតុផលផ្សេងៗទៀត ដែលសន្និដ្ឋានខុស ក្នុងការពន្យល់អំពីដើមកំណើតនៃលោក ជាឧទាហរណ៍ ឯកធម្ម: ដូចជា ពេល-

វេលា ធម្មជាតិជាដើម។ ទោះបីជាយ៉ាងណាក៏ដោយ ជំនឿទៅលើអាទិទេពមិនចាត់ចូល ទៅក្នុងប្រភេទណាមួយនៃមិច្ឆាទិដ្ឋិ ដែលបដិសេធកម្មអាចឲ្យផលខាងសីលធម៌ ដែលសន្ទត់ដើមកំណើតមនុស្ស និងធម្មជាតិដោយចៃដន្យ ឬដែលបង្រៀនតែនិយតិវាទតែមួយ ពោលគឺទិដ្ឋិទាំងនេះឲ្យផលមិនល្អទាំងអស់ មានផលអាក្រក់ពិត (និយតមិច្ឆាទិដ្ឋិ) ដោយសារផលរបស់វាប៉ះពាល់ទៅលើសមាចារ។

ទេវនិយម កើតមានឡើងក្នុងគោលបំណងធ្វើបដិរូបកម្មអំណាច ដែលបង្កើតឲ្យមានក្រឹត្យក្រមធម្មជាតិ។ ជាតួយ៉ាងលក្ខណៈធម្មជាតិបីយ៉ាងរបស់សាសនាហិណ្ឌូ ត្រូវបានគេធ្វើបដិ-រូបកម្មជាព្រះអាទិទេព ដែលគេគោរពបូជាបីអង្គ ដូចជា **ព្រះព្រហ្ម** ជាអ្នកបង្កើតលោក **ព្រះវិស្ណុ** ជាអ្នករក្សាលោក និង **ព្រះមហេស្វរៈ** ជាអ្នកបំផ្លាញលោក។ ដោយសារតែការប្រៀនប្រដៅបែបទេវ-និយមរបស់សាសនាហិណ្ឌូគ្មានតែមានភាពស្មុគស្មាញ យើងត្រូវតែប្រុងប្រយ័ត្នកុំយល់ច្រឡំ វត្ថុតំណាងបីយ៉ាងខាងលើ (**ត្រីមូរតិ** three Murthi) ជាមួយការចែកពហុទេពបែបទេវនិយមមួយចំនួនទៀត ដូចជាអាទិទេពសង្គ្រាម អាទិទេពកសិកម្ម ជាដើម ពីព្រោះសូម្បីតែឈ្មោះ “មូរតិ” តែមួយបានពន្យល់ទស្សនៈនោះហើយ។

តាមន័យនៃពាក្យ មូរតិ គឺជាវត្ថុតំណាង ឬការតំណាងនៃអំណាច ឬលក្ខណៈធម្មជាតិពិសេសណាមួយ។ ហេតុនេះទស្សនៈហិណ្ឌូនេះស្ដីអំពីត្រីមូរតិ គឺពិតជាផលនៃការធ្វើបដិរូបកម្មធម្មជាតិ។ មិនត្រឹមតែសាសនាហិណ្ឌូប៉ុណ្ណោះទេ ថែមទាំងសាសនាទេវនិយមផ្សេងៗទៀតទាំងអស់ផងដែរ បានយល់ត្រូវគ្នាអំពីទស្សនៈនៃការធ្វើបដិរូបកម្មនេះ តាមវិធីមួយ ឬមួយផ្សេងទៀត។

នៅក្នុងជំពូកនេះ ខ្ញុំសូមជូនជាការពិចារណារកហេតុផលថា តើហេតុអ្វី និងយ៉ាងដូចម្ដេចទើបព្រះពុទ្ធបដិសេធទស្សនៈស្ដីពីអាទិទេព សព្វញ្ញុភាពនិងសព្វានុភាពព្រមទាំង ទម្រង់ផ្សេងៗទៀតនៃការប្រៀនប្រដៅបែបនេះ (ជាតួយ៉ាង ព្រះអាទិទេពបង្កើតលោក និងព្រះជាម្ចាស់សួគ៌)។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា បំណងនេះអាចកាត់បន្ថយការយល់ច្រឡំ អំពីឥរិយាបថព្រះពុទ្ធសាសនាចំពោះទស្សនៈអាទិទេពនិយម។

ព្រះសម្មាសម្ពុទ្ធទ្រង់គិតឃើញថា ពុទ្ធិណាមួយដែលមិនជួយឲ្យ យើងមើលឃើញធម៌ទាំងឡាយច្បាស់លាស់ ទៅតាមសភាវៈពិត ពោលគឺទទួលបានចំណេះដឹងខាងអធិបញ្ញា សុខស្ងប់ ការត្រាស់ដឹងនិងនិព្វានទេ គេគប្បីត្រូវបោះបង់ចោល ហើយចាត់ទុក

វាថាជាមិច្ឆាទិដ្ឋិចុះ។ ព្រះអង្គបានសម្តែងថា ទស្សនៈស្តីពីអាទិទេព បង្កើតលោក និងលោកនេះអាទិទេពជាអ្នកបង្កើត (ឥស្សរ-និម្មានវាទ) មិនបានផ្តល់ឲ្យយើងនូវចំណេះដឹង ដែលយកជាផល ប្រយោជន៍ បានដើម្បីត្រាស់នូវអរិយសច្ចៈទាំងឡាយ ហេតុនេះ ហើយព្រះសម្មាសម្ពុទ្ធបានបដិសេធទស្សនៈនេះ ជាមួយនឹងការ បង្រៀនដូចគ្នាដទៃទៀតមួយចំនួនដូចជា និយតិវាទ (អ្វីៗមានការ កំណត់ជាមុន) និងវាសនានិយម (ឧត្តវាទ) ព្រមទាំងជំនឿដែល ថាអ្វីៗទាំងអស់កើតឡើង ដោយសារកម្មពីអតីត (បុព្វេកតហេតុ-វាទ)។

ទីពីរ ជំនឿទៅលើអភិធម្មជាតិ គឺហួសវិស័យមនុស្ស ពោល គឺទាំងការចេះដឹងកម្រិតធម្មតាទាំងអភិញ្ញា។ ទីនេះអភិញ្ញាមានន័យ ថាអានិសង្សនៃសមាធិភាវនា។ គេនិយាយថា មនុស្សម្នាក់អាច សម្រេចទិព្វចក្ខុនិងទិព្វសោត ដែលភ្នែកនិងត្រចៀកធម្មតាមិន អាចមើលឃើញនិងស្តាប់ឮ (ទិព្វចក្ខុគឺភ្នែកទិព្វ និងទិព្វសោតគឺ ត្រចៀកទិព្វ)។ នៅក្នុងបរិបទនេះ "ទិព្វ" គឺមិនមែនអ្វីមួយដែល ត្រូវធ្វើជាមួយអភិធម្មជាតិនោះទេ។ ជាធម្មតា អភិញ្ញាមានន័យថា ជាផលនៃវិរិយៈ (សេចក្តីព្យាយាមរបស់មនុស្ស)។

ជឿលើញាណបែបនេះ ដោយគ្មានការពិសោធឲ្យឃើញច្បាស់ មិនជាវិធីជួយឲ្យសម្រេចបានអភិញ្ញានោះទេ។ សំរាំទខាងក្រោមនេះផ្តល់នូវការយល់ដឹងទ្រឹស្តីព្រះពុទ្ធសាសនា ចំពោះទស្សនៈអំពីអាទិទេព។

“ម្នាលវាសេដ្ឋៈ មែនហើយ បានឮថា ពួកព្រាហ្មណ៍ អ្នកត្រៃវិជ្ជា មិនដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួន បានឮថា ពួកអាចារ្យរបស់ពួកព្រាហ្មណ៍ អ្នកត្រៃវិជ្ជា ក៏មិនដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនដែរ ពួកបុព្វាចារ្យរបស់ពួកព្រាហ្មណ៍តាំងពីជំណាន់អាចារ្យជាជីតារបស់អាចារ្យ ជាគំរប់៧ ក៏មិនដែលឃើញព្រហ្មផ្ទាល់នឹងភ្នែករបស់ខ្លួនដែរ ពួកឫសីជាន់មុនៗដែលជាអ្នកតែងមន្ត ជាអ្នករាយមន្ត ដល់ពួកព្រាហ្មណ៍ អ្នកត្រៃវិជ្ជា ពួកព្រាហ្មណ៍ អ្នកត្រៃវិជ្ជា ក្នុងកាលឥឡូវនេះ តែងស្វាធ្យាយតែបទមន្តបុរាណនេះ ដែលពួកឫសីធ្លាប់ស្វាធ្យាយ ធ្លាប់រៀន ធ្លាប់ប្រមូលទុកមកហើយ តែងសូត្រតាមបទមន្តនោះ តែងពោលតាមបទមន្ត ដែលឫសីទាំងឡាយពោលមកហើយ តែងបង្រៀនតាមបទមន្ត ដែលឫសីទាំងឡាយបង្រៀនមកហើយ សូម្បីឫសីទាំងនោះ ក៏មិនពោលយ៉ាងនេះថា ព្រហ្មនៅក្នុងទីណា ព្រហ្មមាន

សណ្ឋានយ៉ាងណា ព្រហ្មនៅក្នុងកន្លែងណា យើងទាំងឡាយស្គាល់ទីនុ៎ះ យើងទាំងឡាយឃើញព្រហ្មនុ៎ះដូច្នោះដែរ។”

ហេតុនេះ ព្រះសម្មាសម្ពុទ្ធទ្រង់បានប្រៀបធៀបជំនឿងងឹតងងល់បែបនេះទៅនឹងមនុស្សមានភ្នែកខ្វាក់ ដើរជាជួរតោងគ្នានឹងគ្នា។ “ម្នាលវាសេដ្ឋៈ ដូចមនុស្សមានភ្នែកខ្វាក់ ដើរជាជួរ តោងគ្នានឹងគ្នា អ្នកដើរមុន ក៏មើលមិនឃើញ អ្នកដើរកណ្ដាល ក៏មើលមិនឃើញ អ្នកដើរក្រោយ ក៏មើលមិនឃើញ ដូចម្ដេចមិញ ម្នាលវាសេដ្ឋៈ ភាសិតរបស់ពួកព្រាហ្មណ៍ អ្នកត្រៃវិជ្ជា ក៏មានទំនងឧបមេយ្យ ដូចជាមនុស្សខ្វាក់ ដើរជាជួរ អ្នកដើរមុន ក៏មើលមិនឃើញ អ្នកដើរកណ្ដាល ក៏មើលមិនឃើញ អ្នកដើរក្រោយក៏មើល មិនឃើញដូច្នោះដែរ។”

ចំណុចដ៏គួរឲ្យចាប់អារម្មណ៍មួយទៀត ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានសម្ដែង គឺភាពមិនមានប្រសិទ្ធិភាពនៃការពឹងពាក់ទៅលើវត្ថុ ឬអ្នកដទៃ ដើម្បីទទួលបានជំនួយផ្នែកស្មារតីនិងសម្ភារៈ ដូចមានបង្ហាញនៅក្នុងសំវាទខាងក្រោមនេះ ៖

“ម្នាលវាសេដ្ឋៈ ដូចស្ទឹងអចិរវតីនេះ ពេញប្រៀបដោយទឹកល្មមតែក្អែកទំមាត់ប្រាំងឱនផឹកបាន គ្រានោះមានបុរសអ្នកត្រូវការ

ត្រើយខាងនាយ អ្នកស្វែងរកត្រើយខាងនាយ អ្នកទៅត្រើយខាងនាយ អ្នកចង់ឆ្លងទៅត្រើយខាងនាយ បានមកដល់ (ស្ទឹងនោះ) ក៏យកខ្សែដ៏មាំ មកចងដើមដៃទៅខាងក្រោយ (ចងស្លាបសេក) យ៉ាងខ្ជាប់ទុកនៅត្រើយខាងអាយ ម្នាលវាសេដ្ឋៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច បុរសនោះនឹងចេញពីត្រើយខាងអាយនៃស្ទឹងអចិរវតី ទៅត្រើយខាងនាយ តើបានឬទេ៕"

"បពិត្រ ព្រះគោតមដ៏ចំរើន មិនបានទេ៕"

ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ គឺជំរុញឲ្យយើងស្គាល់សភាវធម៌ទាំងឡាយទៅតាមសភាពពិត តាមរយៈការធ្វើសមាធិភាវនាផ្ទាល់របស់យើង៕

តើព្រះពុទ្ធសាសនាជាលទ្ធិមិនជឿអាទិទេពឬ?

ព្រះតេជគុណ ញាណបោនិកៈ ដើមកំណើតអាឡឺម៉ង់ ជាព្រះថេរៈ និងជាសង្ឃបណ្ឌិត មានចំណេះដឹងជ្រៅជ្រះ គង់នៅក្នុងប្រទេសសិរីលង្កា នៅក្នុងសៀវភៅរបស់ព្រះអង្គ ដែលមានចំណងជើងថា "ព្រះពុទ្ធសាសនា និងទស្សនៈអាទិទេព" បានពន្យល់ដំណោះស្រាយរបស់ពួកលោកខាងលិច ចំពោះព្រះពុទ្ធសាសនាថាជាសាសនាបដិសេធអាទិទេព ពោលគឺហៅព្រះពុទ្ធ

សាសនា ថាការប្រៀនប្រដៅមួយដែលមិនជឿលើអាទិទេព ទាំងនៅក្នុងសេចក្តីវិនិច្ឆ័យដែលពេញចិត្ត (ដោយបណ្តាអ្នកគិតសេរី អ្នកសនិទាននិយម ជាដើម) ប៉ុន្តែជាញឹកញាប់មានបំណងបន្តុះបង្អាប់ ជាមួយគ្នាដែរ ដូចជាពាក្យថា "គ្មានអាទិទេព" ត្រូវបានគេប្រើថាជាពាក្យនិយាយបង្ខូចធ្វើឲ្យអាប់អោនកេរ្តិ៍ឈ្មោះ។

ព្រះពុទ្ធសាសនា មានតែវិធីមួយគាត់ អាចបកស្រាយថាជាលទ្ធិមិនជឿអាទិទេព គឺត្រឹមតែបដិសេធការកើតមាននៃព្រះអាទិ-ទេព ប្រកបដោយសព្វានុភាព មិនចេះច្យុត ឬក៏ព្រះជាម្ចាស់ដែលជាអ្នកសាង ឬអ្នកបង្កើតឲ្យមានលោក។ ទោះបីជាយ៉ាងណាក៏ដោយ ពាក្យថា "សាសនាមិនជឿអាទិទេព" ជាញឹកញាប់បង្កប់ន័យមិនបង្ហាញការបន្តុះបង្អាប់ឲ្យឃើញត្រង់ ឬការពោលបន្តុះបង្អាប់ចំៗ ដែលតាមវិធីណាក៏ដោយ ត្រូវមានអនុវត្តនៅក្នុងឱវាទរបស់ព្រះសម្មាសម្ពុទ្ធ។

អ្នកទាំងឡាយណាដែលប្រើពាក្យ "សាសនាមិនជឿលើអាទិទេព" តែងតែភ្ជាប់ពាក្យនេះទៅនឹងលទ្ធិសម្ភារៈនិយម ដែលគ្មានអ្វីជ្រៅជ្រះ ជាងលោកនេះនៃកាយល់ និងសុកមង្គលបន្តិចបន្តួច ដែលលទ្ធិនេះអាចផ្តល់ឲ្យ។ ព្រះពុទ្ធសាសនាគ្មានការយល់

ដូចលទ្ធិខាងលើនោះទេ។ នៅក្នុងប្រការនេះ ព្រះពុទ្ធសាសនាបានយល់ស្របទៅលើការប្រៀនប្រដៅរបស់សាសនាដទៃទៀត។

អធិប្បាយនេះផ្ដល់ឲ្យយើង នូវការប្រាប់ឲ្យដឹងច្បាស់ពីគ្រោះថ្នាក់នៃទម្លាប់ដាក់ព្រះពុទ្ធសាសនា ទៅក្នុងជំពូកណាមួយដែលមានស្រាប់ ជាជាងពិនិត្យមើលសាសនានេះទៅតាមសភាពពិត។ នេះគឺជាចំណុចតែមួយគត់ នៅក្នុងចំណោមការបកស្រាយខុសបែបនេះជាច្រើន ជាពិសេសនៅក្នុងសង្គមលោកខាងលិច។ គោលបំណងបែបនេះ មិនត្រឹមតែលាក់អត្ថន័យពិតនៃពាក្យប្រៀនប្រដៅដើម ថែមទាំងបង្ហាញផ្លូវខុសដល់អ្នកអាន អ្នកស្ដាប់ដោយមធ្យោបាយជាច្រើន។

**ទស្សនៈព្រះពុទ្ធសាសនាអំពីទេវតា**

នេះគឺជាការបែងចែកឲ្យដាច់ដ៏សំខាន់ ដែលធ្វើឡើងរវាងពាក្យ "ព្រះអាទិទេព" និងពាក្យ "ទេវតា"។

អាទិទេពជាពាក្យប្រែមកពីពាក្យបាលីថា "ឥស្សរៈ" ពាក្យថាអាទិទេពនេះ តាមដំណើរដើមសំដៅយក "ទេវតាមុនបង្អស់"[៣]

---

៣ ពាក្យសន្មត់ ហៅអនុត្តរបុគ្គល ដែលគេជឿសម្គាល់ទុកថា ជាព្រះ ជាអ្នក បង្កើតទឹកដី និងសត្វលោក ជាអ្នករក្សាការពារឲ្យសុខទុក្ខដល់មនុស្សលោក។

ឬក៏ "អ្នកបង្កើតលោក"។ ពាក្យថា "ទេវតា" ជាពាក្យប្រែមកពីពាក្យ "ទេវតៈ" ដែលជាធម្មតា គេដឹងថាជាអមនុស្សដែលជាទិព្វ។ ទោះបីជាពុទ្ធសាសនិកមិនបដិសេធថា មានឋាន ឬកម្រិតចិត្តនៅក្នុងសកលលោកនេះ តាមមធ្យោបាយមួយចំនួន ទោះបីមិនចាំបាច់នៅក្នុងគ្រប់ប្រការទាំងអស់ ដែលថាខ្ពង់ខ្ពស់ជាងពិភពនៅលើផែនដី និងចិត្តរបស់មនុស្សលោកសាមញ្ញ។

បើតាមការបង្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា ទោះបីភព ឬភូមិដែលប្រសើជាង ក៏គោរពតាមច្បាប់នៃការប្រែប្រួល និងមិនទៀង ដូចពិភពលោកដែលធ្លាប់ដឹង ធ្លាប់ឮរបស់យើងផ្ទាល់។ ពួកទេវតា ព្រះព្រហ្មទាំងឡាយដែលរស់នៅក្នុងភពបែបនេះ នៅក្នុងកម្រិតខុសគ្នាអាចមានអំណាចជាងមនុស្សលោក សប្បាយជាង និងមានអាយុវែងជាងមនុស្សលោក ប៉ុន្តែសំខាន់មិនមានបញ្ញាជាងមនុស្សលោកនោះទេ។ ទោះបីយើងហៅថាព្រះឥន្ទ ទេវតា ឬទេពអប្សរក៏ដោយ ក៏មានសារៈសំខាន់តិចតួច ពីព្រោះមិនគួឲ្យជឿថាព្រះឥន្ទ ព្រះព្រហ្ម ទេពអប្សរ និងពួកទេព្តាទាំងនោះ ហៅខ្លួនគេនូវឈ្មោះទាំងនេះដែរទេ។

# ព្រះពុទ្ធសាសនា និងការបែងចែកវណ្ណៈសង្គម

នៅក្នុងបរិបទនេះ ការបែងចែកវណ្ណៈសំដៅយកការចែកឋានៈ ដែលធ្វើឡើងដោយមនុស្សក្នុងចំណោមមនុស្សជាតិ ដោយផ្អែកទៅលើ ពណ៌សម្បុរស្បែក ភាសា ពូជសាសន៍ សាសនា ភេទ និងជំនឿនយោបាយដែលទទួលខុសត្រូវ មិនអាចមាននរណាហ៊ានជំទាស់ទៅលើការធ្វើទុក្ខបុកម្នេញ ការរើសអើង និងការសម្លាប់រង្គាល តាមរយៈប្រវត្តិសាស្ត្រមនុស្សជាតិ។ គ្មានគោលបំណងណាមួយនឹងត្រូវធ្វើឡើង ដើម្បីស្វែងរកឫសគល់នៃការបែងចែកវណ្ណៈនៃការរើសអើងបែបនេះ នៅក្នុងពិភពលោកសម័យបច្ចុប្បន្ននេះទេ កិច្ចការនេះនឹងទាក់ទងជាមួយវិធីដែលព្រះសម្មា-សម្ពុទ្ធបានដោះស្រាយការបែងចែកវណ្ណៈសង្គម។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា ការស្វែងរកការសិក្សានេះ អាចជួយយើងទទួលបានចំណេះដឹង អំពីការបែងចែកវណ្ណៈសង្គមសម័យទំនើប ដែលកាន់តែស្មុគស្មាញថែមទៀត។

នៅសម័យពុទ្ធកាល ក៏ដូចសព្វថ្ងៃនេះដែរ សង្គមឥណ្ឌាបានបែងចែកចាក់ឫសយ៉ាងជ្រៅជាវណ្ណៈបួន ហៅថា “វណ្ណៈ” គឺព្រាហ្ម

ណ៌ ខត្តិយឬក្សត្រ វេស្សៈ និងសូទ្រៈ (វណ្ណៈអប់រំនិងបង្ហាត់បង្រៀនខាងវិជ្ជាសាសនា វណ្ណៈគ្រប់គ្រងដឹកនាំ វណ្ណៈកសិករនិងអ្នកជំនួញ និងវណ្ណៈអ្នកបម្រើគេ)។ ការកើតឡើងពាក្យគន្លឹះដើមពីរបីពាក្យនឹងផ្តល់ឲ្យយើងនូវពន្លឺ ដើម្បីដោះស្រាយបញ្ហានេះឲ្យកាន់តែមានន័យ។ ពាក្យគន្លឹះទាំងនេះមានដូចជា ជាតិ (ពូជ-សាសន៍) វណ្ណៈ (ពណ៌សម្បុរ) ទាសៈ (អ្នកបម្រើ)។ តាមដំណើរដើមនៃពាក្យគន្លឹះទាំងនេះ យើងអាចសន្និដ្ឋានបានថាប្រព័ន្ធវណ្ណៈឥណ្ឌា (ដូចការបែងចែកវណ្ណៈសង្គមដទៃទៀតជាច្រើនផងដែរ) គឺផ្អែកលើពូជសាសន៍ ពណ៌សម្បុរ និងកត្តាសេដ្ឋកិច្ច។ កាន់តែភ្ញាក់ផ្អើលថែមទៀតនោះ មិនត្រឹមតែប្រជាជនឥណ្ឌាសម័យបុរាណទេ ថែមទាំងភាគច្រើននៃប្រជាជនឥណ្ឌាសម័យទំនើប ប្រកាន់គំនិតថា ប្រព័ន្ធវណ្ណៈ គឺព្រះអាទិទេពជាអ្នកបែងចែកស្រាប់ៗ និងមិនអាចតវ៉ាបាន។ បើតាមពួកគេកើតមកជាមនុស្ស យើងគ្មានសិទ្ធិអ្វីទៅប្រឡូងប្រណាំង ឬផ្លាស់ប្តូរការបែងចែកវណ្ណៈដែលមានស្រាប់នោះទេ ពីព្រោះការបែងចែកវណ្ណៈទាំងនេះ ជាការតាក់តែងរបស់ព្រះអាទិទេព។ សាសនានានាភាគច្រើនបានប្រើប្រាស់គំនិតរួមគ្នាដោយមធ្យោបាយតែមួយ ឬមធ្យោបាយមួយផ្សេងទៀត។

ព្រះពុទ្ធសាសនាគឺជាសាសនាទីមួយ និងជាសាសនាតែមួយគត់ ដែលបានរិះគន់ប្រព័ន្ធវណ្ណៈដែលមានអាយុកាលរាប់សតវត្សមកហើយនៅក្នុងប្រទេសឥណ្ឌា។ ព្រះសម្មាសម្ពុទ្ធទ្រង់បានសម្ដែងថា ការបែងចែកវណ្ណៈមនុស្ស ដែលថាអាទិទេពជាអ្នកបែងចែកស្រាប់ៗនេះគឺមិនពិតទេ គឺការបែងចែកវណ្ណៈនេះពិតជាធ្វើឡើងដោយមនុស្ស ហើយគ្មានមូលដ្ឋានវិទ្យាសាស្ត្រទេ។ ការបែងចែកវណ្ណៈទាំងអស់នេះ គឺសំខាន់ប្រព្រឹត្តទៅតាមការព្រមព្រៀង ហើយមិនមែនដាច់ខាត ឬតែមួយគ្មានការកែប្រែនោះទេ។ នៅក្នុងឱកាសជាច្រើន ព្រះសម្មាសម្ពុទ្ធបានបញ្ជាក់ថា មនុស្សលោកទាំងអស់មានប្រភេទតែមួយ ហើយដូច្នេះ គោលបំណងណាមួយចង់បង្កើតការបែងចែកវណ្ណៈខុសៗគ្នា ក្នុងសង្គមមនុស្ស ដោយផ្អែកលើវណ្ណៈ ជាតិ សាសនា ជាដើម គឺពិតជាមិនពិត ហើយធ្វើឡើងដោយមនុស្សគឺគ្មានអាទិទេពណាជាអ្នកបែងចែកទេ។ ប្រសិនបើក្រុមដែលមានឥទ្ធិពលណាមួយ ព្យាយាមដណ្ដើមយកសក្ដិធំជាងគេ លើក្រុមទន់ខ្សោយ ហើយរាំងពួកគេមិនឲ្យទទួលបានសិទ្ធិស្មើគ្នា និងសេរីភាព នេះគឺជាការរំលោភបំពានលើសិទ្ធិមនុស្ស។

ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងបញ្ជាក់ ដោយបង្ហាញការព្រមព្រៀងជាប្រវត្តិសាស្ត្រ ត្រឹមត្រូវតាមសីលធម៌ជាអាជីព ស្របតាមច្បាប់ និងតាមជីវសាស្ត្រថា ការបែងចែកវណ្ណៈទាំងនេះគឺមិនអាចទទួលយកបាន និងគ្មានមូលដ្ឋានណាមួយបញ្ជាក់ឲ្យបានច្បាស់លាស់ផងទេ។

នៅសម័យថ្ងៃមួយ ព្រះពុទ្ធទ្រង់បានត្រាស់សម្តែងប្រារព្ធចំពោះព្រាហ្មណ៍ពីរនាក់ (វាសេដ្ឋៈនិងភារទ្វាជៈ) និងពន្យល់អំពីដើមកំណើតនៃប្រព័ន្ធបែងចែកវណ្ណៈ ដែលគេឃើញមាននៅក្នុងប្រទេសឥណ្ឌា។ គ្រានោះ ព្រះពុទ្ធមិនត្រឹមតែ បានផ្តល់ឲ្យយើងនូវរូបភាពច្បាស់មួយ អំពីប្រវត្តិនៃប្រព័ន្ធបែងចែកវណ្ណៈនៃប្រជា-ជនឥណ្ឌា ថែមទាំងបានរំលឹកយើងថា ប្រព័ន្ធបែងចែកវណ្ណៈគឺជាការបង្កើតរបស់មនុស្សដោយគ្មានការសង្ស័យ ជាជាងការបង្កើតឡើងដោយព្រះអាទិទេព។

ដើម្បីបង្ហាញការព្រមព្រៀងគ្នាផ្នែកជីវសាស្ត្រ ព្រះសាស្តាបានពន្យល់ពីរបៀបដែលពិបាករកហេតុផល សម្រាប់ការចែកប្រភេទរវាងមនុស្ស។ យើងអាចរកភស្តុតាងសមហេតុសមផលនៅក្នុងប្រភេទផ្សេងៗរបស់សត្វ ដើម្បីបញ្ជាក់ឲ្យឃើញថា ពួកវា

ជាប្រភេទសត្វខុសៗគ្នា។ ប្រសិនបើយើងមើលថនិកសត្វ និងបក្សី លិង្គភេទរបស់សត្វទាំងនេះមានជាតិផ្សេងៗគ្នា។ ដូចគ្នានេះដែរ សត្វល្អិតនិងសត្វពពួកល្មូន លិង្គភេទរបស់សត្វទាំងនេះមានជាតិផ្សេងៗគ្នា។ សូម្បីតែស្មៅនិងរុក្ខជាតិទាំងឡាយ លិង្គភេទក៏មានជាតិផ្សេងៗគ្នាដែរ។ នៅក្នុងប្រភេទសត្វសំខាន់ៗជាច្រើនផងដែរ យើងអាចឃើញមានអនុប្រភេទជាច្រើន ជាតួយ៉ាងដូចជា សត្វឆ្មា និងសត្វឆ្កែ លិង្គភេទរបស់សត្វឆ្មានិងសត្វឆ្កែមានជាតិផ្សេងគ្នា ហើយលិង្គភេទរបស់សត្វទាំងពីរនេះមានជាតិផ្សេងគ្នាពីថនិកសត្វ។ ប៉ុន្តែគ្មានកស្តុតាងផ្នែកជីវិសាស្ត្រណាមួយដែលបង្ហាញថាមនុស្សមានភាពខុសគ្នា ហេតុនេះហើយ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងបញ្ជាក់ថា ការបែងចែកវណ្ណៈណាមួយ រវាងមនុស្សដែលធ្វើឡើងដោយអាទិទេពគឺមិនពិតនោះទេ គឺពិតជាធ្វើឡើងដោយមនុស្សហ្នឹងឯង។

ដូចគ្នានេះដែរ តាមទស្សនៈនៃច្បាប់ មនុស្សគ្រប់រូបគឺមានសិទ្ធស្មើគ្នា។ ពណ៌សម្បុរ វណ្ណៈ ឋានៈ ឬការបែងចែកវណ្ណៈដែលមានស្រាប់ដទៃទៀត គឺមិនមានភាពខុសគ្នាទេ។ ជាងនេះទៅទៀត គ្មានការបែងចែកវណ្ណៈណាមួយ ដែលបានរៀបរាប់ខាងលើ

តាមវិធីណាក៏ដោយ ជាឧបសគ្គដល់ការសម្រេចគុណធម៌កម្រិតខ្ពស់នៃការអភិវឌ្ឍខាងប្រាជ្ញាស្មារតីឡើង។ ទន្ទឹមនឹងនេះ អសីលធម៌នៅក្នុងការរស់នៅ ធ្វើឲ្យមនុស្សអន់ថយក្នុងការអភិវឌ្ឍខាងប្រាជ្ញាស្មារតី ដោយមិនគិតពីវណ្ណៈ ឬឋានៈនៅក្នុងសង្គមរបស់គេនៅវិញ។

ព្រះពុទ្ធទ្រង់សម្តែងថា មុខរបរមិនគួរត្រូវបានគេចាត់ទុកថាខ្ពស់ ឬទាប ព្រោះមុខរបរទាំងនោះមិនធ្វើឲ្យខូចសង្គម។ ព្រះអង្គបានសម្តែងផងដែរថា គ្មានមុខរបរណាត្រូវបានគេរក្សាទុក ឬកាន់កាប់ផ្តាច់មុខ ដោយក្រុមមនុស្សពិសេសណាមួយនោះទេ។ ប្រសិនបើនរណាម្នាក់មានគុណវឌ្ឍិគ្រប់គ្រាន់ និងបានទទួលការហ្វឹកហ្វឺនសម្រាប់ការងារពិសេសណាមួយនោះ ពួកគេគួរត្រូវបានផ្តល់ការងារនោះឲ្យធ្វើ ដោយមិនគិតពីវណ្ណៈ ឬឋានៈក្នុងសង្គមរបស់ពួកគេឡើយ។

ការរិះគន់ដ៏ខ្លាំងខ្លានេះ ប្រឆាំងនឹងប្រព័ន្ធបែងចែកវណ្ណៈរបស់ពួកហិណ្ឌូបានប្រកួតប្រជែងជាមួយបណ្តាជំនឿ នាពេលបច្ចុប្បន្ន និងមានឥទ្ធិពលក្នុងសម័យពុទ្ធកាល ប៉ុន្តែមិនត្រឹមតែព្រះសម្មាសម្ពុទ្ធទ្រង់ទេសនាពន្យល់ តបនឹងប្រព័ន្ធបែងចែកវណ្ណៈ

ប៉ុណ្ណោះទេ ថែមទាំងបានបង្កើតឡើងដោយជោគជ័យនូវសង្គម ដែលគ្មានការបែងចែកវណ្ណៈមួយៗ គំរូដ៏ល្អនៃការបង្កើតនេះ គឺ គណសង្ឃ (មហាសង្ឃ)។ ព្រះសម្មាសម្ពុទ្ធទ្រង់បំបួសកុលបុត្រ ណាដែលមានបំណងបដិបត្តិព្រះធម៌ ហើយប្រតិបត្តិតាមជីវិតអប់រំ ផ្លូវចិត្ត។ គណសង្ឃ ឬមហាសង្ឃនេះរួមមានបុគ្គលទាំងឡាយ មកពីវណ្ណៈសំខាន់ៗទាំងបួន។ ជំនួសឲ្យប្រព័ន្ធបែងចែកវណ្ណៈ របស់ពួកហិណ្ឌូ ព្រះពុទ្ធទ្រង់បង្កើតសង្គមមួយដែលមានបួន ប្រភេទថ្មីមួយ គឺ ភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា។ អ្នកទាំង ឡាយ ដែលមានបំណងត្រូវបានទទួលដោយមិនគិតពីឋានៈសង្គម ប្រពៃណីរបស់ពួកគេ ហើយទាំងអស់គ្នាត្រូវបានគោរពស្មើៗគ្នា។

ដូចនៅក្នុងសង្គមផ្សេងទៀតជាច្រើន នៅក្នុងប្រទេសឥណ្ឌា ឋានៈស្ត្រីគួរឲ្យសោកសៅយ៉ាងខ្លាំង ពិសេសសម្រាប់ពួកហិណ្ឌូ ដែលមានជំនឿថា ស្ត្រីនាំមកនូវសំណាងមិនល្អ និងអពមង្គលមក ឲ្យគ្រួសារ ហើយជារឿយៗ តែងតែចាត់ទុកស្ត្រីដូចសត្វពាហនៈ។ ហេតុដូច្នេះ មានការដាក់កំហិតដ៏សាហាវឃោរឃៅ ប្រឆាំង សមាជិកជាស្ត្រីភេទនៅក្នុងសង្គម។ ជាតួយ៉ាង មានការប្រតិបត្តិ តាម "សត្តិ" ពោលគឺនៅពេលដែលស្វាមីស្លាប់ ភរិយាត្រូវគេបង្ខំ

ឲ្យលោតចូលភ្លើង ហើយត្រូវគេដុតទាំងរស់។ ប្រសិនបើ ពួកគេបដិសេធមិនធ្វើដូចនេះ ពួកគេត្រូវដាក់ឲ្យនៅដាច់ដោយឡែកតែឯកឯង ហើយចាត់ទុកជាមនុស្សអាក្រក់និងអភ័ព្វ។ ទំនៀមទម្លាប់ទីពីរគឺរឹតតែអាក្រក់ទៅទៀត គឺនៅពេលដែលស្ត្រីទាំងឡាយនៅក្មេង បានភ្ជាប់ពាក្យជាមួយបុរសណា ដែលមានអាយុស្មើគ្នា។ ប្រសិនបើមានរឿងហេតុអ្វីកើតឡើងចំពោះកូនប្រុស ប្រសិនបើគេស្លាប់ ឬក្លាយជាមានកាយ ឬចិត្តវិកល ស្ត្រីនោះត្រូវគេបង្ខំឲ្យនៅលីវអស់មួយជីវិត ឬក៏បូជាជីវិតរបស់ពួកគេ ដើម្បីបម្រើថែរក្សាប្ដីអភ័ព្វនោះ។ ទោះបីទំនៀមទម្លាប់ទាំងនេះមិនទូទៅ ដូចដែលធ្លាប់មាន ក៏ទំនៀមទម្លាប់ទាំងនេះនៅតែអនុវត្ត នៅក្នុងសង្គមឥណ្ឌាជនបទ។

សូម្បីសព្វថ្ងៃនេះ ស្ត្រីមិនត្រូវបានគ្រួសារទទួលស្វាគមន៍ដូចបុរសនៅឡើយទេ។ នៅពេលដែលកូនប្រុសកើតមក ឪពុកម្ដាយសប្បាយរីករាយ ហើយបង្ហាញក្ដីសប្បាយរីករាយរបស់ពួកគេដោយបរិច្ចាគម្ហូបអាហារ មានក្លិនក្រអូបទៅព្រះវិហារ និងទៅសាច់ញាតិមិត្តភក្ដិ។ ប៉ុន្តែ ប្រសិនបើកូនដែលកើតមកត្រឡប់ទៅជាស្រីវិញ ពួកគេតូចចិត្តនិងខកចិត្ត។ ហេតុផលអ្វីក៏ដោយ

ដែលពួកគេផ្ដល់ដើម្បីបញ្ជាក់សេចក្ដីសំអាងរបស់ពួកគេ ក៏ព្រះពុទ្ធសាសនាបដិសេធសេចក្ដីសំអាងទាំងនេះថា ជាជំនឿងងឹតងងល់ គ្មានហេតុផល ដោយហេតុថាស្ត្រីមានឋានៈស្មើគ្នាដើម្បីរស់ ហើយការធ្វើវិភាគទានរបស់ពួកគេចំពោះសង្គមគឺរកអ្វីមកប្រៀបស្មើពុំបានទេ ហេតុនេះព្រះពុទ្ធសាសនាបញ្ជាក់ថា ការរើសអើងណាមួយប្រឆាំងនឹងស្ត្រីភេទ គឺជាការរំលោភបំពានលើសិទ្ធិមនុស្ស។ ព្រះពុទ្ធសាសនាបានយល់ពីសារៈសំខាន់នៃស្ត្រីភាពនិងកិច្ចប្រឹងប្រែងមិនចេះនឿយហត់របស់ពួកគេ ព្រមទាំងការរួមវិភាគទានចំពោះសមិទ្ធផលទាំងឡាយរបស់មនុស្ស ហេតុនេះហើយ មាតានិងបងប្អូនស្រីត្រូវបានគេឲ្យតម្លៃខ្ពស់និងគោរពនៅក្នុងសង្គមកាន់ព្រះពុទ្ធសាសនាទាំងអស់ ជាង២៥៥០ឆ្នាំមកហើយ។ ជាអកុសល នៅមានសង្គមជាច្រើនដែលមានឈ្មោះថាអារ្យធម៌ខ្ពង់ខ្ពស់ ហាក់នៅមានទម្រង់ខ្លះនៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ទោះបីដោយនិយាយតាមចំណែកដែល ពាក់ព័ន្ធថាស្ត្រីរបស់ពួកគេមានសេរីភាពច្រើនជាង ស្ត្រីជាច្រើនទៀតនៅតាមតំបន់នានាលើពិភពលោក។

ដោយឃើញមាន ការបែងចែកវណ្ណៈទាំងនេះរវាងមនុស្សជាតិ ព្រះពុទ្ធទ្រង់សម្តែងម្តងហើយម្តងទៀតថា លក្ខណៈវិនិច្ឆ័យតែមួយគត់ចំពោះ ឋានៈសង្គមខ្ពស់ឬទាប គឺតាមកម្មរបស់ខ្លួនជាងជាតិ វណ្ណៈ ជាដើម (កម្មុនា វាសលោ ហោតិ កម្មុនា ហោតិ ព្រាហ្មណោ)។

ទស្សនៈព្រះពុទ្ធសាសនា អំពីការបែងចែកវណ្ណៈសង្គមគឺមនុស្សជាតិមានប្រភេទតែមួយ ហើយដែលថាការបែងចែកវណ្ណៈណាមួយរវាងមនុស្ស ហេតុនេះគឺជាសំខាន់មិនពិតនិងប្រឌិតឡើងដោយមនុស្ស។

# ព្រះពុទ្ធសាសនា និងសង្គមវប្បធម៌ចម្រុះ

មិនដូចសម័យបុរាណ ពិភពលោកសម័យបច្ចុប្បន្នកំពុងក្លាយទៅតូចទៅៗ ដោយសារបច្ចេកវិទ្យាទំនើបជាមួយមធ្យាបាយដឹកជញ្ជូនកាន់តែរហ័ស និងបណ្តាញផ្តល់ពត៌មានទ្រង់ទ្រាយធំកាន់តែមានឥទ្ធិពលខ្លាំងឡើង។ ពីជ្រុងម្ខាងនៃពិភពផែនដីនេះទៅជ្រុងម្ខាងទៀត គឺជាបញ្ហានៃការធ្វើដំណើរដែលមានរយៈពេលពីរបីម៉ោង។ សង្គមនានានៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ ឧស្សាហកម្មកំពុងក្លាយជាពូជសាសន៍ចម្រុះ ដែលកំពុងកើនឡើង។ ជាលទ្ធផល ទីកន្លែងសក្ការៈបូជាខុសៗគ្នាជាច្រើន ដូចជា វិហារគ្រឹស្តសាសនា វិហារសាសនាហិណ្ឌូ វិហារសាសនាឥស្លាម វិហារសាសនាសិខ និងព្រះវិហារពុទ្ធសាសនា គេអាចឃើញមាននៅក្នុងតំបន់តែមួយ និងកំពុងក្លាយជារឿងសាមញ្ញទៅហើយ។ ជាការធម្មតាផងដែរ ដែលឃើញមានក្រុមអង្គការជំនឿចម្រុះ និងអន្តរជំនឿ ទទួលយកទាំងអស់មកពិភាក្សានូវបញ្ហាទាំងឡាយ ស្តីពីក្តីកង្វល់ទៅវិញទៅមក ដូចជា សន្តិភាពពិភពលោក គ្រោះទុរភិក្ស ជនរងគ្រោះដោយសារសង្គ្រាមជាដើម។ នៅក្នុងជំពូកនេះ

ខ្ញុំសូមលើកយកមកពិភាក្សានូវទស្សនៈដ៏មានប្រយោជន៍របស់ព្រះពុទ្ធសាសនា ដែលរួមវិភាគទានចំពោះសាមគ្គីភាពរបស់មនុស្ស។

ព្រះពុទ្ធសាសនាពេញចិត្តយ៉ាងខ្លាំង ចំពោះគោលបំណងណាមួយ ដើម្បីបង្កើតភាពជារបស់តែមួយក្នុងចំណោមមនុស្សជាតិ។ ខ្ញុំចង់ចាំពេលមួយ សមាជិកម្នាក់នៃជំនឿមួយផ្សេងទៀតបានផ្តល់បាឋកថាមួយស្តីពី "ភាពជារបស់តែមួយរបស់ព្រះអាទិទេព"។ មានសមាជិកជាច្រើនមកពីជំនឿផ្សេងៗ ចូលរួមក្នុងអង្គប្រជុំនេះ ស្តីអំពីក្រុមអន្តរសាសនា Wolverhampton ហើយដោយសារតែខ្ញុំជាតំណាងព្រះពុទ្ធសាសនាតែមួយអង្គគត់ ពួកគេបានស្នើរសុំឲ្យនិយាយ អំពីអ្វីដែលខ្ញុំបានគិតអំពីបាឋកថានោះ។ ខ្ញុំបានប្រាប់ពួកគេថា នៅពេលដែលខ្ញុំពោលសរសើរគោលបំណងចង់រួបរួមឯកភាពរបស់ព្រះជាម្ចាស់ ដូចគ្នានេះដែរ ពុទ្ធសាសនិកផ្តល់អាទិភាពទៅលើឯកភាព និងភាពជារបស់តែមួយរបស់មនុស្ស ពីព្រោះយើងរស់នៅក្នុងសង្គម ដែលដាច់ឆ្ងាយពីគ្នា ហើយជាអ្នកដែលឃើញព្រឹត្តិការណ៍កើតឡើង ចំពោះការរើសអើង និងការធ្វើទុក្ខបុកម្នេញ ដោយសារតែការបែងចែកទាំងនេះ។

ប្រសិនបើយើងក្រឡេកមើល ទស្សនវិជ្ជាព្រះពុទ្ធសាសនា យើងអាចមើលឃើញថា ព្រះសម្មាសម្ពុទ្ធបានបង្រៀនប្រដៅអំពីមេត្តាធម៌ និងការចូលចិត្តធ្វើល្អ មិនត្រឹមតែចំពោះមនុស្សប៉ុណ្ណោះទេ ថែមទាំងចំពោះសត្វលោកទាំងអស់ផងដែរ។ ធម៌ទាំងឡាយ៤យ៉ាង (ចត្តារោ ព្រហ្មវិហារ) គឺជាឧទាហរណ៍ដ៏ល្អសម្រាប់ការបង្រៀនប្រដៅនេះ។ ព្រហ្មវិហារធម៌បួននេះគឺការរាប់អានដោយស្និទ្ធចំពោះមនុស្សសត្វទាំងអស់ (ករុណា) សេចក្តីត្រេកអរចំពោះមនុស្សសត្វដែលបានសុខ (មុទិតា) និងការតាំងចិត្តជាកណ្តាលចំពោះមនុស្សសត្វ (ឧបេក្ខា)។

ព្រះពុទ្ធសាសនាបង្រៀនយើង ឲ្យចម្រើនសេចក្តីរាប់អាន (មេត្តា) និងសេចក្តីសន្តោសប្រោសប្រណីឲ្យឈានដល់កម្រិតខ្ពស់បំផុត ដោយមិនគិតពីការបែងចែក ដែលមានស្រាប់រវាងសត្វលោក ដូចជា មនុស្ស សត្វ ជាដើម។

លើសពីនេះទៅទៀត ឧវាទទាំងនេះជារឿយៗត្រូវបានប្រតិបត្តិជាការភាវនាជាប្រក្រតី។ សូត្រទាំងឡាយបានពន្យល់អំពីរបៀបប្រតិបត្តិដូច្នេះថា៖ “ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃដែលមានចិត្តប្រកបដោយមេត្តា ផ្សាយទៅទិសខាងកើត បន្ទាប់មកទៅ

កាន់ទិសខាងត្បូង បន្ទាប់មកទិសខាងលិច រួចហើយទៅកាន់ទិសខាងជើង បន្ទាប់មកទិសខាងលើ និងទិសខាងក្រោម និងគ្រប់ទិសានុទិសទាំងអស់ ព្រមទាំងគ្រប់ទីកន្លែងទាំងអស់ ដោយកំណត់ខ្លួនឯងជាមួយសព្វសត្វទាំងអស់ថា "អាត្មាអញជាអ្នកផ្សាយមេត្តាទៅកាន់ពិភពលោកទាំងមូល ដោយចិត្តប្រកបដោយមេត្តា ដោយចិត្តទូលំទូលាយ ដោយចិត្តចម្រើនមិនជាប់ជំពាក់ រួចរំដោះពីទោសៈ និងព្យាបាទ។" យ៉ាងណាមិញ ករុណាក្តី មុទិតាក្តី ឧបេក្ខាក្តី ក៏មានវិធីផ្សាយទៅដោយអាការៈ ដូចមេត្តានោះដែរ។

ព្រះពុទ្ធសាសនាបង្រៀនយើង ពីរបៀបយល់ដឹងសភាវៈពិតនៃព្រះធម៌ និងពីរបៀបធ្វើចិត្តរបស់យើងឲ្យបរិសុទ្ធ។ ប្រសិនបើការបង្រៀនណាមួយ យល់ស្របជាមួយទ្រឹស្តីគោលនេះ ហើយចូលរួមធ្វើវិភាគទានមានប្រយោជន៍ ដើម្បីធ្វើចិត្តឲ្យរីកចម្រើនអ៊ីចឹងទើបព្រះពុទ្ធសាសនាកោតសរសើរ និងឲ្យតម្លៃខ្ពស់ទៅលើពាក្យប្រៀនប្រដៅបែបនេះ ដោយមិនគិតពី ពណ៌សម្បុរ ឬប្រភេទរបស់ឱវាទទាំងនោះ។ ការធ្វើចិត្តរបស់យើងឲ្យបរិសុទ្ធនៅទីនេះមានន័យថា លះលោភៈ ទោសៈ និងមោហៈ ដែលតាំងនៅជាប់ជាយូរមកហើយ ឲ្យចេញពីចិត្ត និងហឫទ័យរបស់យើង។ ទោះបីជា

ពុទ្ធសាសនិកជនមិនយល់ស្រប ជាមួយពាក្យប្រៀនប្រដៅមួយចំនួន ពីព្រោះពាក្យប្រៀនប្រដៅទាំងនោះបង្វែរទិសដៅចេញពីការពិត ព្រះពុទ្ធសាសនាក៏នៅតែអញ្ជើញពួកគេ ដោយមានចិត្តចង់ជួយ ឲ្យគិតម្តងហើយម្តងទៀត និងកែតម្រូវឡើងវិញ នូវទ្រឹស្តីរបស់ពួកគេៗ ដោយសារតែព្រះពុទ្ធសាសនាពិតជាទាក់ទងទៅនឹងការពិតនៃជីវិត សាសនានេះផ្តល់ការយកចិត្តទុកដាក់តិចតួចទៅលើការតឹងរឹងមួយចំនួន ដែលជាធម្មតាទទួលយកថាជាការតាក់តែងរបស់ព្រះអាទិទេព ជាតួយ៉ាង ការតឹងរឹងទាក់ទងទៅនឹងម្ហូបអាហារ សំលៀកបំពាក់ និងការប្រតិបត្តិក្នុងសាសនា។

ព្រះពុទ្ធសាសនាផ្តល់យោបល់ប្រាកដនិយមថា បើមិនធ្វើឲ្យប៉ះពាល់ដល់ការអភិវឌ្ឍប្រាជ្ញាស្មារតី និងមិនធ្វើឲ្យប៉ះពាល់ដល់សង្គម គេអាចរៀបចំឲ្យត្រឹមត្រូវនូវទម្លាប់បរិភោគរបស់គេ និងភាពចាំបាច់សំខាន់ៗផ្សេងទៀត ដើម្បីឲ្យស្របទៅនឹងកត្តាភូមិសាស្ត្រ និងអាកាសធាតុ។ ប៉ុន្តែព្រះពុទ្ធសាសនាក៏បានបញ្ជាក់ម្តងហើយម្តងទៀត អំពីការធ្វើឲ្យខូចតិចតួចដល់បរិស្ថាន និងការប្រើប្រាស់ និងការវិវាទគ្នាយ៉ាងច្រើន នៅពេលដែលគេប្រើប្រាស់ធនធានធម្មជាតិ។

មិនដូចកន្លែងសក្ការៈបូជារបស់សាសនាដទៃទៀតទេ វត្តអារាមព្រះពុទ្ធសាសនាបើកទូលាយសម្រាប់មនុស្សគ្រប់រូប ហើយពុទ្ធសាសនិកពិតជាមានបំណងចង់ចូលរួម ជាមួយអ្នកកាន់សាសនាដទៃយូរអង្វែង រហូតដល់ហេតុដែលបណ្តាលឲ្យធ្វើអ្វីមួយនៅតែមិនធ្វើឲ្យប៉ះពាល់ ដល់សាមគ្គីភាពរបស់មនុស្សជាតិ។ ព្រះបាទអសោក ដែលជាពុទ្ធសាសនូបត្ថម្ភ សោយរាជ្យនៅសតវត្សទី៣ មុនគ.ស ក្នុងប្រទេសឥណ្ឌា ហើយមានព្រះរាជតួនាទីផ្សព្វផ្សាយព្រះពុទ្ធសាសនាទៅកាន់ពិភពលោក បានផ្តល់ការទូន្មានដោយទៀងត្រង់ថា "ប្រសិបើអ្នកមើលងាយជំនឿសាសនាដទៃ គឺអ្នកកំពុងមើលងាយជំនឿសាសនារបស់ខ្លួន"។

# ទស្សនៈព្រះពុទ្ធសាសនា អំពីការថែទាំមនុស្ស ចាស់ជរា

នៅគ្រប់សង្គមទាំងអស់ គេគួរផ្តល់ឲ្យបណ្តាក្រុមមនុស្សគ្រប់វ័យទាំងអស់ នូវសុវត្ថិភាព ការយកចិត្តទុកដាក់ សេចក្តីស្រឡាញ់ ការថែទាំសមរម្យ ព្រមទាំងការប្រព្រឹត្តត្រឹមត្រូវសមគួរត្រឹមតែប៉ុណ្ណោះ យើងអាចចាត់ទុកសង្គមនោះថា មានអារ្យធម៌ឬក៏អភិវឌ្ឍន៍គ្រប់វិស័យទាំងអស់។ ប្រសិនបើតម្រូវការទាំងអស់នោះមិនបានបំពេញឲ្យបានគ្រប់គ្រាន់នោះទេ លទ្ធផលតែងតែក្លាយជាមានរូបភាពនៃអំពើហឹង្សា (ឧ: ចរិតឃោរឃៅ)។ ការស្វែងយល់ពីការសិក្សា ដោយយកចិត្តទុកដាក់ទៅលើប្រធានបទនៃសមាជិកសង្គមដែលគ្មានគុណសម្បត្តិឬអន់ថយ ដូចជា ក្មេងៗនិងមនុស្សចាស់ បានបង្ហាញឲ្យឃើញតាមលទ្ធផលមួយចំនួនថាមនុស្សបែបនេះមានការកើនឡើង។ ជាពិសេសនៅបណ្តាសង្គមឧស្សាហកម្ម ហាក់មានការកើនឡើងដ៏សំខាន់មួយនៅក្នុងករណីទាំងឡាយបែបនេះ។ ដូច្នេះ ចាំបាច់ត្រូវរកឲ្យឃើញឫសគល់នៃបញ្ហា ដែលអាចកើតមានឡើង។ នៅក្នុងជំពូកនេះ ខ្ញុំមានបំណង

លើកយកមកសង្កេតពិនិត្យទស្សនៈព្រះពុទ្ធសាសនា ចំពោះការថែទាំមនុស្សចាស់ជរា។

កម្មវិធី អត្ថបទ និងការសិក្សានានា ដែលទាក់ទងនៅក្នុងបណ្តាញផ្តល់ពត៌មានយ៉ាងច្រើនសន្ធឹកសន្ធាប់ជាញឹកញាប់ណាស់សន្និដ្ឋានការសិក្សារបស់ពួកគេ ជាមួយបណ្តាសំនួរដែលគ្មានចម្លើយ "តើនរណាទទួលខុសត្រូវ ចំពោះមនុស្សចាស់ជរា ដែលគេមិនចង់បាន និងបោះបង់ចោលនៅក្នុងសង្គម? តើកូនរបស់ពួកគេរង្គាភិបាល ឬស្ថាប័នស្ម័គ្រចិត្តនានាឬ?" នរណាក៏ដោយទទួលខុសត្រូវ និងហេតុផលអ្វីក៏ដោយដែលពួកគេសុំឲ្យ ជួយស្វែងរកនៃការសិក្សារបស់ពួកគេមិនយុត្តិធម៌ទេ ទុកឲ្យក្រុមមួយនៃសង្គមត្រូវគេបោះបង់ចោលនិងមិនថែទាំ ពីព្រោះអ្នកទាំងនោះ ជាអ្នកត្រួសត្រាយផ្លូវឲ្យសមិទ្ធផលបច្ចុប្បន្ននេះ ដែលយើងទាំងអស់រីករាយ ចំពោះសមិទ្ធផលនោះដោយខ្លួនយើង ហើយពីមុនពួកគាត់គឺម្តាយឪពុក ដែលគួរឲ្យស្រឡាញ់ និងថែទាំរបស់យើង ព្រមទាំងបានធ្វើអ្វីៗទាំងអស់សម្រាប់យើង នៅពេលដែលយើងមិនទាន់បញ្ចុកចំណី និងដុសលាងសម្អាតខ្លួនដោយខ្លួនឯង។ ហេតុនេះ

ជាកាតព្វកិច្ចរបស់យើង ដើម្បីមើលថែទាំពួកគាត់ នៅពេលដែលពួកគាត់ស្ថិតនៅក្នុងវ័យទន់ខ្សោយ និងត្រូវការជួយ។

ទោះបីជាអាចមានកត្តាសង្គម សេដ្ឋកិច្ច និងវប្បធម៌មួយចំនួន ដែលជាប់ពាក់ព័ន្ធ នៅក្នុងការបង្កើនស្ថានភាពគ្រួសារ និងការផ្លាស់ប្តូរឥរិយាបថចាស់ចោលក៏ដោយ យើងមិនគួរប្រើប្រាស់កត្តាទាំងនោះធ្វើជាការដោះសា ប្រសិនបើការផ្លាស់ប្តូរទាំងនោះរាំងផ្នែកមួយនៃសង្គម ពីការទទួលបាននូវសិទ្ធិរបស់ពួកគេ។ ជាឧទាហរណ៍ ប្រសិនបើនរណាម្នាក់មើលការថែទាំមនុស្សចាស់ជរាចាំបាច់រកឲ្យឃើញដំណោះស្រាយជាទីពេញចិត្ត ចំពោះបញ្ហានោះ។ ហើយប្រសិនបើគ្មានបញ្ហាបែបនេះពីមុនមកទេ ហេតុអ្វីបានជាមានបញ្ហាបែបហ្នឹង នៅពេលបច្ចុប្បន្ននេះ។ នេះគឺជាកង្វល់នៃជំពូកនេះ។ តើព្រះពុទ្ធសាសនាសុំឲ្យមានដំណោះស្រាយណាមួយ ចំពោះបញ្ហាសម័យបច្ចុប្បន្ននេះដែរឬទេ?

នៅក្នុងឱកាសជាច្រើន ព្រះពុទ្ធបានបង្ហាញឲ្យឃើញពីសារៈសំខាន់ របស់មាតាបិតា និងមនុស្សមានវ័យចាស់ដទៃទៀត។ សម័យថ្ងៃមួយ ព្រះសម្មាសម្ពុទ្ធបានប្រៀបផ្ទឹមមាតាបិតា ទៅនឹងព្រះព្រហ្មដែលជាអាទិទេពនិងជាអ្នកបង្កើតលោកនៅក្នុងសាសនា

ហិណ្ឌូ។ ព្រះពុទ្ធទ្រង់សម្តែងប្រាប់យើងថា មាតាបិតាមានព្រហ្ម-វិហារធម៌បួន ដូចជា មេត្តា ករុណា ជាដើម ស្ថិតនៅក្នុងកម្រិតខ្ពស់បំផុត ចំពោះការបង្កើតរបស់គាត់។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងទៀតថា មានតែមាតាបិតាទេទើបមានព្រហ្មវិហារធម៌ចំពោះបុត្រធីតា ហេតុនេះបុត្រធីតាគួរគោរពប្រតិបត្តិទំនុកបម្រុងពួកគាត់ឲ្យបានសមរម្យ។ ជាងនេះទៅទៀត ព្រះពុទ្ធទ្រង់បង្ហាញឲ្យយើញថា មាតាបិតាជាបុព្វាចារ្យរបស់បុត្រធីតា។ សេចក្តីស្រឡាញ់និងការថែទាំរបស់មាតាបិតា និងការណែនាំដំបូងរបស់ពួកគាត់ ចំពោះបុត្រធីតាដែលវ័យនៅក្មេង គឺជាការទទួលខុសត្រូវយ៉ាងសំខាន់ ចំពោះការលូតលាស់ជាប្រក្រតី របស់បុត្រធីតាដើម្បីក្លាយទៅជាពលរដ្ឋដ៏ល្អម្នាក់។ ហេតុនេះ សេចក្តីស្រឡាញ់និងការលះបង់របស់មាតាបិតា គេមិនគួរបំភ្លេចចោលនោះទេប៉ុន្តែគេគួរតែផ្តល់រង្វាន់ និងគោរពប្រតិបត្តិយ៉ាងហោចណាស់ ជានិមិត្តរូបនៃកតញ្ញូតាធម៌។

អ្នកទាំងឡាយណាដែលចងចាំសេចក្តីស្រឡាញ់និងមេត្តាធម៌ដ៏ធំសម្បើមរបស់មាតាបិតា គឺជាអ្នកស្នងរបស់គាត់ ទាំងសមិទ្ធិផលជាសម្ភារៈ ទាំងគំនិតប្រាជ្ញាស្មារតី។ម្យ៉ាងទៀត ការថែ

រក្សាមាតាបិតា ដែលមានវ័យចំណាស់របស់ខ្លួនឲ្យបានគ្រប់គ្រាន់ គឺជាមង្គលដ៏ឧត្តមមួយ ក្នុងចំណោមមង្គលដ៏ឧត្តមផ្សេងទៀត។ ប្រសិនបើនរណាមួយមិនយកចិត្តទុកដាក់ និងបោះបង់ចោលមាតាបិតារបស់ពួកគេ សូម្បីតែមានលទ្ធភាពទទួលខុសត្រូវ នៅពេលដែលមាតាបិតាត្រូវការការជួយទំនុកបម្រុងពីកូនរបស់គាត់ និងថែទាំខ្ពស់បំផុតនៅថ្ងៃចុងក្រោយរបស់ពួកគាត់ក៏ដោយ នេះគឺជាហេតុដ៏មានកម្លាំង និងមិនអាចគេចផុត ឲ្យធ្លាក់ទៅក្នុងអបាយ នៅក្នុងជីវិតរបស់ខ្លួន (លោកថា ធ្លាក់នរកទាំងរស់)។ អាស្រ័យហេតុនេះ យោងទៅតាមការបង្រៀនប្រដៅផ្នែកព្រះពុទ្ធសាសនា ជាកាតព្វកិច្ច និងទំនួលខុសត្រូវរបស់កូនល្អ ដើម្បីផ្ដល់ការថែទាំ និងសេចក្ដីស្រឡាញ់គ្រប់គ្រាន់ ចំពោះមាតាបិតារបស់ពួកគេ។ ហើយមិនតែមាតាបិតារបស់ខ្លួនឯងផ្ទាល់នោះទេ ពោលគឺគោរពប្រតិបត្តិអ្នកដែលចាស់ជាងរបស់ខ្លួន ទាំងអាយុ ទាំងបុណ្យសក្តិ គឺជាការឲ្យតម្លៃខ្ពស់ ហើយបានត្រូវគេប្រតិបត្តិក្នុងបណ្ដាប្រទេសកាន់ព្រះពុទ្ធសាសនា អស់រយៈកាលជាច្រើនសតវត្សរ៍មកហើយ។

# ទស្សនវិស័យព្រះពុទ្ធសាសនា ស្តីអំពីចរិត
# ឃោរឃៅ

ចរិតឃោរឃៅនៅពាសពេញពិភពលោក ជម្មតាកំពុងកើតឡើងគួរឲ្យសោកសៅ ពិសេសនៅបណ្តាសង្គមឧស្សាហកម្មៗ ទោះជាមួយអាកប្បកិរិយាមនុស្សភាគច្រើន មិនទំនងជាមានហេតុផលតែមួយ ឬសាមញ្ញនោះឡើយ ប៉ុន្តែប្រហែលច្រើនបន្តិច ហើយតែងជាហេតុដ៏ស្មុគស្មាញទៀតផង។ ចរិតលក្ខណៈអ្នកបំផ្លាញ ប្រហែលជាត្រូវបានភ្ជាប់ ទៅនឹងតម្រូវការផ្លូវចិត្តជាមូលដ្ឋានជាច្រើន និងកម្រិតដែលតម្រូវការទាំងនេះត្រូវបានបំផ្លាញ ឬនៅតែមិនទាន់បំពេញ។ មានការបែកជាបួនប្រភេទ នៃតម្រូវការទាំងនេះ គឺតម្រូវការសេចក្តីសុខ និងសុវត្ថិភាព តម្រូវការបទពិសោធន៍ថ្មីៗ តម្រូវការសេចក្តីសរសើរ និងការទទួលស្គាល់ ហើយនិងតម្រូវការទទួលខុសត្រូវ។ តម្រូវការទាំងនេះគេត្រូវតែបំពេញ ចាប់តាំងពីដើមដំបូងនៃជីវិត (ពេលកើត) និងបន្តតម្រូវការឲ្យមានការបំពេញ ពោលគឺទំហំតូច ឬធំ រហូតដល់ទីបញ្ចប់នៃជីវិត (ពេលស្លាប់)។

ប្រសិនបើតម្រូវការមួយ ក្នុងចំណោមតម្រូវការទាំងនេះ នៅមិនទាន់បានបំពេញ ឬបំពេញមិនបានគ្រប់គ្រាន់ នឹងមានប្រតិកម្មពីរ គឺវាយប្រហារ ឬដកថយ។

តម្រូវការសេចក្តីស្រឡាញ់ និងសុវត្ថិភាពគឺប្រហែលតម្រូវដ៏សំខាន់បំផុតមួយ។ វាគឺជាមូលដ្ឋាននៃបំណងទាក់ទងបន្ទាប់ទាំងអស់ មិនត្រឹមតែនៅក្នុងគ្រួសារ ថែមទាំងជាមួយមិត្តភ័ក្តិ អ្នករួមការងារជាមួយ ហើយទីបំផុតនៅក្នុងគ្រួសារផ្ទាល់របស់ខ្លួន។ តម្រូវការនេះត្រូវបានបំពេញឲ្យកូន ដែលធ្វើឲ្យថ្មីកតាំងពីកើតសំដៅទៅរកទំនាក់ទំនងសេចក្តីស្រឡាញ់ គួរឲ្យជឿទុកចិត្តបានឥតដាច់ ពោលគឺដំបូងជាមួយម្តាយ បន្ទាប់មកឪពុក ហើយបន្ទាប់មកទៀតជាមួយមជ្ឈដ្ឋានយុវជនដែលរីកលូតលាស់កាន់តែធំឡើង និងមនុស្សរស់នៅក្នុងសម័យកាលជាមួយគ្នា។

នៅពេលដែលមិនបានបំពេញឲ្យបានគ្រប់គ្រាន់ ផលវិបាកទាំងឡាយ គឺប្រកបដោយសេចក្តីវិនាសអន្តរាយខ្លាំងជាបន្តបន្ទាប់ទាំងសម្រាប់បុគ្គលម្នាក់ៗ ទាំងសម្រាប់សង្គមជាតិ។ កំហឹង សេចក្តីស្អប់ និងការខ្វះខាតក្តីកង្វល់ ចំពោះអ្នកដទៃ គឺជាប្រតិកម្ម

ធម្មតា ដែលមិនគួរឲ្យស្រឡាញ់ និងមិនអាចទទួលយកបាន។ ចរិតលក្ខណៈឃោរឃៅ និងអំពើហឹង្សា គឺជាការបង្ហាញនូវអារម្មណ៍ទាំងនេះ។ តាមរយៈទំនាក់ទំនងសេចក្ដីស្រឡាញ់ ក្មេងៗទាំងឡាយរៀនគ្រប់គ្រងការខឹងក្រោធរបស់ពួកគេ ឬប្រើវាប្រកបដោយប្រយោជន៍ដោយគ្មានសុច្ឆន្ទៈ វានៅមានក្នុងកម្រិតទាបបំផុត តែរីកធំ កាន់តែសាហាវខ្លាំងឡើង ហើយចងគំនុំដោយកម្លាំងកាយកាន់តែកើតឡើង។

នៅពេលរាងកាយត្រូវការចំណីអាហារ ដើម្បីការរីកចម្រើនរាងកាយ និងមុខមួយដែលមានតុល្យភាពសមរម្យ គឺមានសារៈសំខាន់សម្រាប់ការរីកលូតលាស់ធម្មតា ដូច្នេះបទពិសោធន៍ថ្មីៗមានសារៈសំខាន់សម្រាប់ផ្លូវចិត្ត។ ប៉ុន្តែប្រសិនបើតម្រូវការនេះត្រូវបានបំពេញគ្រប់គ្រាន់ ក្នុងវ័យកុមារ និងវ័យពេញជំទង់ គំនិតប្រាជ្ញារបស់ក្មេងនឹងលូតលាស់បានពេញលេញ។ នៅពេលដែលតម្រូវការទាំងនេះមិនបានបំពេញ អំពើហឹង្សានិង ចរិតឃោរឃៅ គឺជាមធ្យោបាយផ្សេងទៀត ដែលអាចកើតមានឡើងច្រើនបំផុត។

ការពិតដ៏អស្ចារ្យមួយគឺអំពើហឹង្សា និងចរិតឃោរឃៅ គឺជាសកម្មភាពរបស់មនុស្សដ៏ច្រើនលើសលុប។

សេចក្ដីសរសើរ ការទទួលស្គាល់ និងការពោលសរសើរសមិទ្ធិផល ជាស្នាដៃរបស់កុមារ ទោះបីតូចតាចក៏ដោយ គឺជាកត្តាសំខាន់បំផុតសម្រាប់ជីវិតសាមញ្ញ។ នៅពេលដែលកុមារត្រូវបានទាត់ចោល ដោយឪពុកម្ដាយរបស់ពួកគេ នឹងចាត់ទុកថា ជាមនុស្សមិនទទួលបានជោគជ័យ ដោយគ្រូរបស់ពួកគេ កុមារនឹងត្រឡប់ទៅជាមនុស្ស ដែលមានឋានៈស្មើៗគ្នា (ក្រុមជើងកាង) ដើម្បីទទួលបានការទទួលស្គាល់ និងការកោតសរសើរ។ ដូច្នេះវាមិនមែនជាជំហានធំពេក មិនអាចឈានទៅដល់អំពើហឹង្សា និងចរិតឃោរឃៅនោះទេ។

កុមារដែលគេមិនព្រមឲ្យឱកាស ដើម្បីអនុវត្តទំនួលខុសត្រូវ នឹងខកខានមិនបានអភិវឌ្ឍវិចារណញាណ ក្នុងការទទួលខុសត្រូវចំពោះខ្លួនឯង ចំពោះអ្នកដទៃ ឬចំពោះកម្មវត្ថុ សម្ភារៈនានា។ ការអប់រំក្មេងបែបនេះតែងតែខ្វះខាតការហ្វឹកហ្វឺន ឲ្យគ្រប់គ្រងខ្លួនឯងឲ្យរង់ចាំ និងធ្វើអ្វីដែលពួកគេចង់ ព្រមទាំងឲ្យរក្សាទុកទ្រព្យសម្បត្តិខ្លួនឯងផ្ទាល់ និងទ្រព្យសម្បត្តិអ្នកដទៃ។

ប្រសិនបើទាំងនេះជាឫសគល់ពិតនៃចរិតឃោរឃៅ ដូចដែលអ្នកស្រាវជ្រាវទាំងឡាយស្នើសុំឲ្យស្រាវជ្រាវរក ព្រះពុទ្ធសាសនាមានច្រើនណាស់ ដើម្បីផ្តល់ប្រឆាំងនឹងអំពើហឹង្សា និងចរិតឃោរឃៅ ដែលកើនឡើង មិនចេះឈប់ឈរ ក្នុងចំណោមយុវជនក្មេងៗ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឈ្វេងយល់សារៈសំខាន់នៃកាតព្វកិច្ច និងទំនួលខុសត្រូវរបស់មនុស្សសម្រាប់សង្គម ដែលមានសុវត្ថិភាព និងសាមគ្គីធម៌។ ការយល់ដឹងអំពីកាតព្វកិច្ច និងទំនួលខុសត្រូវរបស់ខ្លួន ហើយការបំពេញកាតព្វកិច្ចនិងទំនួលខុសត្រូវផ្តល់គ្រឹះសម្រាប់សង្គមរាក់ទាក់ និងស្មោះភាព ហើយមានតែសង្គមបែបនេះទេ ទើបអាចប្រកាសថា ជាសង្គមអភិវឌ្ឍប្រាជ្ញាស្មារតី។ នេះជាវិធីតែមួយគត់ ដើម្បីឲ្យមានសង្គមគ្មានអំពើហឹង្សា។ ជាធម្មតា ការយល់ដឹងកាតព្វកិច្ច និងទំនួលខុសត្រូវទាំងឡាយរបស់ខ្លួនចំពោះអ្នកដទៃ បង្កើតឲ្យមានគ្រឹះរឹងមាំ សម្រាប់សង្គមល្អសុក្រិត។ កាតព្វកិច្ចនិងទំនួលខុសត្រូវ ដែលស្នើរឡើងនៅក្នុងព្រះពុទ្ធសាសនា គឺពាក់ព័ន្ធយ៉ាងច្រើន ជាមួយសេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់ ការទទួលស្គាល់ និងការកោតសរសើរគំរូល្អ និងការណែនាំ ឲ្យដើរក្នុងផ្លូវត្រូវរបស់មាតាបិតា និងគ្រូ

អាចារ្យ ដល់បុត្រធីតា និងសិស្សទាំងឡាយ នៅក្នុងជីវិតដំបូងបំផុតរបស់ពួកគេ។

គេផ្ដល់ការយកចិត្តទុកដាក់តិចតួច ឬក៏គ្មានសោះចំពោះច្បាប់សីលធម៌ព្រះពុទ្ធសាសនា នៅលោកខាងលិច។ ពីបទពិសោធន៍របស់ខ្លួនខ្ញុំផ្ទាល់ជាជនជាតិអាស៊ីរស់នៅបច្ចិមប្រទេស ជាកន្លែងដែលចរិតលក្ខណៈឃោរឃៅ កំពុងកើនឡើងប្រកបដោយគ្រោះថ្នាក់ ខ្ញុំមានជំនឿយ៉ាងមុតមាំថា ការប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនាភាគច្រើន ជាពិសេសដែលទាក់ទងក្រមសីលធម៌ អាចត្រូវបានប្រើប្រាស់ជាផ្លែផ្កា ដើម្បីការពារអាកប្បកិរិយាហឹង្សាភាគច្រើន ក្នុងចំណោមយុវជនក្មេងៗ។

នៅក្នុងឱកាសជាច្រើន ព្រះពុទ្ធសាសនាពិភាក្សាដោយផ្ទាល់អំពីកាតព្វកិច្ច និងទំនួលខុសត្រូវរបស់មនុស្ស ជាសមាជិករបស់សង្គម។ ក្នុងចំណោមនោះ "ឱវាទចំពោះគហបតីបុត្ត ឈ្មោះសិង្គាលកៈ" (**សិង្គាលកសូត្រ**) គឺរកអ្វីមកប្រៀបមិនបាន ពីព្រោះកាតព្វកិច្ច និងទំនួលខុសត្រូវ ត្រូវបានសម្ដែងជាលំអិតនៅក្នុងព្រះសូត្រនេះ។ រឿងដែលគួរឲ្យចាប់អារម្មណ៍នេះមានតម្លៃជាការរ៉ាយរ៉ាប់អធិប្បាយ។

លំដាប់នោះឯង ព្រះមានព្រះភាគ ស្តេចទ្រង់ចេញពីកលន្ទកនិវាបស្ថាន ក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាទ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញសិង្គាលកគហបតីបុត្ត មានសំពត់ស្លៀកជណ្តប់ទទឹក និងសក់ទទឹក។ គហបតីបុត្តកំពុងអញ្ជលី ថ្វាយបង្គំទិសទាំងឡាយច្រើន គឺទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ខាងក្រោម និងទិសខាងលើ។ លុះទ្រង់ឃើញហើយ ទើបទ្រង់ត្រាស់សួរសិង្គាលកគហបតីបិត្ត ដូច្នេះថា នែគហបតីបុត្ត តើអ្នកកំពុងធ្វើអ្វី។

"បពិត្រព្រះអង្គដ៏ចំរើន កាលបិតារបស់ខ្ញុំជិតនឹងធ្វើមរណកាល បានផ្តាំនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ហៃបា អ្នកត្រូវតែថ្វាយបង្គំទិសទាំងឡាយ ដើម្បីបិទបាំងកយន្តរាយ ពីទិសទាំង៦។"

ព្រះមានព្រះភាគទ្រង់ត្រាស់ថា "ជាការប្រពៃណាស់ធ្វើសក្ការៈ គោរព រាប់អាន បូជានូវពាក្យរបស់បិតាអ្នក ដែលគាត់បានផ្តាំជាពាក្យចុងក្រោយរបស់គាត់ ប៉ុន្តែអ្នកមិនត្រូវធ្វើសក្ការៈគោរព រាប់អានបូជានូវពាក្យរបស់បិតាអ្នក ដោយត្រង់ៗ ដូច្នេះទេ"។ គ្រានោះ ព្រះមានព្រះភាគទ្រង់សំដែងពន្យល់អំពីសារៈសំខាន់នៃការយល់ដឹង និងការបំពេញកាតព្វកិច្ច និងទំនួលខុស

ត្រូវរបស់ខ្លួន។ "ថ្វាយបង្គំទិសខាងកើត អ្នកត្រូវដឹងថា គោរព និងផ្ដល់កិត្តិយសដល់មាតាបិតារបស់អ្នក។" ប៉ុន្តែបុត្រធីតាអាច គោរព ដោយស្មោះត្រង់ចំពោះមាតាបិតារបស់ខ្លួន ក្នុងករណីដែល មាតាបិតាបានបំពេញកាតព្វកិច្ចរបស់គាត់ចំពោះបុត្រធីតា។

មាតាបិតារមែងអនុគ្រោះកូនដោយស្ថាន ៥ យ៉ាង គឺ ហាម ឃាត់កូនចាកអំពើអាក្រក់ ១ ឲ្យកូនតម្កល់នៅតែក្នុងអំពើល្អ ១ ឲ្យកូនរៀនសូត្រសិល្បសាស្ត្រ ១ ដណ្ដឹងភរិយាស្វាមីសមគួរឲ្យ១ ចែកទ្រព្យឲ្យកូនក្នុងសម័យដ៏សមគួរ ១ ។ ឥឡូវនេះឃើញច្បាស់ ហើយថា ព្រះសម្មាសម្ពុទ្ធទ្រង់ឈ្វេងយល់តម្រូវការ សេចក្ដី ថែរក្សា សេចក្ដីស្រឡាញ់ និងសុវត្ថិភាព ចំពោះការធំធាត់របស់ បុត្រធីតា។

"ថ្វាយបង្គំទិសខាងត្បូង អ្នកត្រូវដឹងថា គោរពនិងស្ដាប់ ដំបូន្មានអាចារ្យ។" ជាធម្មតា សិស្សគោរពអាចារ្យ លុះត្រាតែ អាចារ្យលើកតម្កើង និងទទួលស្គាល់កិច្ចការ ដែលបានបំពេញ របស់សិស្ស។ ព្រះពុទ្ធទ្រង់ត្រាស់ដឹង ពីស្ថានប្រាំយ៉ាងរបស់ អាចារ្យចំពោះសិស្ស។ ស្ថានប្រាំយ៉ាងនេះទាក់ទិនផងដែរ ទៅនឹង

ការយល់ដឹង និងការលើកតម្កើង ព្រមទាំងការទទួលស្គាល់លទ្ធផលការសិក្សារបស់សិស្ស។

“ថ្វាយបង្គំទិសខាងជើង អ្នកត្រូវដឹងថា មានចិត្តល្អ និងសង្គ្រោះដល់មិត្តអាមាត្យ សាច់ញាតិ និងអ្នកជិតខាង។” “មិត្ត” នៅក្នុងបរិបទនេះ មានន័យខុសប្លែកគ្នាផងដែរនឹងពាក្យ “មិត្តភាព” របស់ក្រុមបក្សពួកតាមចិញ្ចើមផ្លូវ ដែលទទួលខុសត្រូវចំពោះភាគច្រើននៃភាពសាហាវឃោរឃៅ នៅក្នុងបណ្ដាសង្គមសម័យបច្ចុប្បន្ន។ សេពគប់ជាមួយមិត្តល្អមានសារៈសំខាន់ណាស់ ពីព្រោះមិត្តទាំងឡាយមានឥទ្ធិពលលើការអប់រំនិស្ស័យ អត្តចរិតនៅក្នុងពេលកំពុងលូតលាស់។

“ថ្វាយបង្គំទិសខាងលិច អ្នកត្រូវដឹងថា ស្មោះត្រង់និងលះបង់ចំពោះកូននិងប្រពន្ធ។” ទីនេះព្រះសម្មាសម្ពុទ្ធ ទ្រង់សម្ដែងពន្យល់អំពីកាតព្វកិច្ច និងទំនួលខុសត្រូវកិរិយាស្វាមី ហើយទ្រង់បញ្ជាក់ពីសារៈសំខាន់ នៃការបំពេញកាតព្វកិច្ច និងទំនួលខុសត្រូវទាំងនោះ។ ទំហំនៃជីវិតគ្រួសារ មានសារៈសំខាន់ផងដែរ ពីព្រោះការរកឃើញនៃការសិក្សាបង្ហាញថា កូនមកពីគ្រួសារដែលបែក

បាក់គ្នា គឺទំនងជាប្រព្រឹត្តអំពើសាហាវឃោរឃៅ ជាងកូនមកពីគ្រួសារមានស្ថានភាពមិនបែកបាក់គ្នា។

ពិតមែនហើយ ព្រះពុទ្ធទ្រង់សម្តែងបញ្ជាក់ពីសារៈសំខាន់នៃទំនាក់ទំនងស្មារតី។ បើតាមព្រះពុទ្ធសាសនា សម្រាប់ការអភិវឌ្ឍល្អឥតខ្ចោះ ទាំងថ្នាក់បុគ្គល ទាំងថ្នាក់សង្គម ក៏គួរមានតុល្យភាពរវាងសម្បទាសម្ភារៈ និងសម្បទាផ្លូវចិត្ត។ ហេតុនេះ ចាំបាច់ត្រូវស្វែងយល់ពីតម្រូវការផ្នែកស្មារតី។

ព្រះពុទ្ធទ្រង់មិនត្រឹមតែសម្តែង ពីកាតព្វកិច្ចនិងទំនួលខុសត្រូវប៉ុណ្ណោះទេ ថែមទាំងចង្អុលបង្ហាញពីចំណុចមានសារៈសំខាន់ដទៃទៀត ដែលគួរជៀសវាង ដូចជា កម្មកិលេស (អំពើដ៏សៅ-ហ្មង) ៤ ប្រការ គឺការធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្ទង (សម្លាប់សត្វ) ១ ការកាន់យកទ្រព្យដែលម្ចាស់គេមិនឲ្យ ១ ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ និងការនិយាយពាក្យកុហក ១ ។

ទីនេះ ការសម្លាប់មានអត្ថន័យទូលំទូលាយ។ មិនដូចការបង្រៀនរបស់សាសនាដទៃទៀតជាច្រើន ព្រះពុទ្ធសាសនាបង្រៀនយើងយ៉ាងតឹងរឹង កុំឲ្យធ្វើឲ្យអន្តរាយ ឬក៏ធ្វើឲ្យបាត់បង់ជីវិតសត្វណាមួយ។ សូម្បីតែរុក្ខជាតិ ក៏គេគួរផ្តល់ ការការពារ

និងការថែរក្សាសមរម្យដែរ។ ហេតុនេះ ការគ្មានចិត្តត្រាប្រណី អំពើសាហាវឃោរឃៅ និងអាកប្បកិរិយាបំផ្លិចបំផ្លាញ និងរើស អើង ត្រូវផ្តន្ទាទោស និងគេគួរជៀសវាង។ ការមិនអើពើរឿងពិត សាមញ្ញនេះអាចជាហេតុផល ចំពោះការចំណាយប្រាក់ច្រើន សម្បើម និងកិច្ចប្រឹងប្រែង ដើម្បីរៀបចំចលនាអន្តរជាតិខុសៗគ្នា ដើម្បីការពារសិទ្ធិជាមូលដ្ឋាន ដូចជា សិទ្ធិមនុស្ស សិទ្ធិស្ត្រី សិទ្ធិ កុមារ សិទ្ធិសត្វពាហនៈ និងជាងនេះទៅទៀត សិទ្ធិបរិស្ថាន។

ការបោកប្រាស់ ការលួចប្លន់ ការគៃបន្លំ គឺជាកម្មកិលេស ទីពីរត្រូវជៀសវាង។ ការលួចនេះអាចមានតាមរូបភាពជាច្រើន។ វាអាចមានចាប់ ពីការលួចបន្តិចបន្តួច រហូតដល់ការគៃបន្លំ គណនេយ្យធនាគារអន្តរជាតិ និងការស៊ូកប៉ាន់របស់មន្ត្រីខាង ការងាររដ្ឋបាល។ ទម្រង់អ្វីក៏ដោយ ដែលអាចធ្វើឡើង ទម្រង់នៃ ទង្វើទាំងអស់នេះ គឺគ្រោះថ្នាក់ដល់សង្គម។

ការញៀនគ្រឿងញៀន គឺជាបញ្ហាសំខាន់មួយផ្សេងទៀត សម្រាប់សង្គមជាច្រើនត្រូវដោះស្រាយ។ ជាថ្មីម្តងទៀត ចំនួននៃ អ្នកញៀនគ្រឿងញៀនកំពុងកើនឡើងគួរឲ្យព្រួយបារម្ភ និងមាន ការចូលរួមជិតស្និទ្ធិជាមួយអំពើហឹង្សា។ ព្រះពុទ្ធទ្រង់ឈ្វេងយល់

ពីគ្រោះថ្នាក់នៃគ្រឿងស្រវឹង ហើយទ្រង់ត្រាស់សម្តែងឲ្យជៀសវាងទម្លាប់ដ៏អាក្រក់នេះ។

ចុងក្រោយ ការប្រព្រឹត្តខុសក្នុងកាម គួរគេជៀសវាង។ មិនត្រឹមតែវាធ្វើឲ្យខូចសតិស្មារតីប៉ុណ្ណោះទេ ថែមទាំងអាចធ្វើឲ្យខូចសុខភាពរបស់ខ្លួនផងដែរ។ ការសិក្សាប្រកបដោយការយកចិត្តទុកដាក់បង្ហាញថាមានទំនាក់ទំនងជិតស្និទ្ធមួយ រវាងជម្ងឺទាំងឡាយបណ្តាលឲ្យស្លាប់ និងការរួមភេទមិនស្របច្បាប់ផងដែរ។

**ឆន្ទាគតិ ទោសាគតិ មោហាគតិ** និង**ភយាគតិ** គឺជាហេតុបួនយ៉ាង ចំពោះអំពើអាក្រក់នេះ បើតាមព្រះសម្មាសម្ពុទ្ធទ្រង់បានសម្តែង។ ហេតុទាំងបួនយ៉ាងនេះ បណ្តាលឲ្យកើតមានភាគច្រើននៃអំពើហិង្សា នៅក្នុងសម័យទំនើបនេះ។

ដោយបានសង្កេតពិនិត្យ ការសិក្សាសម័យទំនើបទៅក្នុងចរិតឃោរឃៅ និងបានប្រៀបធៀបការរកឃើញ និងការស្នើរសុំរបស់ពួកគេ ជាមួយច្បាប់សីលធម៌ព្រះពុទ្ធសាសនា ជាមូលដ្ឋានមួយចំនួន យើងអាចសន្និដ្ឋានបានថា ព្រះពុទ្ធសាសនាមានចម្លើយមានប្រយោជន៍មួយចំនួនចំពោះបញ្ហាសម័យទំនើបទាំងនេះ។ ប៉ុន្តែព្រះពុទ្ធសាសនាចូលរួមចំណែកជាច្រើននិងស្នើថា ការមិនអើពើ

ពីសារៈសំខាន់នៃការបំពេញកាតព្វកិច្ចនិងទំនួលខុសត្រូវរបស់ខ្លួនអាចធ្វើឲ្យអន្តរាយថែមទៀតដល់សង្គមៗ កាតព្វកិច្ចទាំងនេះមានសារៈសំខាន់ណាស់ ពីព្រោះវាជានាំឲ្យមានសេចក្ដីស្រឡាញ់ ការគោរព និងការការពារចំពោះសព្វសត្វទាំងអស់ និងជានាសាមគ្គីភាពគ្រួសារៗ

# គោលដៅជីវិត

ប្រសិនបើអស់លោកអ្នកសួរសំនួរនេះ ទៅអ្នកទាំងឡាយមកពីសាវតាវប្បធម៌ និងក្រមសីលធម៌ខុសៗគ្នា លោកអ្នកអាចទទួលបានចម្លើយខុសៗគ្នា ពីព្រោះការយល់ដឹងរបស់មនុស្សម្នាក់ៗ អំពីលោកនិងជីវិត ត្រូវបានកើតឡើងដោយជំនឿសាសនា និងឥរិយាបថផ្ទាល់ខ្លួនរបស់គេ។ ម៉្យាងទៀតយើងមិនគួរទទួលយកចម្លើយងាយៗ ចំពោះសំនួរស្មុគស្មាញនេះ។ ពិតមែនហើយ សេចក្តីព្យាយាមណាមួយ ដើម្បីរិះរកចម្លើយមានអត្ថន័យមួយ នឹងជាការលំបាកក្រៃលែង។ សំនួរនេះហាក់ដូចជាគេនិយមណាស់ ហេតុនេះដោយសេចក្តីសន្ទត់នៅតែមិនទាន់បានឆ្លើយតប ឲ្យបានពេញលេញ នៅក្នុងជំពូកចុងក្រោយនេះ ខ្ញុំនឹងព្យាយាមសង្កេតពិនិត្យមើលពាក្យ ប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា ដែលពាក់ព័ន្ធមួយចំនួន ពីព្រោះចម្លើយមានអត្ថន័យបែបនេះ នឹងជួយយើងធ្វើឲ្យវៀវចន្លោះរវាងជំនឿខុសគ្នា និងការកើនឡើងការយល់ដឹងអំពីព្រះពុទ្ធសាសនា។

សម័យមួយ សំនួរដូចគ្នានេះ ប៉ុន្តែប្រើពាក្យខុសគ្នាបន្តិច

ត្រូវបានសួរចំពោះព្រះកក្រ្តព្រះមានព្រះភាគ។ "តើជីវិតរស់នៅបែបណា ទើបគេចាត់ទុកថាជាជីវិតប្រសើរ?" ចម្លើយខ្ទីរបស់ព្រះអង្គគឺ "ជីវិតរស់នៅប្រកបដោយបញ្ញា ជាជីវិតប្រសើរ"។

ខ្ញុំជឿជាក់ថា សំនួរដែលបានសួរមានលក្ខណៈប្រសើរជាងសំនួរនេះគឺ "តើអ្វីទៅជាគោលដៅជីវិត?" ពីព្រោះវាផ្តល់ប្រភេទខ្វះនៃការយល់ដឹងជ្រៅជ្រះ ទៅក្នុងវិធីដោះស្រាយរបស់ព្រះពុទ្ធសាសនាចំពោះបញ្ហាជីវិត។ ព្រះពុទ្ធទ្រង់ឈ្វេងយល់ភាពពិបាកឆ្លើយសំនួរបែបនេះ ហើយទ្រង់ឆ្លើយហាក់ដូចជាបានព្រមព្រៀងហើយ។ "ជីវិតរស់នៅប្រកបដោយបញ្ញា ជាជីវិតប្រសើរ" ពិតមែនហើយជាចម្លើយល្អ។ ប៉ុន្តែ នៅមានគេលើកសំនួរជាច្រើនទៀត។ "តើអ្វីទៅជាជីវិតរស់នៅប្រកបដោយបញ្ញា?" តើយើងអាចរស់នៅប្រកបដោយបញ្ញាដោយរបៀបណា? ដើម្បីយល់ដឹងវិធីដោះស្រាយរបស់ព្រះពុទ្ធសាសនា ចំពោះមាគ៌ាក្នុងការរស់នៅជាដំបូង យើងត្រូវឲ្យនិយមន័យនៃពាក្យគន្ធិះ (បញ្ញា)។ (បញ្ញា) គឺជាពាក្យដើមជាភាសាបាលី ដែលគេប្រើដើម្បីពន្យល់អត្ថន័យទស្សនវិជ្ជាពិសេសមួយ។ បញ្ញាគឺជាចំណេះដឹងជ្រៅជ្រះបំផុត

ហើយបញ្ហាខុសគ្នាយ៉ាងច្បាស់លាស់ពី "គតិបណ្ឌិត" ឬប្រាជ្ញា ដែលគ្រាន់តែសន្មត់នោះៗ ពុទ្ធសាសនិកជឿថា មានតែបញ្ញាមួយ គត់អាចជួយយើងឲ្យមើលឃើញសភាវធម៌ទាំងឡាយតាមសភាព ពិតៗ ទម្រង់មួយចំនួនទៀតនៃចំណេះដឹងអាចប្រឫកប្រឫបល់ចូល គ្នាជាមួយការស្រមើលស្រមៃ និងជំនឿរបស់យើង ជាជាងការ យល់ដឹងជាក់ច្បាស់អំពីធម្មជាតិៗ ប៉ុន្តែនិយមន័យនៃពាក្យគន្លឹះនេះ តែមួយមិនអាចឆ្លើយសំនួរទីមួយរបស់យើង "តើជីវិតប្រភេទណា ជាជីវិតប្រសើរ?"

ដើម្បីមានការយល់ដឹងកាន់តែប្រសើរ អំពីបញ្ហាប្រធានបទ នេះ យើងត្រូវមានចំណេះដឹងមួយចំនួន អំពីគោលដៅចុងក្រោយ របស់ព្រះពុទ្ធសាសនាៗ គោលដៅនេះ គេហៅថា **និព្វាន** ដែល មានន័យថា ការដកឫសនៃលោភៈ ទោសៈ និងមោហៈ និយាយ ម៉្យាងទៀតគឺការកាត់ផ្តាច់ឫសគល់នៃអវិជ្ជា និងតណ្ហាទាំងឡាយ ដែលជិតជាប់ជាយូរមកហើយ ចេញពីចិត្តរបស់យើងៗ ដើម្បី សម្រេចបាន យើងតម្រូវឲ្យមានការយល់ដឹងពិតអំពីលោកៗ វិធី សាស្ត្រនេះ ជាធម្មតា គេហៅថា "សម្មាទិដ្ឋិ"ៗ ហេតុនេះ ការ ពន្យល់ណាមួយ ដែលបិទបាំងធម្មជាតិពិត ចាត់ទុកជាការយល់

ខុស ហើយមាគ៌ាក្នុងការរស់នៅណាមួយ ដែលបង្ខំដោយហេតុអាក្រក់ ដូចជា លោភៈ ទោសៈ និងមោហៈខ្លាំង ចាត់ទុកជាការរស់នៅខុស ពីព្រោះអំពើបែបនេះចងយើងឲ្យឆ្ងាយពីគោលដៅចុងក្រោយរបស់យើងគឺនិព្វាន។ ហេតុនេះ ព្រះពុទ្ធទ្រង់ពន្យល់របៀបនេះជាលំអិត នៅពេលព្រះអង្គសម្តែង "អរិយសច្ចបួន"។ ឱវាទដ៏ប្រសើរនេះ ហៅថា មាគ៌ាដឹកនាំឆ្ពោះទៅទីរំលត់ទុក្ខ (មគ្គ-សច្ចៈ)។ ហេតុនេះ ជាធម្មតា សីលធម៌ព្រះពុទ្ធសាសនាផ្អែកលើឱវាទដ៏សំខាន់នេះ។

ផ្ទុយមកវិញ បណ្ឌិតខ្លះបង្ហាញថា ការឈ្លានពាន និងអំពើហឹង្សា គឺជាកត្តាមានជីវិតនៅក្នុងទម្រង់នៃជីវិតណាមួយ។ នៅលើថ្នាក់សត្វនេះអាចមានពិត ប៉ុន្តែនៅលើថ្នាក់មនុស្ស ការឈ្លានពាន និងអំពើហឹង្សា គេមិនអាចប្រើប្រាស់ដើម្បីដោះស្រាយបញ្ហានោះបានទេ។ សង្គ្រាម ជាញឹកញាប់ណាស់ ជាគ្រឿងបន្ទាល់ សម្រាប់ដោះស្រាយបញ្ហា នៅក្នុងសង្គមមនុស្ស សូម្បីតែនៅក្នុងសម័យវិទ្យាសាស្ត្រក៏ដោយ។ ប៉ុន្តែបើតាមព្រះពុទ្ធសាសនា កម្រិតណាមួយនៃអំពើហឹង្សា ចំពោះទម្រង់ណាមួយនៃជីវិត ឬជាងនេះទៅទៀត ធាតុទាំងឡាយទ្រទ្រង់ជីវិត ដូចជា ដី ទឹក រុក្ខជាតិ ឬខ្យល់

គឺមិនអាចទទួលយកទាំងស្រុង និងពិតប្រាកដក្រោមកាលៈទេសៈណាមួយនោះទេ។

មនុស្សជាច្រើនហាក់មានគំនិតថា កាមឆន្ទៈទាំងឡាយគឺជាធម្មជាតិ ច្បាស់លាស់ណាស់ ហើយជាងនេះទៅទៀត កាន់តែធ្វើឲ្យភ្ញាក់ផ្អើលឡើង ដោយចាត់ទុកថា ជាកត្តាសំខាន់សម្រាប់សាសនាមិនទាន់ផុតរលត់។ ប៉ុន្តែ ព្រះពុទ្ធសាសនាបញ្ជាក់ថា ហេតុផលអាក្រក់ទាំងនេះចម្លែកនៅក្នុងចិត្ត ប៉ុន្តែរហូតដល់វានៅក្នុងចិត្តរបស់យើង អស់រយៈពេះដ៏យូរអង្វែងបែបនេះ ភាពចម្លែកទាំងនោះបានត្រូវគេបំភ្លេចចោល ដូច្នេះហើយពួកគេបានក្លាយជាទទួលយកថា មានមកពីកំណើត និងជាធម្មជាតិ។ ការយល់ដឹងពីសច្ចៈនេះ គេចាត់ទុកជាសំខាន់ចាំបាច់ថាជាសម្មាទិដ្ឋិ។ សម្រាប់ហេតុផលនេះ ព្រះពុទ្ធសាសនាបង្កើតមូលដ្ឋានគ្រឹះរាក់ទាក់ និងពិតប្រាកដមួយ ហើយបង្ហាញយ៉ាងសុទិដ្ឋិនិយមថា យើងនៅទីនេះដើម្បីជួយជីវិត មិនមែនបំផ្លិចបំផ្លាញវាទេ។

ឥឡូវនេះយើងអាចផ្តល់ចម្លើយមានប្រយោជន៍មួយ ចំពោះសំនួរដើម "តើអ្វីទៅជាគោលដៅជីវិត?" ចម្លើយ គោលដៅជីវិតគឺជាការទទួលបានចំណេះដឹងពិត និងដឹងនាំជីវិតរាក់ទាក់មាន

ប្រយោជន៍ និងមានប្រាជ្ញាមួយៗ គ្រាន់តែប្រភេទនៃជីវិតបែបនេះ អាចចាត់ទុកថាជាជីវិតមានន័យ និងមានជ័យជំនះ ពីព្រោះប្រភេទនៃជីវិតនោះដឹកនាំមនុស្ស ឲ្យឈានដល់កម្រិតខ្ពស់បំផុតនៃការសម្រេចបានខាងសតិស្មារតី និងដឹកនាំទៅកាន់សង្គមគ្មានអំពើហឹង្សាមួយៗ នេះគួរជាគោលដៅនៃជីវិត៕

# បរិសិដ្ឋ

## វាសេដ្ឋសូត្រ[៤]-ទស្សនវិជ្ជាសង្គមរបស់ព្រះពុទ្ធសាសនា

ខ្ញុំបានស្ដាប់មកយ៉ាងនេះ។ សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងដងព្រៃឈ្មោះឥច្ឆានង្គលៈ។ សម័យនោះឯង ពួកព្រាហ្មណ៍មហាសាលជាច្រើនមានឈ្មោះល្បីល្បាញ អាស្រ័យនៅក្នុងស្រុកឈ្មោះឥច្ឆានង្គលៈ គឺ ចង្កីព្រាហ្មណ៍ តារុក្ខព្រាហ្មណ៍ បោក្ខរសាតិព្រាហ្មណ៍ ជាណុស្សោណិព្រាហ្មណ៍ តោទេយ្យព្រាហ្មណ៍ នឹងពួកព្រាហ្មណមហាសាលឯទៀត ដែលមានឈ្មោះល្បីល្បាញ។ គ្រានោះ វាសេដ្ឋមាណព នឹងភារទ្វាជមាណព កំពុងដើរទៅដើរមកសម្រាកស្ងួន ក៏កើតអន្តរាកថានេះឡើងថា ម្នាលគ្នាយើង បុគ្គលឈ្មោះថាជាព្រាហ្មណ៍ តើដោយប្រការដូចម្ដេច។ ភារទ្វាជមាណពនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន បុគ្គលដែលមានកំណើតល្អ ទាំងពីរចំណែក គឺខាងមាតានឹងខាងបិតា ជាអ្នកកើតក្នុងផ្ទៃរបស់ព្រាហ្មណី ដែលបរិសុទ្ធដរាបអំពីគូនៃជីដូនជីតា ៧

---

[៤] សូត្រនេះដកស្រង់ចេញពីព្រះត្រៃបិដក

ដំណាមក មិនមានអ្នកណាពោលទោសតិះដៀល ដោយការពោល អំពីជាតិបាន ម្នាលអ្នកដ៏ចំរើន បុគ្គលបានឈ្មោះថាព្រាហ្មណ៍ ដោយហេតុប៉ុណ្ណោះឯង។ វាសេដ្ឋមាណពនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន លុះតែបុគ្គលមានសីលផង បរិបូណ៌ដោយវត្ត ផង ម្នាលអ្នកដ៏ចំរើន បុគ្គលនោះទើបហៅថាព្រាហ្មណ៍ដោយ ហេតុប៉ុណ្ណោះឯង។ ភារទ្វាជមាណព មិនអាចញុំាងវាសេដ្ឋមាណព ឲ្យយល់ឃើញបាន ទាំងវាសេដ្ឋមាណព ក៏មិនអាចញុំាងភារទ្វាជ មាណព ឲ្យយល់ឃើញបាន។ គ្រានោះ វាសេដ្ឋមាណពហៅ ភារទ្វាជមាណពថា ម្នាលភារទ្វាជៈដ៏ចំរើន ព្រះសមណគោតមនេះ ជាសក្យបុត្រ ចេញចាកសក្យត្រកូលទ្រង់ព្រះផ្នួស (ឥឡូវនេះ) គង់នៅក្នុងដងព្រៃឥច្ឆានង្គលៈជិតស្រុកឈ្មោះឥច្ឆានង្គលៈកិត្តិស័ព្ទ ដ៏ពិរោះរបស់ព្រះគោតមដ៏ចំរើននោះ ខ្ចរខ្ចាយសុះសាយទៅយ៉ាង នេះថា ព្រះមានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គត្រាស់ដឹង ចតុរារិយសច្ច ព្រះអង្គលែងត្រឡប់មកកើតក្នុងភពថ្មីទៀត ម្នាល ភារទ្វាជៈ មកទៅយើង នឹងចូលសំដៅទៅត្រង់ទីដែលព្រះសមណ គោតមគង់ លុះចូលទៅដល់ហើយ នឹងសួរសេចក្ដីនេះ ព្រះ សមណគោតមនឹងដោះស្រាយឲ្យយើងយ៉ាងណា យើងនឹងចាំទុក

នូវសេចក្តីនោះយ៉ាងនោះៗ ការទ្វាជមាណពទទួលស្តាប់ពាក្យរបស់វាសេដ្ឋមាណពថា អើអ្នកៗ គ្រានោះ វាសេដ្ឋមាណពនឹងការទ្វាជមាណព ចូលសំដៅទៅត្រង់កន្លែង ដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យគួរជាទីរីករាយ នឹងពាក្យដែលគួរឲ្យរលឹកហើយ ក៏អង្គុយក្នុងទីសមគួរៗ វាសេដ្ឋមាណព លុះអង្គុយក្នុងទីសមគួរហើយ ក្រាបទូលព្រះមានព្រះភាគ ដោយគាថាទាំងឡាយថា ៖

១ បពិត្រព្រះអង្គដ៏ចំរើន យើងជាអ្នកមានត្រៃវិជ្ជា ដែលអាចារ្យអនុញ្ញាតនឹងប្តេជ្ញាហើយ ដោយពិត ខ្ញុំព្រះអង្គជាសិស្សបោក្ខរសាតិព្រាហ្មណ៍ មាណពនេះជាសិស្សរបស់តារុក្ខព្រាហ្មណ៍ៗ

២ ពាក្យណារបស់អ្នកមានត្រៃវិជ្ជាទាំងឡាយ ដែលអាចារ្យបានប្រាប់ហើយ ពួកយើងជាអ្នកសម្រេចក្នុងពាក្យនោះហើយ យើងទាំងឡាយ ជាអ្នកចេះបទ ចេះវេយ្យាករណ៍ក្នុងវេទ ប្រហែលនឹងអាចារ្យៗ

៣ បពិត្រព្រះគោតម ពួកយើងនោះមានការជជែកគ្នាក្នុងការពោល អំពីជាតិ ការទ្វាជមាណពនិយាយថា បុគ្គលជាព្រាហ្មណ៍

ព្រោះជាតិ។ ឯខ្ញុំព្រះអង្គនិយាយថា បុគ្គលដែលឈ្មោះថាព្រាហ្មណ៍ ព្រោះកម្ម បពិត្រព្រះអង្គ ជាបុគ្គលមានចក្ខុ សូមព្រះអង្គជ្រាបយ៉ាងនេះ។

៤ យើងទាំងពីរនាក់នេះ មិនអាចញ៉ាំងគ្នានឹងគ្នាឲ្យយល់ឃើញបានទេ (ព្រោះហេតុនោះ) ទើបយើងទាំងឡាយមក ដើម្បីសួរព្រះអង្គដ៏ចំរើន ដែលល្បីល្បាញថាជាអ្នកត្រាស់ដឹងឯង។

៥ បពិត្រព្រះគោតម ពួកជន ផ្គងអញ្ជលី ចូលទៅ កាលថ្វាយបង្គំក៏ថ្វាយបង្គំព្រះចន្ទ្រ ដែលកន្លងនូវការអស់ទៅនៃងងឹត (ព្រះចន្ទ្រពេញវង្ស)។

៦ យ៉ាងណាមិញ ពួកជនក្នុងលោក (ក៏ថ្វាយបង្គំព្រះអង្គ) យ៉ាងនោះដែរ។ ពួកយើង សូមសួរព្រះគោតម ដែលមានចក្ខុកើតហើយក្នុងលោក បុគ្គលឈ្មោះថាព្រាហ្មណ៍ ព្រោះជាតិ ឬព្រោះកម្ម សូមព្រះអង្គសំដែង ប្រាប់ពួកយើង ដែលជាអ្នកមិនទាន់ស្គាល់ឲ្យទាល់តែពួកយើងស្គាល់។

៧ (ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលវាសេដ្ឋៈ) បើដូច្នោះតថាគតនឹងសំដែងឲ្យពិស្តារអំពីជាតិ របស់សត្វទាំងឡាយ តាម

ពិត ដោយលំដាប់ ដល់អ្នកទាំងឡាយនោះ ធម្មតា សត្វទាំងឡាយរមែងមានជាតិផ្សេងៗគ្នា។

៨ អ្នកទាំងឡាយស្គាល់ស្មៅនិងឈើ (ឬទេ) ឬក៏មិនដែលប្តេជ្ញាថា ស្មៅនិងឈើទេ លិង្គគឺភេទរបស់ស្មៅនិងឈើទាំងនោះ តែងសម្រេចអំពីជាតិ ព្រោះថាសត្វទាំងឡាយ មានជាតិផ្សេងៗគ្នា។

៩ លិង្គគឺភេទ តាំងអំពីកណ្តូប និងមមង រហូតដល់ ស្រមោចខ្មៅ និងស្រមោចក្រហម ទាំងនោះ តែងសម្រេចអំពីជាតិ ព្រោះថាសត្វទាំងឡាយ មានជាតិផ្សេងៗគ្នា។

១០ អ្នកទាំងឡាយស្គាល់ ពួកសត្វមានជើងបួន ទាំងតូចទាំងធំ (ឬទេ) លិង្គគឺភេទរបស់សត្វទាំងនោះ តែងសម្រេចអំពីជាតិ ព្រោះថា សត្វទាំងឡាយមានជាតិផ្សេងៗគ្នា។

១១ អ្នកទាំងឡាយ ស្គាល់ពស់មានទ្រូងជាជើង មានខ្នងវែង (ឬទេ) លិង្គគឺភេទរបស់ពស់ទាំងនោះ តែងសម្រេចអំពីជាតិ ព្រោះថា សត្វទាំងឡាយមានជាតិផ្សេងៗគ្នា។

១២ លំដាប់អំពីនោះ អ្នកទាំងឡាយ ស្គាល់ពួកត្រីក្នុងទឹក មានទឹកជាគោចរ (ឬទេ) លិង្គគឺភេទរបស់ត្រីទាំងនោះ តែងសម្រេចអំពីជាតិ ព្រោះថា សត្វទាំងឡាយមានជាតិផ្សេងៗគ្នា។

១៣ លំដាប់អំពីនោះ អ្នកទាំងឡាយ ស្គាល់ពួកសត្វស្លាប មានស្លាបជាយាន ដែលហើរឯអាកាស (ឬទេ) លិង្គគឺភេទរបស់សត្វស្លាបទាំងនោះ រមែងសម្រេចអំពីជាតិ ព្រោះថា សត្វទាំងឡាយមានជាតិផ្សេងៗគ្នា។

១៤ លិង្គគឺភេទក្នុងជាតិទាំងឡាយនោះ សម្រេចអំពីជាតិជាច្រើនៗ

១៥ យ៉ាងណាមិញ លិង្គគឺភេទ ក្នុងមនុស្សទាំងឡាយ សម្រេចអំពីជាតិ មិនច្រើនយ៉ាងនោះទេ។

លិង្គគឺភេទ មិនហៅ ព្រោះសក់ទាំងឡាយ មិនហៅ ព្រោះក្បាលទាំងឡាយ មិនហៅ ព្រោះត្រចៀកទាំងឡាយ មិនហៅ ព្រោះភ្នែកទាំងឡាយ។

១៦ លិង្គគឺភេទ មិនហៅ ព្រោះប្រមាត់ មិនហៅ ព្រោះច្រមុះ មិនហៅ ព្រោះបបូរមាត់ទាំងឡាយ មិនហៅ ព្រោះចិញ្ចើមទាំងឡាយ មិនហៅ ព្រោះក មិនហៅ ព្រោះស្មាទាំងឡាយ មិនហៅ ព្រោះពោះ មិនហៅ ព្រោះខ្នង មិនហៅ ព្រោះត្រគាក មិនហៅ ព្រោះទ្រូង មិនហៅ ព្រោះទីចង្អៀត មិនហៅ ព្រោះមេថុន។

១៧ មិនហៅ ព្រោះដៃទាំងឡាយ មិនហៅ ព្រោះជើងទាំងឡាយ មិនហៅ ព្រោះរោមទាំងឡាយ មិនហៅ ព្រោះក្រចកទាំងឡាយ មិនហៅ ព្រោះស្មងទាំងឡាយ មិនហៅ ព្រោះភ្លៅទាំងឡាយ មិនហៅ ព្រោះពណ៌ មិនហៅ ព្រោះសំឡេងទេ លិង្គភេទរបស់មនុស្សសម្រេចអំពីជាតិ មិនដូចជាភេទ ក្នុងជាតិទាំងឡាយឯទៀតៗទេ។

១៨ លិង្គភេទផ្សេងដោយសណ្ឋាន មានសក់ជាដើម ដូចជាលិង្គភេទ តិរច្ឆានទាំង មិនមាន ប្រាកដក្នុងសរីរៈរបស់ខ្លួនទាំងឡាយ ក្នុងពួកមនុស្សទេ ពាក្យសម្រាប់ហៅ (ថាព្រាហ្មណ៍ ជាដើម) គេតែងហៅតាមឈ្មោះ ក្នុងមនុស្សទាំងឡាយ។

១៩ បណ្ដាមនុស្សទាំងឡាយ នរណាមួយ ចិញ្ចឹមជីវិតដោយការរក្សាស្រែចំការ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះជាអ្នកកសិករ មិនមែនព្រាហ្មណ៍ទេ។

២០ បណ្ដាមនុស្សទាំងឡាយ នរណាមួយ ចិញ្ចឹមជីវិតដោយសិល្បៈ ច្រើនយ៉ាង ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះជាអ្នកចិញ្ចឹម ជីវិតដោយសិល្បៈ មិនមែនព្រាហ្មណ៍ទេ។

២១ បណ្ដាមនុស្សទាំងឡាយ នរណាមួយ ចិញ្ចឹមជីវិតដោយការជួញប្រែ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះជាពាណិជ្ជ មិនមែនព្រាហ្មណ៍ទេ។

២២ បណ្ដាមនុស្សទាំងឡាយ នរណាមួយ ចិញ្ចឹមជីវិតដោយការបំរើអ្នកដទៃ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះជាអ្នកបំរើ មិនមែនព្រាហ្មណ៍ទេ។

២៣ បណ្ដាមនុស្សទាំងឡាយ នរណាមួយ ចិញ្ចឹមជីវិតដោយការលួចទ្រព្យគេ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះជាចោរ មិនមែនព្រាហ្មណ៍ទេ។

២៤ បណ្ដាមនុស្សទាំងឡាយ នរណាមួយ ចិញ្ចឹមជីវិតដោយភាពជាអ្នកកាន់អាវុធ (ទាហាន) ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះជាអ្នកចិញ្ចឹមជីវិតដោយភាពជាទាហាន មិនមែនព្រាហ្មណ៍ទេ។

២៥ បណ្ដាមនុស្សទាំងឡាយ នរណាមួយ ចិញ្ចឹមជីវិតដោយភាពជាបុរោហិត ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះជាអ្នកបូជា មិនមែនព្រាហ្មណ៍ទេ។

២៦ បណ្ដាមនុស្សទាំងឡាយ នរណាមួយ បរិភោគនូវធរណីផលដែលកើតអំពីស្រុក ឬដែន (ស្ដេច) ប្រើប្រាស់ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ អ្នកនោះជាស្ដេច មិនមែនព្រាហ្មណ៍ទេ។

២៧ តថាគត មិនហៅបុគ្គលដែលមានកំណើតកើតអំពីមាតា ថាជាព្រាហ្មណ៍ទេ បុគ្គលនោះ ឈ្មោះថា ភោវាទី បុគ្គលនោះប្រកបដោយគ្រឿងកង្វល់ តថាគតហៅបុគ្គលដែលមិនមានគ្រឿងកង្វល់ មិនមានកំណាន់នោះ ថាជាព្រាហ្មណ៍។

២៨ បុគ្គលណា កាត់សំយោជនៈទាំងអស់ហើយ មិនតក់ស្លុត តថាគតហៅបុគ្គលអ្នកកន្លងសង្គហធម៌ ប្រាសចាកយោគៈទាំង៤ នោះ ថាជាព្រាហ្មណ៍។

២៩ បុគ្គលណា កាត់ខ្សែជ្រាមគឺសេចក្ដីក្រោធផង ព្រ័ត្រគឺតណ្ហាផង ទីតគឺមិច្ឆាទិដ្ឋិ ព្រមទាំងអនុសយកិលេសផង ជាអ្នកបានដករនុកគឺអវិជ្ជា ត្រាស់ដឹងសច្ចធម៌៤ តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍។

៣០ បុគ្គលណា មិនប្រទូស្ត ចេះអត់ធ្មត់ ចំពោះពាក្យជេរផង ការវាយ នឹងការចងផង តថាគតហៅបុគ្គល អ្នកមានខន្តីធម៌ ជាកំឡាំង មានខន្តិធម៌ ជាវេហ៍ពលនោះ ថាជាព្រាហ្មណ៍។

៣១ តថាគត ហៅបុគ្គលមិនខឹង ជាអ្នកមានវត្ត មានសីលធម៌ មិនមានចំហាយគឺតណ្ហា មានឥន្ទ្រិយបានទូន្មាន មានសរីរៈកើតក្នុងទីបំផុតនោះ ជាព្រាហ្មណ៍។

៣២ បុគ្គលណា មិនជាប់ក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូចគ្រាប់ស្ពៃលើចុងនៃដែកស្រួច តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍។

៣៣ បុគ្គលណា ដឹងច្បាស់នូវការអស់ទៅនៃសេចក្ដីទុក្ខរបស់ខ្លួន ក្នុងលោកនេះ តថាគតហៅបុគ្គល អ្នកដាក់ភារៈចុះហើយ ប្រាសចាកយោគៈនោះ ថាជាព្រាហ្មណ៍។

៣៤ តថាគតហៅបុគ្គល មានប្រាជ្ញាជ្រាលជ្រៅ មានប្រាជ្ញាធ្មុងធ្មាយ ឆ្លៀវឆ្លាសក្នុងមគ្គនឹងមិនមែនមគ្គ បានសម្រេចប្រយោជន៍ខ្ពង់ខ្ពស់នោះ ថាជាព្រាហ្មណ៍។

៣៥ តថាគតហៅបុគ្គល អ្នកមិនច្រឡូកច្រឡំ ដោយបុគ្គលពីរពួក គឺគ្រហស្ថ១ បព្វជិត១ ដែលត្រាច់ទៅដោយមិនប្រកាន់លំនៅ មិនមានសេចក្ដីប្រាថ្នានោះ ថាជាព្រាហ្មណ៍។

៣៦ បុគ្គលណា ដាក់ចេញនូវអាជ្ញា ក្នុងពួកសត្វអ្នកតក់ស្លុតនឹងពួកសត្វនឹងនួន មិនសម្លាប់ មិនបៀតបៀនសត្វ តថាគតហៅ

បុគ្គលនោះ ថាជាព្រាហ្មណ៍។

៣៧ តថាគតហៅបុគ្គល អ្នកមិនមានគំនុំ ក្នុងពួកជនដែលមានគំនុំ អ្នកមានចិត្តត្រជាក់ ចំពោះអាជ្ញារបស់ខ្លួន ជាអ្នកមិនប្រកាន់ក្នុងពួកជនអ្នកប្រកបដោយអំពើគួរប្រកាន់នោះ ថាជាព្រាហ្មណ៍។

៣៨ បុគ្គលណា បានទំលាក់ចោលចេញនូវរាគៈ ទោសៈ មានៈ នឹងមក្ខៈ ដូចគ្រាប់ស្ពៃ ដែលធ្លាក់អំពីចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍។

៣៩ បុគ្គលណា ពោលវាចាមិនត្រគោះ វាចាញុំាងគេឲ្យស្គាល់ច្បាស់នូវប្រយោជន៍ ជាសំដីពិត ដែលមិនញុំាងគេឲ្យចំពាក់ចិត្តតិចតួច (ដោយអំណាចញុំាងគេឲ្យខឹង) តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍។

៤០ បុគ្គលណា មិនកាន់យកទ្រព្យដែលគេមិនបានឲ្យ ទោះជាទ្រព្យវែងក្តី ខ្លីក្តី តូចក្តី ធំក្តី ល្អនិងមិនល្អក្តី ក្នុងលោក តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍។

៤១ បុគ្គលណាមិនមានសេចក្តីប៉ុនប៉ង ក្នុងលោកនេះក្តី ក្នុងលោកខាងមុខក្តី តថាគតហៅបុគ្គលអ្នកមិនមានសេចក្តីប៉ុនប៉ងប្រាសចាកកិលេសនោះ ថាជាព្រាហ្មណ៍។

៤២ បុគ្គលណា មិនមានសេចក្តីអាល័យ មិនមានការងឿងឆ្ងល់ ព្រោះដឹងច្បាស់ តថាគតហៅបុគ្គល អ្នកដល់នូវធម៌ជាគ្រឿងឈមទៅរកព្រះនិព្វានឈ្មោះអមតៈនោះ ថាជាព្រាហ្មណ៍។

៤៣ បុគ្គលណា (កាត់បង់) អំពើទាំងពីរ គឺបុណ្យ១ បាប១ កន្លងផុតនូវសង្គហធម៌ តថាគតហៅបុគ្គល អ្នកមិនមានសេចក្តីសោក ប្រាសចាកធូលីគឺ រាគៈជាដើម ជាបុគ្គលបរិសុទ្ធនោះ ថាជាព្រាហ្មណ៍។

៤៤ តថាគត ហៅអ្នកស្អាត ដូចព្រះចន្រ្ទ ប្រាសចាកមន្ទិលមានចិត្តថា មិនស្អប់ដោយកិលេស មានតណ្ហា ក្នុងភពអស់ហើយនោះ ថាជាព្រាហ្មណ៍។

៤៥ បុគ្គលណា កន្លងនូវផ្លូវវាងគឺរាគៈ នូវផ្លូវទុគ៌មគឺកិលេសនូវសង្សារវដ្ត នូវមោហៈ ជាអ្នកឆ្លង (នូវឱឃៈទាំង៤) បានដល់ត្រើយគឺនិព្វាន ជាអ្នកមានឈាន មិនមានសេចក្តីញាប់ញ័រ មិនមានសេចក្តីសង្ស័យ មិនប្រកាន់មាំ ជាអ្នករលត់កិលេស តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍។

៤៦ បុគ្គលណា លះកាមទាំងឡាយក្នុងលោកនេះ ជាអ្នកមិនមានផ្ទះ បួស តថាគតហៅបុគ្គលអ្នកមានកាមរាគៈអស់ហើយនោះ

ថាជាព្រាហ្មណ៍ ។

៤៧ បុគ្គលណា បានលះតណ្ហាក្នុងលោកនេះ ជាអ្នកមិនមានផ្ទះ តថាគត ហៅបុគ្គលដែលមានតណ្ហានឹងភពអស់ហើយនោះ ថាជាព្រាហ្មណ៍ ។

៤៨ បុគ្គលណា លះយោគៈ ជារបស់មនុស្ស កន្លងផុតនូវយោគៈ របស់ទិព្វ តថាគតហៅបុគ្គល ដែលប្រាសចាកយោគៈទាំងអស់នោះ ថាជាព្រាហ្មណ៍ ។

៤៩ តថាគត ហៅបុគ្គល អ្នកលះសេចក្ដីត្រេកអរ (ក្នុងកាមគុណ) នឹងសេចក្ដីអផ្សុក មានចិត្តត្រជាក់ មិនមានឧបធិ គ្របសង្កត់នូវលោកទាំងអស់ ជាអ្នកមានព្យាយាមនោះ ថាជាព្រាហ្មណ៍ ។

៥០ បុគ្គលណា បានដឹងច្បាស់នូវចុតិនឹងបដិសន្ធិ របស់សត្វទាំងឡាយ ដោយសព្វគ្រប់ តថាគតហៅបុគ្គល អ្នកមិនជាប់ចំពាក់ មានដំណើរល្អ ត្រាស់ដឹងសច្ចធម៌នោះ ថាជាព្រាហ្មណ៍ ។

៥១ ទេវតា គន្ធព្វនឹងមនុស្សទាំងឡាយ មិនដឹងគតិរបស់បុគ្គលណា តថាគតហៅបុគ្គល ដែលអស់អាសវៈហើយ ឆ្ងាយចាកកិលេសនោះ ថាជាព្រាហ្មណ៍ ។

៥២ បុគ្គលណា មិនមានសេចក្ដីកង្វល់គឺកិលេស មានរាគៈជាដើម ក្នុងអតីតក្ខន្ធ អនាគតក្ខន្ធ និងបច្ចុប្បន្នក្ខន្ធ តថាគតហៅបុគ្គល ដែលមិនមានគ្រឿងកង្វល់ មិនមានការប្រកាន់ស្អិតនោះថាជាព្រាហ្មណ៍។

៥៣ តថាគត ហៅបុគ្គលអ្នកអង់អាចដូចគោឧសភ អ្នកប្រសើរ មានប្រាជ្ញា ស្វែងរកគុណដ៏ធំ មានជ័យជំនះ មិនមានសេចក្ដីញាប់ញ័រ ងូតលាង (នូវកិលេស) ត្រាស់ដឹងសច្ចធម៌នោះ ថាជាព្រាហ្មណ៍។

៥៤ បុគ្គលណា ដឹងច្បាស់នូវបុព្វេនិវាសផង ឃើញឋានសួគ៌ និងអបាយផង ទាំងដល់នូវធម៌ជាទីក្ស័យនៃជាតិ តថាគតហៅបុគ្គល នោះថាជាព្រាហ្មណ៍។

៥៥ នាមនិងគោត្រណា ដែលគេបានកំណត់ទុកហើយ (ថាព្រាហ្មណ៍ ក្សត្រិណ៍) នេះគ្រាន់តែជាឈ្មោះ (ជាបញ្ញត្តិវោហារ) ក្នុងលោក (ព្រោះនាមនិងគោត្រនោះ) គឺ ពួកញាតិសាលោហិតបានផ្សំផ្គុំកំណត់ទុកហើយ ក្នុងកាលដែលកើតមកនោះៗ។

៥៦ ទិដ្ឋិរបស់ពួកជនដែលមិនដឹង តែងដេកត្រាំអស់កាលអង្វែង ពួកជន ដែលមិនដឹងហ្នឹងឯង តែងនាំគ្នានិយាយថាបុគ្គលឈ្មោះថា

ព្រាហ្មណ៍ ព្រោះជាតិ។

៥៧ បុគ្គល មិនមែនឈ្មោះថាព្រាហ្មណ៍ ព្រោះជាតិទេ បុគ្គល មិនមែនព្រាហ្មណ៍ ក៏មិនមែនព្រោះជាតិដែរ បុគ្គលឈ្មោះថា ព្រាហ្មណ៍ ព្រោះកម្ម (ការងារ) ឈ្មោះថា មិនមែនព្រាហ្មណ៍ ក៏ ព្រោះកម្ម។

៥៨ បុគ្គល ឈ្មោះថាអ្នកភ្ជួររាស់ ព្រោះកម្ម ឈ្មោះថាអ្នកមាន សិល្បសាស្ត្រ ព្រោះកម្ម។

៥៩ បុគ្គលឈ្មោះថាអ្នកជំនួញ ក៏ព្រោះកម្ម ឈ្មោះថាអ្នកបំរើ ក៏ព្រោះកម្ម ឈ្មោះថាចោរ ក៏ព្រោះកម្ម ឈ្មោះថាយោធាជីវៈ ក៏ព្រោះកម្ម ឈ្មោះថាយាជកៈ (អ្នកបូជា) ក៏ព្រោះកម្ម ឈ្មោះថា ស្ដេច ក៏ព្រោះកម្ម។

៦០ បណ្ឌិតទាំងឡាយ អ្នកឃើញបដិច្ចសមុប្បាទ (ថាវត្ថុយ៉ាង នេះកើតឡើងដោយបច្ច័យនេះ) ឈ្លាសវៃក្នុងកម្មនឹងវិបាក រមែង ឃើញកម្មនុ៎ះ តាមសេចក្ដីពិតយ៉ាងនេះ។

៦១ លោករមែងប្រព្រឹត្តទៅ ព្រោះកម្ម ប្រជាជនក៏ប្រព្រឹត្តទៅ ព្រោះកម្ម ពួកសត្វជាប់ចំពាក់ ដោយកម្ម (ទើបប្រព្រឹត្តទៅបាន ដូចភ្លៅនៃរថ ដែលវិលទៅ)។

៦២ បុគ្គលឈ្មោះថា ព្រាហ្មណ៍បាន ដោយកម្មនេះ គឺតបធម៌ (ការសង្រួមឥន្ទ្រិយ) ១ ព្រហ្មចរិយៈ (ការប្រព្រឹត្តិប្រសើរ) ១ សញ្ញមៈ (ការសង្រួមក្នុងសីល) ១ ទមៈ (ការទូន្មាន) ១ កម្មដ៏ឧត្តមនេះឯងដែលធ្វើឲ្យទៅជាព្រាហ្មណ៍។

៦៣ បុគ្គលអ្នកបរិបូណ៌ ដោយវិជ្ជា៣ ប្រការ ជាអ្នកស្ងប់ មានភពថ្មីអស់ហើយ ទើបឈ្មោះថាព្រះព្រហ្ម ឈ្មោះថាព្រះឥន្ទ្រ របស់អ្នកប្រាជ្ញាទាំងឡាយ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះចុះ។

កាលដែលព្រះមានព្រះភាគ សំដែងយ៉ាងនេះហើយ វាសេដ្ឋមាណព នឹងភារទ្វាជមាណព ក៏សរសើរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចំរើន ច្បាស់ណាស់ ។បេ។ សូមព្រះគោតមដ៏ចំរើន ចំណាំនូវពួកយើង ថាជាឧបាសក អ្នកដល់សរណគមន៍ ស្មើដោយជីវិត ក្នុងកាលតាំងអំពីថ្ងៃនេះជាដើមតរៀងទៅ៕